

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍

លេខ: ០០៦សសរ..គជទ

សេចក្តីសម្រេច

ស្តីពី

ការដាក់ឱ្យប្រើប្រាស់ផែនការសកម្មភាពផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប

ឆ្នាំ២០២១ -២០៣៥

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

និងជាគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៨២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញសេចក្តីសម្រេចលេខ ៤៣/សសរ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប
- បានឃើញផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២១-២០៣៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប

សម្រេច

ប្រការ១ ._

ត្រូវបានដាក់ឱ្យអនុវត្តផែនការសកម្មភាពនៃផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ ២០២១-២០៣៥។

ផែនការសកម្មភាពលម្អិតជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

ប្រការ២ ._

ដើម្បីធានាការអនុវត្តផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២១-២០៣៥ ឱ្យមានប្រសិទ្ធភាពខ្ពស់ ផែនការសកម្មភាពនេះអាចត្រូវបាន ពិនិត្យ កែសម្រួល ស្របតាមការវិវត្តនៃផែនការមេ និងស្ថានភាពជាក់ស្តែងនៃវិស័យទេសចរណ៍ សេដ្ឋកិច្ច និងសង្គម នៅកម្ពុជា។

គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ អាចធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពនៃផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប តាមការចាំបាច់ស្របតាមនីតិវិធី និងបទដ្ឋានគតិយុត្តជាធរមាន។

ប្រការ៣ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ៤ ._

រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា រដ្ឋមន្ត្រីក្រសួងបរិស្ថាន សមាជិក សមាជិកានៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០២១

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និងជាប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ.០០៦ចុះថ្ងៃទី.២៧...ខែ.មិថុនា.ឆ្នាំ.ឆ្នាំ២០២១

ស្តីពី

"ផែនការសកម្មភាពនៃផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ២០២១-២០៣៥"

I. តារាងបរិយាយសកម្មភាពអនុវត្តលម្អិត 4

II. តារាងគម្រោងសកម្មភាពអាទិភាព..... 61

I. តារាងបរិយាយសកម្មភាពអនុវត្តលម្អិត

១. យុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ទេសចរណ៍អាទិភាពក្នុងខេត្តសៀមរាប 5
២. យុទ្ធសាស្ត្រអភិវឌ្ឍន៍ផលិតផលទេសចរណ៍ថ្មីៗ 27
៣. យុទ្ធសាស្ត្រផ្សព្វផ្សាយ និងទាក់ទាញទេសចរណ៍ខេត្តសៀមរាប 35
៤. យុទ្ធសាស្ត្រពង្រឹងគុណភាព និងនិរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍ខេត្តសៀមរាប 40
៥. យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងបរិស្ថាននៅខេត្តសៀមរាប 49
៦. យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងការតភ្ជាប់គាំទ្រវិស័យទេសចរណ៍នៅខេត្តសៀមរាប 52
៧. ផែនការសកម្មភាព និងអភិបាលកិច្ចសម្រាប់ទ្រទ្រង់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តសៀមរាប 59

ល.រ	យុទ្ធសាស្ត្រ	សកម្មភាពអនុវត្ត	បរិយាយសកម្មភាព	ទីតាំងគម្រោង	ប្រភពថវិកា	ថវិកា (ដាន់ដុល្លារ USD)	អង្គភាពអនុវត្ត	រយៈពេលនៃការអនុវត្ត		
								ខ្លី	មធ្យម	វែង
								២០២១-២០២៣	២០២៤-២០៣០	២០៣១-២០៣៥
I.	យុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ទេសចរណ៍អាទិភាពក្នុងខេត្តសៀមរាប									
១	តំបន់ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម-"ភ្នំគូលែន"			ភ្នំគូលែន						
១.១	ការអភិវឌ្ឍទេសចរណ៍សាសនា និងទេសចរណ៍ជំនឿ	១- បង្កើតអាស្រមនិងមណ្ឌលសមាធិ	• សាងសង់ទីកន្លែងសម្រាប់ភ្ញៀវទេសចរដែលមកទស្សនាបែបសាសនា	ភ្នំគូលែន	រដ្ឋ	០,០៥	- ប.ស្ថ - DMO	▪		
		២- រៀបចំព្រឹត្តិការណ៍សាសនាប្រចាំឆ្នាំ	• រៀបចំបុណ្យទានធំៗ ជាព្រឹត្តការណ៍ប្រចាំឆ្នាំ ដូចជាបុណ្យពិសាខបូជា ចូលឆ្នាំខ្មែរ បិណ្ឌសនាគចូលវស្សា ជាដើម ដើម្បីជំរុញទេសចរណ៍សាសនា និងទាក់ទាញភ្ញៀវទេសចរទៅតំបន់ភ្នំគូលែន • សិក្សាពីការប្រតិបត្តិសាសនា មរតកអរូបីរបស់សហគមន៍នៅតំបន់ភ្នំគូលែន • សិក្សាលទ្ធភាពឱ្យមានការរៀបចំកម្មវិធីផ្សេងៗ ដែលមិនប៉ះពាល់ដល់រមណីយដ្ឋាន	ភ្នំគូលែន	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - ប.ស្ថ - អ.ធ.អ - DMO	▪	▪	▪
១.២	ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងអេកូទេសចរណ៍	៣- អភិវឌ្ឍ និងការគ្រប់គ្រងបរិវេណរមណីយដ្ឋានទឹកធ្លាក់ធំ	• ការពារមិនឱ្យមានអ្នកលក់ដូរនៅទីតាំងជិតទឹកធ្លាក់ធំ ដែលមានប្រាសាទចាស់បុរាណកំពុងមានការបាក់បែក • ស្តារ និងជួសជុលផ្លូវ និងជណ្តើរឆ្ពោះទៅកាន់ទឹកធ្លាក់ធំដើម្បីផ្តល់សុវត្ថិភាព និងភាពងាយស្រួលដល់ភ្ញៀវទេសចរ ទាំងកុមារ វយ័ក្មេង វ័យកណ្តាល និងវ័យចំណាស់ • រៀបចំផ្លូវធំថ្មីតភ្ជាប់ភ្នំគូលែនទៅកាន់តំបន់បេតិកភណ្ឌអង្គរ	ភ្នំគូលែន	រដ្ឋ-ឯកជន និងដៃគូអភិវឌ្ឍ	១០	- វ.ប.ស - ប.ស្ថ - អ.ធ.អ - DMO		▪	

			• ជួសជុលផ្លូវចាស់ឱ្យមានសភាពងាយស្រួលក្នុងការធ្វើដំណើរផងដែរ ព្រមទាំងដាក់ចេញជាគម្រោងថែរក្សាជាប្រចាំនូវផ្លូវដែលសាងសង់រួចហើយ							
		៤-ពង្រឹងសហគមន៍មូលដ្ឋាននៅលើឧទ្យានជាតិភ្នំគូលែន	• ពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់សហគមន៍មូលដ្ឋាន ឱ្យក្លាយជាសហគមន៍អេកូទេសចរណ៍ រួមចំណែកដល់ការលើកកម្ពស់កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ព្រមទាំងជំរុញការរស់នៅប្រកបដោយចីរភាព ដោយធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចនៅតាមសហគមន៍មូលដ្ឋាននីមួយៗ	ភ្នំគូលែន	រដ្ឋ-ឯកជន	TBD	- ប.ស្ថ - ក.ទ.ច - DMO	▪	▪	▪
		៥- បង្កើតសួនទេសចរណ៍	• រៀបចំយុទ្ធនាការ **"ទេសចរម្នាក់ ដើមឈើមួយដើម"** ដើម្បីបង្កើនការដាំដើមឈើឡើងវិញដោយបង្កើតសួនទេសចរណ៍ និងជំរុញឱ្យភ្ញៀវទេសចរចូលរួមដាំដើមឈើអនុស្សាវរីយ៍ដូចជា ក្រញូង បេង ។ល។	ភ្នំគូលែន	រដ្ឋ	១	- ប.ស្ថ - DMO		▪	
១.៣	ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងទេសចរណ៍ផ្សងព្រេង	៦- បង្កើតទេសចរណ៍ផ្សងព្រេងតាមរយៈការធ្វើដំណើរនៅក្នុងព្រៃ (Trekking)	• បង្កើតខ្សែទស្សនកិច្ចដំណើរផ្សងព្រេងបេតិកភណ្ឌមហេន្ទ្របរពិត បង្ហាញពីប្រាសាទបុរាណល្អបំផុតនៅលើភ្នំគូលែន ដោយធ្វើដំណើរថ្មើរជើង ជិះកង់ និងម៉ូតូ	ភ្នំគូលែន	រដ្ឋ-ឯកជន	២	- ក.ទ.ច - វ.ជ - DMO		▪	
			• ថែទាំ និងរៀបចំ ផ្លូវលំទៅកាន់បុរាណដ្ឋាន ពើង និងទីតាំងទេសចរណ៍សំខាន់ៗ ដូចជា ផ្លូវថ្មើរជើង ជិះកង់ និងម៉ូតូ ឱ្យមានសុវត្ថិភាពក្នុងការទស្សនាកម្សាន្តទេសចរណ៍បែបផ្សងព្រេង	ភ្នំគូលែន	រដ្ឋ-ឯកជន	៣	- ក.ទ.ច - ប.ស្ថ - រ.ប.ស - DMO			▪
		៧- បង្កើតសកម្មភាពកម្សាន្តនៅលើទីខ្ពស់	• សិក្សាលទ្ធភាពបង្កើតការដើរកម្សាន្តបម្លាស់ទីលើខ្សែពួរ • សិក្សាលទ្ធភាពដំណើរកម្សាន្តបម្លាស់ទីលើខ្សែពួរដែលមានកម្ពស់ខ្ពស់	ភ្នំគូលែន	ឯកជន	២	- ប.ស្ថ - ក.ទ.ច - រ.ប.ស			▪

							- DMO			
១.៤	ការអភិវឌ្ឍគោលដៅទេសចរណ៍ស្រាវជ្រាវ និងវិទ្យាសាស្ត្រ	៨- អភិវឌ្ឍគោលដៅទេសចរណ៍ស្រាវជ្រាវ និងវិទ្យាសាស្ត្រ	• ជំរុញផ្សព្វផ្សាយ និងលើកកម្ពស់ **"មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរភ្នួល សម្តេចវិបុលបញ្ញា សុខ អាន ភ្នំគួលែន"** ដើម្បីឱ្យភ្ញៀវទេសចរជាតិ និងអន្តរជាតិបានសិក្សាស្រាវជ្រាវ និងបានយល់ដឹង • ជំរុញឱ្យមានដំណើរទស្សនកិច្ចសិក្សារបស់អ្នកជំនាញជាតិ និងភ្ញៀវទេសចរអន្តរជាតិនៅមជ្ឈមណ្ឌល ភ្ជាប់ជាមួយនឹងការទស្សនាភ្នំគួលែន (សត្វ និងរុក្ខជាតិ)	ភ្នំគួលែន	រដ្ឋ	TBD	- ប.ស្ថ - ក.ទ.ច - ឧ.ជ.ភ.គ - អ.ធ.អ - DMO	▪		
១.៥	ការពង្រឹងគុណភាពសេវាកម្មទេសចរណ៍នៅក្នុងឧទ្យានជាតិភ្នំគួលែន	៩- បង្កើតមធ្យោបាយធ្វើដំណើរងាយស្រួល និងមានសុវត្ថិភាព	• សិក្សាលទ្ធភាពបង្កើតរថភ្លើងអគ្គិសនី ឬកន្ត្រកឡើងភ្នំ និងចុះពីភ្នំគួលែន ព្រមទាំងសិក្សាពីផលប៉ះពាល់សង្គម វប្បធម៌ និងបរិស្ថាន	ភ្នំគួលែន	ឯកជន	១00	- រ.ប.ស - អ.ធ.អ - ក.ទ.ច - DMO			▪
		១០- ពង្រឹងការអប់រំការយល់ដឹងអំពីបរិស្ថានស្អាត	• ពង្រឹងការអប់រំការយល់ដឹងអំពីបរិស្ថានស្អាត និងផ្សព្វផ្សាយ អំពីផលប៉ះពាល់នៃការចោលកាកសំណល់រឹង-រាវ, ផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍សារតាមអនឡាញ ការផ្សាយពាណិជ្ជកម្មតាមផ្ទាំងផ្សព្វផ្សាយ និងស្លាកសញ្ញាយុទ្ធនាការនៅគ្រប់ឃុំ/ស្រុក/ខេត្ត • អនុវត្តយុទ្ធនាការ **"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ"** ឱ្យបានសកម្ម និងមានប្រសិទ្ធភាពក្នុងតំបន់ទេសចរណ៍	ភ្នំគួលែន	រដ្ឋ	TBD	- ប.ស្ថ - ឧ.ជ.ទ - DMO	▪		
		១១- ពង្រឹងការទទួលខុសត្រូវរបស់វិនិយោគិន និងប្រតិបត្តិករទេសចរណ៍	• ជំរុញឱ្យប្រតិបត្តិករទេសចរណ៍ វិនិយោគិនទេសចរណ៍ ត្រូវគោរពតាមគោលការណ៍ **"ការទទួលខុសត្រូវផ្នែកសង្គម"** ក្នុងនោះត្រូវគោរព និងអនុវត្តតាមសៀវភៅបន្ទុកច្បាស់លាស់។ រាល់សម្បទាទេសចរណ៍នៅក្នុងឧទ្យានជាតិភ្នំគួលែនត្រូវអភិវឌ្ឍស្របតាមស្តង់ដាគុណភាព	ភ្នំគួលែន	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - ប.ស្ថ - DMO	▪		

			អនុវត្តន្ធវស្តង់ដាធុរកិច្ចបៃតងនៅតាមសម្បទាទេសចរណ៍ទាំងអស់នៅក្នុងឧទ្យានជាតិភ្នំគូលែន តាមរយៈយន្តការ **"ទិន្នលខុសត្រូវផ្នែកសង្គម"** ដោយផ្អែកលើសៀវភៅបន្ទុកច្បាស់លាស់ ហើយរាល់សម្បទាទេសចរណ៍នៅក្នុងឧទ្យានត្រូវអភិវឌ្ឍស្របតាមស្តង់ដាគុណភាព							
		១២-ពង្រឹងប្រសិទ្ធភាពនៃការផ្តល់ព័ត៌មានសម្រាប់ភ្ញៀវទេសចរ	• បង្កើតមជ្ឈមណ្ឌលផ្តល់ព័ត៌មាន និងតាំងពិព័រណ៌ • រៀបចំផ្ទាំងព័ត៌មាន ផែនទី និងស្លាកសញ្ញាបង្ហាញផ្លូវ បង្ហាញចម្ងាយ និងរយៈពេលទៅកាន់គោលដៅទស្សនាទីមួយៗ • រៀបចំ និងប្រើប្រាស់ប្រភេទបច្ចេកវិទ្យាទំនើបៗ ជាជំនួយ ដូចជាបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត បច្ចេកវិទ្យា VR និង AR (Virtual Reality & Augmented Reality) និងការប្រើប្រាស់ផែនទីអនឡាញជាដើម	ភ្នំគូលែន	រដ្ឋ និងដៃគូអភិវឌ្ឍ	TBD	- ក.ប.ទ - ក.ទ.ច - ប.ស្ថ - DMO		▪	
១.៦	យន្តការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍តំបន់ឧទ្យានជាតិភ្នំគូលែន	១៣- បង្កើត **"អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍"** តំបន់ឧទ្យានជាតិភ្នំគូលែន	• បង្កើត **"អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍"** ដែលនឹងក្លាយជាអ្នកអភិវឌ្ឍ និងគ្រប់គ្រងទេសចរណ៍ក្នុងតំបន់ឧទ្យានជាតិភ្នំគូលែន។ អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែកនេះ ស្ថិតក្រោមទម្រង់ចម្រុះ ភាពជាដៃគូរដ្ឋ-ឯកជន ឬភាពជាដៃគូ សហគមន៍-រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍ	ភ្នំគូលែន	រដ្ឋ និងដៃគូអភិវឌ្ឍ	TBD	-គ.អ.ទ.ស	▪		
	សរុប÷ យុទ្ធសាស្ត្រ ចំនួន០៦ សកម្មភាពអនុវត្តចំនួន ១៣									
២	**តំបន់ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី**			**បន្ទាយស្រី**						

២.១	ការអភិវឌ្ឍទេសចរណ៍តំបន់បន្ទាយស្រីជាតំបន់ទេសចរណ៍ដ៏ទាក់ទាញថ្មីសម្រាប់ខេត្តសៀមរាប	១- លើកកម្ពស់ភាពទាក់ទាញទេសចរណ៍ប្រាសាទបន្ទាយស្រីផ្សារភ្ជាប់តំបន់ជុំវិញ	• បង្កើតសៀគ្វីទេសចរណ៍បន្ទាយស្រី • ពង្រឹងការអភិវឌ្ឍធនធានមនុស្ស និងការពង្រឹងគុណភាពសេវាកម្មទេសចរណ៍ក្នុងខ្សែចង្វាក់នៃសៀគ្វីទេសចរណ៍នីមួយៗ ផ្សារភ្ជាប់នឹងប្រាសាទបន្ទាយស្រី • ដាក់ប្រាសាទបន្ទាយស្រី ជាចំណុចស្នូលនៃយុទ្ធសាស្ត្រផ្សព្វផ្សាយទេសចរណ៍តំបន់បន្ទាយស្រី	បន្ទាយស្រី	រដ្ឋ	TBD	- ក.ទ.ច - រ.ប.ស - អ.ធ.អ -DMO	▪		
		២- លើកកម្ពស់គម្រោងភូមិធម្ម-ជាតិ និងផ្សព្វផ្សាយរុនតាឯក	• បង្កើតខ្សែទស្សនកិច្ចដោយថ្មើរជើង ទោចក្រយាន ឬយានជំនិះស្រាលៗ ជាប្រព័ន្ធប្រទាក់ក្រឡាពីក្រុមមួយទៅក្រុមមួយរបស់លំនៅឋានក្នុងសហគមន៍ ក្រោមផ្នែបែតងនៃរក្ខជាតិ • រៀបចំបង្កើនបរិស្ថានធម្មជាតិឱ្យបានល្អប្រសើរ ប្រកបដោយគុណភាព និងសកម្មភាពចម្រុះ • បង្កើតភោគផលកសិកម្មសុវត្ថិភាពសម្បូរបែប (ស្រូវ ដំណាំ បន្លែ ដើមឈើហូបផ្លែ ផលិតផលសាច់សត្វ និងត្រី...), • បង្កើតសិប្បកម្ម ធ្វើអំពីធនធានព្រៃឈើដែលមាន (ឈើ ឫស្សី រពាក់ស្លឹកត្នោត ស្លឹករំចេកផ្កា..., • បង្កើតទេសចរណ៍ធម្មជាតិ ផ្អែកលើការប៉ិនប្រសប់របស់ប្រជាជនផ្នែកវប្បធម៌ សិល្បៈ និងរៀបចំឱ្យមានការទស្សនាលំនៅឋានភូមិករក្នុងតំបន់រុនតាឯក ដោយថ្មើរជើង ជិះកង់ ឬរទេះជាដើម • ពង្រឹងធនធានមនុស្សគ្រប់វិស័យ តាមតម្រូវការជីវភាពអ្នកភូមិដូចជាជួសជុលកង់ ម៉ូតូ វិទ្យុ ទូរទស្សន៍ និងការផលិតរបស់របរប្រើប្រាស់ក្នុងផ្ទះ និងឧបករណ៍ដែលប្រើប្រាស់ប្រចាំថ្ងៃជាដើម។	បន្ទាយស្រី	រដ្ឋ-ឯកជន	TBD	- អ.ធ.អ - ក.ទ.ច - វ.ឯ -DMO	▪		

		៣- សិក្សាលទ្ធភាពកែលម្អរង្វង់មូលភ្នំគូលែន(ស្រុកបន្ទាយស្រី) ឱ្យក្លាយជាតំបន់ប្រជុំជនទេសចរណ៍	• កែសម្រួលកាំរង្វង់ឱ្យតូចជាងសភាពបច្ចុប្បន្ន (១៨៥មែត្រ) ដោយរៀបចំមានបំពាក់ភ្លើងបំភ្លឺផ្លូវ និងស្លាកសញ្ញាបង្ហាញទិសចរាចរណ៍, រង្វង់ជុំវិញត្រូវមានការរៀបចំឱ្យមានផ្លូវថ្មើរជើងសម្រាប់ទេសចរណ៍ និងសួនច្បារកម្សាន្ត, រៀបចំឱ្យមានកន្លែងសម្រាកលំហែ កន្លែងអង្គុយលេងសម្រាប់ភ្ញៀវទេសចរ, និងកែលម្អផ្លូវឆ្ពោះទៅកាន់ឧទ្យានជាតិភ្នំគូលែនដែលមានជាផ្លូវទៅ និងត្រលប់មកវិញ មានផ្លូវសម្រាប់រថយន្តទេសចរណ៍ ផ្លូវម៉ូតូ និងផ្លូវជិះកង់ផងដែរ។	បន្ទាយស្រី	រដ្ឋ-ឯកជន	១	- រ.ប.ស -DMO		▪	
		៤- លើកកម្ពស់គុណភាព និងផ្សព្វផ្សាយកញ្ចប់សៅកម្មទេសចរណ៍នៅតំបន់បន្ទាយស្រី	• បន្តរៀបចំកម្មវិធីទស្សនាចរទៅកាន់តំបន់បន្ទាយស្រី ដោយរៀបចំនូវប្រធានបទថ្មីៗ ប្លែកៗ • ពង្រឹងគុណភាពសេវាកម្មទេសចរណ៍ដោយត្រូវរៀបចំសម្បទាគាំទ្រចាំបាច់ជាអាទិ៍÷ រៀបចំផ្លូវជិះកង់ និងតំបន់សម្រាប់អ្នកជិះកង់, រៀបចំស្លាកសញ្ញាប្រាប់ទិស ព្រមទាំង ពង្រឹងការគ្រប់គ្រងបរិស្ថាន **"ភាពស្អាត និងបៃតង"** ដោយពង្រឹងការគ្រប់គ្រងសំណល់ និងបំពាក់ធុងសំរាម, រៀបចំបង្គន់សាធារណៈឱ្យបានគ្រប់គ្រាន់ • រៀបចំសិក្ខាសាលា និងយុទ្ធនាការទាក់ទងនឹងបរិស្ថាន បង្កើត **"យុទ្ធនាការបន្ទាយស្រីស្អាត"** • ផ្តល់ជំនួយបច្ចេកទេសលើការធ្វើកសិកម្មសរីរាង្គបង្កើតកសិដ្ឋានអប់រំ ព្រមទាំងការអនុវត្តកសិកម្មល្អ • បង្កើនការផ្សព្វផ្សាយទេសចរណ៍តំបន់បន្ទាយស្រី ដោយត្រូវអភិវឌ្ឍម៉ាកទេសចរណ៍សម្រាប់តំបន់បន្ទាយស្រី តាមរយៈការបង្កើតរូបសញ្ញាជាក់លាក់បោះពុម្ពខិត្តបណ្ណផ្សព្វផ្សាយ បង្កើតគេហទំព័រ និងកម្មវិធីផ្សព្វផ្សាយតាមទូរសព្ទដៃ។	បន្ទាយស្រី	រដ្ឋ-ឯកជន	០,៥	- ក.ទ.ច - វ.ឯ - រ.ប.ស - អ.ធ.អ -DMO	▪		

២.២	ការលើកស្ទួយតម្លៃធនធានធម្មជាតិ និងទាញយកផលប្រយោជន៍សេដ្ឋកិច្ចឱ្យបានជាអតិបរមាតាមរយៈវិស័យទេសចរណ៍	៥- ជំរុញនិងលើកកម្ពស់ខ្សែក្រវ៉ាត់បៃតងក្នុងតំបន់បន្ទាយស្រី	• គិតគួរដល់ការអភិវឌ្ឍផលិតផលកសិកម្មបម្រើឱ្យការផ្គត់ផ្គង់ដល់សណ្ឋាគារ និងភោជនីយដ្ឋាននៅខេត្តសៀមរាប ពិសេសផលិតផលកសិកម្មសរីរាង្គក្នុងស្រុក • បង្កើនការផ្គត់ផ្គង់ស្រូវអង្ករ, បង្កើនការផ្គត់ផ្គង់ផលិតកម្មសត្វ, និងបង្កើនការផ្គត់ផ្គង់បន្លែ ដល់ឧស្សាហកម្មទេសចរណ៍នៅខេត្តសៀមរាប • រៀបចំឱ្យមានកិច្ចសហការភាពជាដៃគូ ដែលអនុញ្ញាតឱ្យសហគមន៍មូលដ្ឋានអាចផ្គត់ផ្គង់ផលិតផលកសិកម្មដល់ភោជនីយដ្ឋាន និងសណ្ឋាគារ តាមបរិមាណ គុណភាព និងតម្លៃ ដោយមានការព្រមព្រៀងគ្នាជាមុន និងគោរពតាមរដូវកាលទេសចរណ៍ ដើម្បីបង្កើនអន្តរសកម្មរវាងទេសចរណ៍ និងកសិកម្ម • ផលិតផលដែលផ្គត់ផ្គង់ គួរមានការបញ្ជាក់អត្តសញ្ញាណ គឺ “**ប្រភពដើមត្រូវបានត្រួតពិនិត្យ**” និងគោរពតាមគោលការណ៍ផលិតផលកសិកម្មល្អ (GAP)	បន្ទាយស្រី	រដ្ឋ-ឯកជន	០,៥	- ក.ទ.ច - រ.ប.ស - ស.ម - DMO		▪	▪
		៦- លើកកម្ពស់និងអភិវឌ្ឍឧស្សាហកម្មច្នៃប្រឌិតក្នុងតំបន់បន្ទាយស្រី	• អភិវឌ្ឍវិស័យទេសចរណ៍ (អ្នកបរិភោគ) ដែលជាលក្ខណៈពិសេសនៅតំបន់បន្ទាយស្រី • រៀបចំដំណើរទស្សនកិច្ចភូមិសិប្បកម្ម • បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាល និងពង្រឹងសម្បទាជំនាញវិជ្ជាជីវៈច្នៃប្រឌិតស្ថិតក្នុងភូមិសិប្បកម្មដោយភ្ជៀវទេសចរអាចរីករាយការទស្សនាផលិតផលកសិកម្ម និងទិញទុកជាវត្ថុអនុស្សាវរីយ៍ • បង្កើតស្លាកសញ្ញាបញ្ជាក់គុណភាពនៃផលិតផលសិប្បកម្មតំបន់បន្ទាយស្រី	បន្ទាយស្រី	រដ្ឋ ដៃគូ អភិវឌ្ឍ	១	- ក.ទ.ច - រ.ប.ស - អ.ធ.អ - DMO			

២.៣	យន្តការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍ក្នុងតំបន់បន្ទាយស្រី	៧- បង្កើត "**អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍**" តំបន់បន្ទាយស្រី	• បង្កើត "**អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍**" ដែលនឹងក្លាយជាអ្នកអភិវឌ្ឍ និងគ្រប់គ្រងទេសចរណ៍ក្នុងតំបន់បន្ទាយស្រី។ អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែកនេះ ស្ថិតក្រោមទម្រង់ចម្រុះ ភាពជាដៃគូ រដ្ឋ-ឯកជន ឬភាពជាដៃគូ រដ្ឋ-សហគមន៍-ឯកជន-ដៃគូអភិវឌ្ឍ។	បន្ទាយស្រី	រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍ	TBD	- គ.អ.ទ.ស	▪		
	សរុប÷ យុទ្ធសាស្ត្រ ចំនួន០៣ សកម្មភាពអនុវត្តចំនួន០៧									
៣	**តំបន់បេតិកភណ្ឌអង្គរ**			**តំបន់អង្គរ**						
៣.១	ការគ្រប់គ្រងរំហួរភ្ញៀវ	១- ពង្រឹងការស្វែងយល់ពីព័ត៌មានភ្ញៀវទេសចរ	• ប្រមូលផ្តុំទិន្នន័យអំពីភ្ញៀវជាតិ និងអន្តរជាតិ ដោយប្រើប្រាស់យន្តការអង្កេតសាធារណៈ ជាប្រចាំ ពិសេសកិច្ចសហការជាមួយរាល់ភាគីពាក់ព័ន្ធ ដើម្បីចងក្រងព័ត៌មានអំពីភ្ញៀវទេសចរតែមួយ	តំបន់អង្គរ	រដ្ឋ	TBD	- អ.ធ.អ - ក.ទ.ច - រ.ប.ស - គ្រ.អ	▪	▪	▪
		២- រៀបចំហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារសម្រួលដល់ការទស្សនាឱ្យបានល្អប្រសើរ	• រៀបចំផែនការមេ និងសៀវភៅបន្ទុកដើម្បីកំណត់ និងអនុវត្តសាងសង់ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ចាំបាច់ (ប៉ាវីស មណ្ឌលផ្តល់ព័ត៌មាន ផ្ទាំងព័ត៌មាន, ស្លាកសញ្ញាដែលពន្យល់ណែនាំភ្ញៀវដោយប្រើប្រាស់បច្ចេកវិទ្យា កន្លែងសម្រាក បង្គន់អនាម័យ បរិក្ខារសម្រួលដល់ការទស្សនារបស់ទេសចរជាកុមារ ជនពិការ និងមនុស្សចាស់ រួមទាំងផ្លូវដើរចូលទៅកាន់ប្រាសាទនានា) ***គម្រោងសាកល្បងទី១÷*** *រៀបចំកែលម្អស្លាកសញ្ញានៅក្នុងបរិវេណអង្គរធំ* ***គម្រោងសាកល្បងទី២÷*** *រៀបចំកន្លែងបដិសណ្ឋារកិច្ចភ្ញៀវនៅក្បែរបញ្ជរលក់សំបុត្រ (បុរីទេសចរណ៍វប្បធម៌)*	តំបន់អង្គរ	រដ្ឋ - ឯកជន	TBD	- អ.ធ.អ - ក.ទ.ច - រ.ប.ស - គ្រ.អ - វ.ឯ	▪	▪	▪

			• សិក្សាលទ្ធភាពកែលម្អផ្លូវតភ្ជាប់ទៅ តំបន់ទន្លេសាប ភ្នំគូលែន ក្បាលស្ពាន ប្រាសាទបឹងមាលា ប្រាសាទកោះកេរ្តិ៍ និងប្រាសាទបាគង ជាតំបន់ទេសចរណ៍សំខាន់មួយដែលស្ថិតនៅខាងក្រៅក្រុងសៀមរាប • រៀបចំបរិក្ខារបន្ថែមចាំបាច់ដោយផ្អែកទៅលើការសិក្សា និងអនុវត្តសៀគ្វីទៅតាមប្រធានបទដែលមានរយៈពេលខ្លី មធ្យម និងវែង ស្របទៅតាមប្រភេទភ្ញៀវទេសចរជាលក្ខណៈគ្រួសារ ជាក្រុមនិស្សិតម៉ាយ និងឈានដល់ការគិតគូរពីលទ្ធភាពបច្ចេកវិទ្យាក្នុងការសម្រួលដល់ទេសចរសម្រាប់ការអនុវត្ត និងទទួលបានព័ត៌មានលម្អិតពីសៀគ្វីនីមួយៗ។ ***គម្រោងសាកល្បង÷ សៀគ្វីនៅប្រាសាទបាយ័ន*** • សិក្សាលទ្ធភាពបង្កើតផលិតផល និងសេវាកម្មទេសចរណ៍ថ្មីៗដូចជាប្រភេទទេសចរណ៍សាសនា និងកីឡា ដែលអាចមានជាន្លែងសមាធិ ផ្លូវកង់ និងសេវាទ្រទ្រង់ព្រឹត្តិការណ៍ទេសចរណ៍នាពេលរាត្រី ដោយសហការជាមួយស្ថាប័នរដ្ឋឬឯកជន ទៅតាមទីតាំង និងលក្ខខណ្ឌនានាដែលកំណត់ដោយអាជ្ញាធរជាតិអប្សរា • សិក្សាលទ្ធភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យា AR/VR និងបច្ចេកវិទ្យាចាំបាច់សមស្របផ្សេងទៀត ក្នុងការបកស្រាយព័ត៌មាន និងលើកតម្លៃរមណីយដ្ឋាន • សិក្សាជាមួយភាគីពាក់ព័ន្ធពិសេសវិស័យឯកជនក្នុងការរៀបចំកញ្ចប់ទេសចរណ៍សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិ ក្នុងន័យទាក់ទាញតាមរយៈតម្លៃ ព្រមទាំងជំរុញការបញ្ចូលការទស្សនាប្រាសាទ និងរមណីយដ្ឋានដែលពុំសូវមានការទស្សនា							

		៣- សិក្សាប្រភេទសំបុត្រ និងសមត្ថភាពផ្ទុកនៅរមណីយដ្ឋានអង្គរ	• សិក្សាពីប្រភេទ និងតម្លៃសំបុត្រសម្រាប់ និងភ្ញៀវទេសចរអន្តរជាតិ ក៏ដូចជា សំបុត្រអនឡាញ ដើម្បីឱ្យសំបុត្រចូលទស្សនាអង្គរមានលក្ខណៈបត់បែនក្នុងន័យទាក់ទាញភ្ញៀវទេសចរ សម្រួលដល់ការគ្រប់គ្រងប្រមូលទិន្នន័យ ពន្យារការស្នាក់នៅ ជំរុញការទស្សនាប្រាសាទតូចៗ និងកាត់បន្ថយរដូវកាលទេសចរណ៍ • កំណត់ចំនួនភ្ញៀវឬម៉ោងទស្សនាប្រាសាទនៅពេលកកស្ទះ ដោយផ្អែកលើការសិក្សាពីសមត្ថភាពផ្ទុករបស់ប្រាសាទ	តំបន់អង្គរ	រដ្ឋ	TBD	- អ.ធ.អ - គ្រ.អ	▪	▪	▪
		៤- ផ្សព្វផ្សាយ និងលើកតម្លៃរមណីយដ្ឋាន	• សហការជាមួយក្រសួងទេសចរណ៍ និងឯកជនដើម្បីសិក្សារៀបចំព្រឹត្តិការណ៍ប្រចាំឆ្នាំ (សាសនា វប្បធម៌ កីឡា) ដោយមានសៀវភៅបន្ទុកច្បាស់លាស់ • ជំរុញការផ្សព្វផ្សាយពីសកម្មភាពទេសចរណ៍ដែលមានស្រាប់ និងកន្លែងទស្សនានៅតំបន់សៀមរាប-អង្គរ ដោយមានការចូលរួមពីអ្នកជំនាញទីផ្សារ និងផ្សព្វផ្សាយក្នុងឧស្សាហកម្មទេសចរណ៍ និងមធ្យោបាយផ្សព្វផ្សាយនានា (បច្ចេកវិទ្យា E-Marketing)	តំបន់អង្គរ	រដ្ឋ	TBD	- អ.ធ.អ - ក.ទ.ច	▪	▪	▪
		៥- ពង្រឹងសណ្តាប់ធ្នាប់សារធារណៈ:	• គ្រប់គ្រងអ្នកលក់ដូរ និងការប្រើប្រាស់ចំណតដោយគោរពតាមសៀវភៅបន្ទុកនៃការសាងសង់ គ្រប់គ្រង និងប្រើប្រាស់ • ***គម្រោងសាកល្បង÷*** *រៀបចំសណ្តាប់ធ្នាប់តូបលក់ដូរនៅបរិវេណអង្គរធំ (សៀគ្វី បរិក្ខារទេសចរណ៍ និងរំហួរចរាចរណ៍)*	តំបន់អង្គរ	រដ្ឋ	TBD	- អ.ធ.អ - រ.ប.ស	▪	▪	▪
		៦- ជំរុញឱ្យមានកម្មវិធីផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋក្នុងតំបន់	• គាំទ្រសកម្មភាពបម្រើឱ្យវិស័យទេសចរណ៍ (កសិកម្ម សិប្បកម្ម) ដោយរៀបចំឱ្យមានស្តង់ដា និងគុណភាព និងជួយស្វែងរកទីផ្សារ • បណ្តុះបណ្តាលជំនាញ (កសិកម្ម សិប្បកម្មទេសចរណ៍) និងជំរុញឱ្យមានការទស្សនាសកម្មភាពនៅក្នុងភូមិ	តំបន់អង្គរ	រដ្ឋ	TBD	- អ.ធ.អ - រ.ប.ស	▪	▪	▪

៣.២	ការការពារបរិស្ថាន	៧- អនុវត្តគោលនយោបាយការពារបរិស្ថាន	• ពង្រឹងការអនុវត្តវិធានការពារបរិស្ថានដែលមានស្រាប់ ***គម្រោងសាកល្បងទី១÷*** *បញ្ឈប់ការប្រើប្រាស់ដបប្លាស្ទិក សម្រាប់មន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរា* ***គម្រោងសាកល្បងទី២÷*** *បញ្ឈប់ការប្រើប្រាស់ថង់ប្លាស្ទិកនៅប្រាសាទបន្ទាយស្រី* • យុទ្ធនាការអប់រំផ្សព្វផ្សាយពីការការពារបរិស្ថាន • សិក្សាពីមធ្យោបាយគ្រប់គ្រងការកសំណល់ ការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក និងជំរុញ សកម្មភាពកសិកម្មសរីរាង្គ	តំបន់អង្គរ	រដ្ឋ	TBD	- អ.ធ.អ - រ.ប.ស - ប.ស្ថ - ក.ទ.ច	▪	▪	▪
		៨- ជំរុញការប្រើប្រាស់មធ្យោបាយធ្វើដំណើរដែលមិនបំពុល បរិស្ថាន /Shuttle/ មធ្យោបាយធ្វើដំណើរសាធារណៈ	• សិក្សាពីផែនការមេសម្រាប់គ្រប់គ្រងចរាចរណ៍ និងមធ្យោបាយធ្វើដំណើរ (Shuttle រថយន្តអគ្គីសនី ឬមធ្យោបាយធ្វើដំណើរផ្សេងៗ ដែលកាត់បន្ថយការបំពុលបរិស្ថាន) ***គម្រោងសាកល្បង÷*** *Shuttle ពីចំណតមុខប្រាសាទអង្គរវត្តដល់បរិវេណអង្គរធំ ឬពីចំណតភ្នំបាខែងដល់បរិវេណអង្គរធំ* • សិក្សាហាមឃាត់មធ្យោបាយធ្វើដំណើរ (រថយន្ត២៤ កៅអី ឡើង) ធ្វើចរាចរណ៍ក្នុងរមណីយដ្ឋាន	តំបន់អង្គរ	រដ្ឋ	TBD	- អ.ធ.អ - រ.ប.ស - ស.ក	▪	▪	▪
៣.៣	អភិបាលកិច្ច	៩- អភិវឌ្ឍធនធានមនុស្ស	• រៀបចំកម្មវិធីបណ្តុះបណ្តាល សម្រាប់បុគ្គលិកអាជ្ញាធរជាតិ បុគ្គលិកផ្តល់សេវាកម្មទេសចរណ៍ សហគមន៍ និងយុវជន ***គម្រោងសាកល្បង÷*** *វិក្រឹត្តិការមគ្គុទ្ទេសក៍ទេសចរណ៍ និង CBET នៅប្រាសាទបន្ទាយស្រី ដោយសហការជាមួយគម្រោង GIZ* • បណ្តុះបណ្តាលមគ្គុទ្ទេសក៍ភាសាខ្មែរ និងមគ្គុទ្ទេសក៍ពិសេសសម្រាប់តំបន់បេតិកភណ្ឌអង្គរ	តំបន់អង្គរ	រដ្ឋ	TBD	- អ.ធ.អ - ក.ទ.ច - អ.យ.ក	▪	▪	▪

		១០- ពង្រឹងភាពជាដៃគូតាមរយៈកិច្ចពិភាក្សា និងការអនុវត្តការងាររួមគ្នា	• ពង្រឹងយន្តការពិភាក្សាជាមួយផ្នែកពាក់ព័ន្ធ ទាំងរដ្ឋ និងឯកជន ដើម្បីជំរុញកិច្ចសហការឱ្យបានរលូន	តំបន់អង្គរ	រដ្ឋ	TBD	- អ.ធ.អ - ក.ទ.ច	▪	▪	▪
		១១- ធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍន៍ទេសចរណ៍សម្រាប់តំបន់បេតិកភណ្ឌអង្គរ	• ផ្នែកតាមអនុសាសន៍ណែនាំបន្ថែមរបស់អ្នកជំនាញអាដហុក ផ្នែកអភិវឌ្ឍន៍ប្រកបដោយចីរភាព និងតម្រូវការជាក់ស្តែង ធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍទេសចរណ៍សម្រាប់តំបន់បេតិកណ្ឌអង្គរ (២០២០-២០៣០) ឱ្យស្របតាមគោលដៅ (២០២១-២០៣៥)	តំបន់អង្គរ	រដ្ឋ	TBD	- អ.ធ.អ	▪		
	សរុប÷ យុទ្ធសាស្ត្រចំនួន០៣ សកម្មភាពអនុវត្តចំនួន១១									
៤	**តំបន់ក្រុងសៀមរាប÷ ទេសចរណ៍បេតិកភណ្ឌប្រវត្តិសាស្ត្រ**			**ក្រុងសៀមរាប**						
៤.១	ការបង្កើនភាពទាក់ទាញទេសចរណ៍តំបន់កណ្តាលក្រុងសៀមរាប	១-បង្កើតបណ្តាញទេសចរណ៍សៀមរាបក្រោមយុទ្ធនាការ **"សៀមរាប÷ ក្រៅពីប្រាសាទ"** ដែលតភ្ជាប់ការទស្សនាតំបន់ទេសចរណ៍សំខាន់ៗជាកញ្ចប់ដោយតម្លៃទាក់ទាញ	• ប្រាសាទអង្គរ និងប្រាសាទក្រៅតំបន់បេតិកភណ្ឌអង្គរ • ប្រាសាទអង្គរ និងបឹងទន្លេសាប • ប្រាសាទអង្គរ និងភ្នំគូលែន • ប្រាសាទអង្គរ និងទីតាំងទេសចរណ៍ក្នុងក្រុង • ប្រាសាទអង្គរ និងតំបន់គោលដៅទេសចរណ៍នៅខេត្តជុំវិញ	ក្រុងសៀមរាប	រដ្ឋ-ឯកជន	១	- ក.ទ.ច - ក.វ.វ.ស - ប.ស្ថ - គ.ជ.អ.ទ - អ.ធ.អ - គ្រ.អ - វ.ឯ - DMO	▪		

		២- រៀបចំទីក្រុងសៀមរាបដោយផ្តល់នូវសេវាកម្មទេសចរណ៍ចម្រុះប្រកបដោយគុណភាព ដូចជាមជ្ឈមណ្ឌលស្នាក់នៅ ម្ហូបអាហារប្រកបដោយគុណភាព និងមានស្តង់ដា និងមជ្ឈមណ្ឌល ម៉ាយ	• ពង្រឹងគុណភាពសេវាកម្មស្នាក់នៅ ដោយអនុវត្តប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារ និងអនុវត្តស្តង់ដាបៃតង • រៀបចំឱ្យមានសេវាកម្មម្ហូបអាហារចម្រុះដែលមានគុណភាព និងអនាម័យខ្ពស់ • ជំរុញទាក់ទាញភោជនីយដ្ឋានថ្មីៗល្បីបម្រើឱ្យទីផ្សារទេសចរណ៍អាទិភាពមាននៅក្នុងក្រុងសៀមរាប • ជំរុញអនុវត្តប្រព័ន្ធចំណាត់ថ្នាក់ភោជនីយដ្ឋានកម្ពុជានៅខេត្តសៀមរាបឱ្យមានប្រសិទ្ធភាព • ត្រូវរៀបចំឱ្យបានវិថីម្ហូបអាហារយ៉ាងតិច២កន្លែងឱ្យស្របតាមស្តង់ដាវិថីម្ហូបអាហារកម្ពុជា និងរៀបចំឱ្យមានភូមិម្ហូបអាហារមួយកន្លែង • រៀបចំផ្សារចាស់ គួរតែធ្វើឱ្យមានស្តង់ដា **"ផ្សារទេសចរណ៍ស្អាត"**	ក្រុងសៀមរាប	រដ្ឋ-ឯកជន និងដៃគូអភិវឌ្ឍ	TBD	- គ.ជ.អ.ទ - ក.ទ.ច - ប.ស្ថ - ម.ទ.ស - ក.វ.វ.ស - ឧ.វ.ប.ន - រ.ប.ស - ក.អ.ក - DMO	▪	▪	▪
		៣- ពង្រឹង និងលើកកម្ពស់ភាពទាក់ទាញទេសចរណ៍តំបន់ផ្សារចាស់	• គ្រប់គ្រងចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់ប្រព័ន្ធរថយន្តក្រុងរួម • បង្កើតជួរពណ៌បៃតង និងការបង្កើតបណ្តាញផ្លូវថ្មើរជើងតាមរយៈការកែលម្អផ្លូវក្នុងតំបន់ផ្សារចាស់ និងតំបន់ជុំវិញ • បង្កើតតំបន់ថ្មើរជើង កែលម្អតំបន់ទេសចរណ៍ថ្មើរជើង, កែលម្អផ្លូវក្នុងតំបន់ផ្សារចាស់ • ផ្លូវនីមួយៗត្រូវគិតគូរ÷ ផ្លូវសម្រាប់ការបែងចែកការធ្វើដំណើររបស់រថយន្ត, ផ្លូវទេសចរណ៍ថ្មើរជើង,ផ្លូវសម្រាប់ម៉ូតូ, ផ្លូវសម្រាប់ជិះង់, ផ្លូវសម្រាប់ជនពិការ, សួនអមសងខាងផ្លូវ,ការបំពាក់សម្បទាទេសចរណ៍ចាំបាច់	ក្រុងសៀមរាប	រដ្ឋ-ឯកជន	TBD	- គ.ជ.អ.ទ - រ.ប.ស - DMO		▪	

		៤- អភិរក្ស និងប្រើប្រាស់បេតិកភណ្ឌទីក្រុង និងធម្មជាតិ	• អភិរក្សបេតិកភណ្ឌក្រុង (ពិសេសអគារប្រវត្តិសាស្ត្រ) សំណង់ស្ថាបត្យកម្ម ដែលបន្សល់ទុកពីសម័យអាណានិគមបារាំងនៅតាមបុរកជិតផ្សារចាស់ និងដើមឈើចាស់ៗ • សិក្សាស្ទៀគ្វីទៅតាមប្រធានបទនានា សម្រាប់ទស្សនានៅក្រុងសៀមរាប មានជាអាទិ៍ សៀគ្វីទស្សនាវត្តអារាម សៀគ្វីទស្សនាសំណង់ក្នុងសម័យអាណានិគម • ស្រាវជ្រាវបន្ថែមទៅលើរចនាបថ និងតម្លៃប្រវត្តិសាស្ត្រនៃសំណង់អគារចាស់ៗ	ក្រុងសៀមរាប	រដ្ឋ	TBD	- ក.វ.វ.ស - ក.ធ.ស - ក.ទ.ច - វ.ប.ស - DMO	▪		
		៥- ធ្វើឱ្យដងស្ទឹងសៀមរាបក្លាយជាស្ទឹងទេសចរណ៍ប្រណីត	• កែលម្អស្ទឹងអាចរៀបចំឡើងជា ០៣ផ្នែកគឺ÷ ទី១. ផ្នែកខាងលើមានទីតាំងពីគូលែន ទៅសង្កាត់នគរធំ (ដែលគួរបំពាក់សម្បទាទ្រទ្រង់ដូចជា÷ ប៉មទស្សនាសត្វ និងព្រៃឈើ, ផ្លូវសុវត្ថិភាពក្នុងព្រៃ, រៀបចំទីសក្ការៈ, បំពាក់ស្លាកសញ្ញា, ផែនទីចង្អុលផ្លូវ), ទី២. ផ្នែកកណ្តាល នៅត្រង់ផ្លូវសង្កាត់នគរធំ ទៅដល់អាងក្រពើចាស់នៃក្រុងសៀមរាប (ដែលគួររៀបចំសម្បទាទ្រទ្រង់ដូចជា÷ ផ្លូវសុវត្ថិភាពក្នុងព្រៃ និងសម្រាប់ជិះកង់, រៀបចំដងស្ទឹងសមស្រប និងទំហំប្រើប្រាស់សម្រាប់សកម្មភាពទេសចរណ៍កីឡា, រៀបចំទីសក្ការៈ, បំពាក់ស្លាកសញ្ញា, ផែនទីចង្អុលផ្លូវ, រៀបចំសួនអមមាត់ស្ទឹង, ផ្លូវថ្មើរជើងចំណត, បង្គន់សាធារណៈ), ទី៣. ផ្នែកខាងក្រោម ពីចំណុចអាងក្រពើចាស់នៃក្រុងសៀមរាប ទៅដល់បឹងទន្លេសាប (ដែលគួររៀបចំសម្បទាទ្រទ្រង់ដូចជា÷ បំពាក់ស្លាកសញ្ញា, ផែនទីចង្អុលផ្លូវ,រៀបចំសួនអមមាត់ស្ទឹង, ផ្លូវថ្មើរជើង ចំណត, បង្គន់សាធារណៈ, ផ្លូវសុវត្ថិភាពក្នុងព្រៃ និងសម្រាប់ជិះកង់, ផែទូកទេសចរណ៍)។	ក្រុងសៀមរាប	រដ្ឋ-ឯកជន	១៥	- គ.ជ.អ.ទ - ស.ក - ប.ស្ថ - ក.ទ.ច - ក្រ.ធ.ឧ.ខ - វ.ប.ស - អ.ធ.អ - DMO	▪	▪	

			• កែលម្អសោភណភាព និងគ្រប់គ្រងបរិស្ថាន • កែលម្អផ្លូវអមសងខាងស្ទឹង និងច្រាំងស្ទឹង • សាងសង់ស្ពានសម្រាប់ថ្មើរជើងឆ្លងកាត់ស្ទឹង • បង្កើតសកម្មភាពកីឡា និងទេសចរណ៍ដែលមិនប៉ះពាល់តម្លៃប្រវត្តិសាស្ត្រ និងទេសភាពវប្បធម៌នៃស្ទឹងសៀមរាប							
		៦- ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង និងសមត្ថភាពរបស់ក្រុងសៀមរាប ឱ្យស័ក្តិសមជាជ័យលាភី **"កម្ពុជាជាទីក្រុងស្អាត"** និងជាជ័យលាភី **"ទីក្រុងទេសចរណ៍ស្អាតអាស៊ាន"**	• ធ្វើឱ្យក្រុងសៀមរាបក្លាយជាទីក្រុងស្អាត និងបៃតង ដោយបង្កើត និងបង្កើនតំបន់បៃតង រួមមានការកែលម្អសួននានាក្នុងក្រុងសៀមរាប • គ្រប់គ្រងការបំពុលដោយសំឡេងក្នុងក្រុង ដោយត្រូវពង្រឹងការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យក្នុងតំបន់កណ្តាលក្រុងសៀមរាប • រៀបចំតំបន់ប្រមូលផ្តុំសម្រាប់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ស្ថិតនៅភូមិជ្រាវ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ដោយប្រសិទ្ធនាមថា **"បុរីកម្សាន្តខេត្តសៀមរាប"** ហើយមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដែលមិនមានលក្ខណៈសម្បត្តិអនុលោមតាមស្មារតី នៃអនុក្រឹត្យ ស្តីពី ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ និងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដែលនឹងបង្កើតថ្មីក៏គួរតែរៀបចំនៅក្នុងតំបន់ប្រមូលផ្តុំនេះ • បំពាក់សម្បទាទេសចរណ៍ទ្រទ្រង់គ្រប់គ្រាន់ ដែលមានស្តង់ដាត្រឹមត្រូវ (មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍, បង្គន់អនាម័យសាធារណៈ ពិសេសនៅតាមរមណីយដ្ឋានទេសចរណ៍ និងគោលដៅទេសចរណ៍សំខាន់ៗ, ស្លាកសញ្ញាប្រាប់ទិសសម្រាប់ភ្ញៀវទេសចរ)	ក្រុងសៀមរាប	រដ្ឋ	TBD	- រ.ប.ស - DMO	▪		

			• គ្រប់គ្រងប្រព័ន្ធចរាចរណ៍ និងសណ្តាប់ធ្នាប់ឱ្យបានល្អ ដោយផ្លូវក្នុងក្រុង និងទេសភាពតាមដងផ្លូវត្រូវឱ្យមានការរចនាដូចគ្នា ត្រូវមានហេដ្ឋារចនា សម្ព័ន្ធល្អ បរិស្ថានល្អ និងអនាម័យល្អ ។ រីឯការពង្រឹងការគ្រប់គ្រងសណ្តាប់ធ្នាប់ក្នុងក្រុងសៀមរាប ត្រូវមានការគិតគូរលើ÷ ការគ្រប់គ្រងចរាចរណ៍ជាមួយការគ្រប់គ្រងចល័តភាពបម្រើវិស័យទេសចរណ៍ឱ្យមានគុណភាព និងមានស្តង់ដា, ការពង្រឹងចំណតរថយន្តទេសចរណ៍ក្នុងក្រុងសៀមរាប ដើម្បីបម្រើឱ្យភ្ញៀវទេសចរ និងបង្កើនភាពងាយស្រួលធានាបាននូវសុវត្ថិភាព ចំណតទាំងអស់ក្នុងក្រុងត្រូវរៀបចំសណ្តាប់ធ្នាប់							
៤.២	ការពង្រីកតំបន់ទន្ទាប់នៃក្រុងសៀមរាប	៧- បង្កើតសម្បទាទាក់ទាញទេសចណ៍ម៉ាយ	• រៀបចំទីតាំងប្រជុំតូច មធ្យម និងធំឱ្យស្របតាមបទដ្ឋានអន្តរជាតិ សម្រាប់បម្រើឱ្យតម្រូវការភ្ញៀវទេសចរគ្រប់ប្រភេទ	ក្រុងសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - អ.ធ.អ - ឧ.វ.ប.ន - វ.ប.ស - DMO	▪	▪	
		៨- ពង្រីកផលិតផលទេសចរណ៍បន្ថែម-អង្គរផ្លាស់ (Angkor plus)	• ពង្រីកឱ្យមានផលិតផលទេសចរណ៍ប្រភេទបែបកម្សាន្ត បម្រើឱ្យទីផ្សារទេសចរណ៍អន្តរជាតិ និងទីផ្សារទេសចរណ៍ក្នុងស្រុក ដើម្បីលើកទឹកចិត្តភ្ញៀវទេសចរពន្យារការស្នាក់នៅបានមួយកម្រិតទៀត	ក្រុងសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - ឧ.វ.ប.ន - DMO		▪	▪
		៩-បង្កើតមជ្ឈមណ្ឌលអប់រំ និងមន្ទីរពេទ្យកម្រិតអន្តរជាតិ	• លើកទឹកចិត្តផ្នែកដីធ្លីសម្រាប់បង្កើតសាកលវិទ្យាល័យអន្តរជាតិ និងសាលាអន្តរជាតិ មួយ ឬច្រើន សម្រាប់ជាមណ្ឌលស្រាវជ្រាវអំពីកម្ពុជា សម្រាប់បម្រើដល់ប្រភេទទស្សនកិច្ចទេសចរបែបស្រាវជ្រាវកម្រិតខ្ពស់	ក្រុងសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - DMO		▪	▪

		១០-បង្កើតឱ្យមានតំបន់ទេសចរណ៍ផ្ទះទីពីរ	• អភិវឌ្ឍលំនៅឋាន និងតំបន់ពាណិជ្ជកម្មក្នុងតំបន់សៀមរាបខាងកើត (តំបន់ទ្រនាប់)	ក្រុងសៀមរាប	រដ្ឋ-ឯកជន		- ក.ទ.ច - រ.ប.ស - DMO		▪	▪
		១១- គ្រប់គ្រង និងអភិវឌ្ឍ តំបន់ទ្រនាប់ សៀមរាបខាងកើត	• រៀបចំតំបន់ទ្រនាប់ នៅលើផ្នែដីជាទីក្រុងឆ្លាតវៃ និងបៃតងស្របតាមទស្សនាទាន **"អភិវឌ្ឍដើម្បីអភិរក្ស អភិរក្សដើម្បីអភិវឌ្ឍ"** • អភិវឌ្ឍតំបន់ទ្រនាប់ គួរដំណើរការក្រោមទម្រង់ភាពជាដៃគូ រដ្ឋ-ឯកជន។ អ្នកអភិវឌ្ឍតំបន់នេះ ត្រូវមានផែនការមេអភិវឌ្ឍន៍សៀមរាបភាគខាងកើតលម្អិតមួយដែលត្រូវពិនិត្យ និងអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា។	ក្រុងសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - ម.ទ.ស - ខ.រ.ប.ន - វ.ឯ - DMO		▪	▪
៤.៣	យន្តការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ក្រុងសៀមរាប	១២- ប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីអភិវឌ្ឍសៀមរាបជា"ទីក្រុងឆ្លាត"	• ប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងរំហួរចរាចរ ប្រព័ន្ធសន្តិសុខសុវត្ថិភាព ប្រព័ន្ធដឹកជញ្ជូន អភិបាលកិច្ច បរិស្ថាន ការរស់នៅឆ្លាតជាដើម ពោលគឺការលើកកម្ពស់គុណភាពជីវិតប្រជាជនឱ្យកាន់តែមានមជ្ឈដ្ឋានរស់នៅល្អប្រសើរ និងមានសមត្ថភាពក្នុងការគ្រប់គ្រងហានិភ័យសង្គមនានា តាមរយៈបច្ចេកវិទ្យា និងប្រព័ន្ធឆ្លាត។ ការអភិវឌ្ឍក្រុងសៀមរាប ជាទីក្រុងឆ្លាត ត្រូវផ្តោតលើយុទ្ធសាស្ត្រសំខាន់ៗ ដូចជា សេដ្ឋកិច្ចឆ្លាត, ការបម្លាស់ទីឆ្លាត, បរិស្ថានឆ្លាត, ការរស់នៅឆ្លាត, ប្រជាពលរដ្ឋឆ្លាត និងអភិបាលកិច្ចឆ្លាត។	ក្រុងសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ប.ទ - ខ.រ.ប.ន - ក.ទ.ច - រ.ប.ស - DMO			▪
		១៣-ពង្រឹងអភិបាលកិច្ចគ្រប់គ្រងទេសចរណ៍ក្រុងសៀមរាប	• បង្កើត **"អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍"** ដែលនឹងក្លាយជាអ្នកអភិវឌ្ឍ និងគ្រប់គ្រងទេសចរណ៍ក្នុងតំបន់ក្រុងសៀមរាប។ អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែកនេះ ស្ថិតក្រោមទម្រង់ចម្រុះ ភាពជាដៃគូ រដ្ឋ-ឯកជន ឬភាពជាដៃគូ រដ្ឋ-ឯកជន-សហគមន៍-ដៃគូអភិវឌ្ឍ។	ក្រុងសៀមរាប	រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍ	TBD	- គអទស	▪		

	សរុប÷ យុទ្ធសាស្ត្រ ចំនួន០៣ សកម្មភាពអនុវត្តចំនួន១៣								
៥	តំបន់បឹងទន្លេសាប÷ ទេសចរណ៍ធម្មជាតិ និងអេកូទេសចរណ៍			ទន្លេសាប					
៥.១	ការពង្រឹងគុណភាពសេវាកម្ម និងពិពិធកម្មផលិតផលទេសចរណ៍តំបន់បឹងទន្លេសាប	១- ពង្រឹងគុណភាពសេវាកម្មទេសចរណ៍ក្នុងតំបន់បឹងទន្លេសាប	• ពង្រឹងគុណភាពសេវាកម្មស្នាក់នៅទេសចរណ៍ ឱ្យស្របតាមស្តង់ដាគុណភាព អមជាមួយការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ • បង្កើតឱ្យមានប្រព័ន្ធហិរញ្ញប្បទានកម្ចីសម្បទានដល់គម្រោងផ្ទះស្នាក់សហគមន៍នៅតំបន់ទន្លេសាបក្រោមគម្រោងឈ្មោះថា **"ទន្លេសាបផ្ទះខ្ញុំ"** • ពង្រឹងសេវាកម្មម្ហូបអាហារដោយរៀបចំហាងឱ្យមានសោភណភាព និងបម្រើសេវាកម្មឱ្យបានល្អ ជាពិសេសគីគុណភាពម្ហូបអាហារត្រូវធានាបាននូវជាសុកភាព និងអនាម័យខ្ពស់ • ពង្រឹងសេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍តំបន់បឹងទន្លេសាប អមជាមួយកម្មវិធីបណ្តុះបណ្តាលជំនាញ និងត្រូវអនុវត្តតាមក្រមប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈ សំដៅធានាភាពជឿជាក់ គុណភាព និងសុវត្ថិភាពជូនភ្ញៀវទេសចរ	ទន្លេសាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - វ.ប.ស - DMO	▪	▪	
		២- កែលម្អកំពង់ផែទេសចរណ៍នៅតំបន់បឹងទន្លេសាប	• កែលម្អកំពង់ផែនៅតំបន់បឹងទន្លេសាប (កំពង់ផែសហគមន៍អេកូទេសចរណ៍ បឹងពារាំង (ជ្រាវ), កំពង់ផែសហគមន៍ទេសចរណ៍ធម្មជាតិកំពង់ភ្លុក, កំពង់ផែសហគមន៍អេកូទេសចរណ៍កំពង់ឃ្លាំង, កំពង់ផែសហគមន៍ទេសចរណ៍ធម្មជាតិមេជ្រៃ) ដោយត្រូវគិតគួរសម្បទាទ្រទ្រង់ចាំបាច់ជាអប្បបរិមា ជាអាទិ៍ ភោជនីយដ្ឋាន ឬអាហារដ្ឋាន, ហាងកាហ្វេ, អគាររដ្ឋបាល, បញ្ជរព័ត៌មានទេសចរណ៍ និងមគ្គុទ្ទេសក៍ទេសចរណ៍, សួនច្បារ, កន្លែងក្បែងលេង, ចំណតរ៉ឺម៉កកង់បី ម៉ូតូ កង់, ចំណតរថយន្តលក្ខណៈគ្រួសារ, ចំណតរថយន្តក្រុង, ការរៀបចំផ្លូវ	ទន្លេសាប	រដ្ឋ-ឯកជន	TBD	- គជអទ - ក.ទ.ច - ប.ស្ថ - ក.ស.ក - ក្រធន.ខ - អ.ធ.ទ - វ.ប.ស - DMO	▪	▪	

			ចូលទៅកាន់ចំណតទូក, ការរៀបចំកន្លែងលក់សំបុត្រ, រៀបចំឱ្យមានកន្លែងសម្រាករង់ចាំ, បំពាក់ដោយអំពូលបំភ្លឺផ្លូវឆ្លាត, បង្គន់អនាម័យសាធារណៈ និងគោរពតាមសៀវភៅបន្ទុក ព្រមទាំងឆ្លើយតបទៅតាមវិធានលើកតម្លៃបរិស្ថាន វប្បធម៌ ប្រវត្តិសាស្ត្រទៅតាមផែនីមួយៗ • កំពង់ផែទេសចរណ៍ភូមិចុងឃ្មាស ជាកំពង់ផែទេសចរណ៍ធំជាងគេ និងជាច្រកសំខាន់ចូលទៅកាន់ទន្លេសាប សម្បទាទ្រទ្រង់គួរបន្ថែមទៀត÷ មណ្ឌលព័ត៌មានទេសចរណ៍, ផ្ទះលំហែ, ផ្សារសហគមន៍, ស្ថានីយប្រេងឥន្ធនៈ, ភោជនីយដ្ឋានកម្រិតខ្ពស់ និង "ផ្ទះទន្លេសាប" ដែលអាចជាសារមន្ទីរត្រី និងធនធានក្រោមទឹក និងកន្លែងពិព័រណ៌ និងថតរូប។ល។							
		៣- ពង្រឹងគុណភាពទូកទេសចរណ៍នៅតំបន់បឹងទន្លេសាប	• អនុវត្តស្តង់ដាទូកទេសចរណ៍របស់ក្រសួងទេសចរណ៍ • គិតគួរលើផ្នែកបរិស្ថាន ដែលទូកនីមួយៗ ត្រូវបំពាក់ធុងសំរាម ដាក់ខិតប័ណ្ណផ្សព្វផ្សាយស្តីពីការហាមចោលសំរាមចូលក្នុងទឹក និងសៀវភៅណែនាំអំពីទូក ការទុកដាក់សំរាម និងការណែនាំបន្ថែមតាមការចាំបាច់ • គុបតែងលម្អទូក និងទង់ជាតិព្រះរាជាណាចក្រកម្ពុជា ព្រមជាមួយការសរសេរអក្សរខ្មែរបញ្ជាក់ពីឈ្មោះទូកសហគមន៍ និងពណ៌សមរម្យ • ផ្នែកសុវត្ថិភាព (ត្រូវបំពាក់ឧបករណ៍ពន្លត់អគ្គីភ័យ បរិក្ខារសង្គ្រោះបឋម និងអាវពោងសុវត្ថិភាពស្មើនឹងចំនួនកៅអី • ផ្នែកបដិណ្ណាកិច្ចល្អ÷ គ្រប់អ្នកបើកបរទាំងអស់ត្រូវមានឯកសណ្ឋានដែលចេញដោយសហគមន៍ ដោយមានការទទួលស្គាល់ដោយមន្ទីរ	ទន្លេសាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - រ.ប.ស - វ.ឯ - DMO	▪	▪	▪

			ទេសចរណ៍ខេត្ត និងអនុវត្តតាមក្រមសីលធម៌ និងមានយន្តការតាមដានវាយតម្លៃលើការបើកបរ, ត្រូវរៀបចំផែទូក ចំណតទូកឱ្យមានសណ្តាប់ធ្នាប់ល្អ។							
		៤- ពង្រឹងគុណភាពផ្ទះស្នាក់ និងផ្ទះបណ្តែតទឹកនៅបឹងទន្លេសាប	• រៀបចំផ្ទះស្នាក់ របស់ប្រជាជន ដែលអនុញ្ញាតឱ្យភ្ញៀវស្នាក់នៅជាមួយម្ចាស់ផ្ទះ • រៀបចំឱ្យមានផ្ទះស្នាក់នៅបែបប្រណីត ដោយធានាភាពស្អាត អនាម័យ ភាពធន់រឹងមាំ សុវត្ថិភាព និងការគ្រប់គ្រងបានល្អ • រៀបចំការស្នាក់នៅបែបដាច់ដោយឡែក ប្រភេទជាផ្ទះបណ្តែតទឹក ឬប្រភេទតង់កៅស៊ូ ដែលធន់នឹងអាកាសធាតុ ឬជាប្រភេទផ្ទះសាងសង់ថ្មីនៅតាមដើមឈើ (ផ្ទះលើដើមឈើ) • រៀបចំប្រភេទផ្ទះបណ្តែតទឹកលំហែ ឬជាប្រភេទរីស៊ីតបណ្តែតទឹក ដែលជាសំណង់ស្រាល ធន់នឹងអាកាសធាតុ (ការបោកបក់នៃកម្លាំងខ្យល់ កម្លាំងនៃទឹករលក...) • រៀបចំកែលម្អសោភណភាពផ្ទះបណ្តែតទឹក ត្រូវមានការគិតគូរពីបរិស្ថាន សម្រាប់អនាគតនៃបឹងទន្លេសាប	ទន្លេសាប	រដ្ឋ-ឯកជន	TBD	- ក. ទ. ច - ប. ស្ថ - រ. ប. ស - ក. ស. ក - DMO	▪	▪	
		៥- បង្កើតឱ្យមានកន្លែងផ្តល់ព័ត៌មានទេសចរណ៍ និងបង្កើតកម្មវិធីទូរសព្ទបង្ហាញសៀគ្វី	• បង្កើតកន្លែងផ្តល់ព័ត៌មានសម្រាប់ភ្ញៀវទេសចរ រួមបញ្ចូលជាមួយអគារនៃសារមន្ទីរបឹងទន្លេសាបដែលមានទីតាំងនៅតំបន់ចុងឃ្នាស (ភ្នំក្រោម) • បង្កើតឱ្យមានកម្មវិធីទូរស័ព្ទទេសចរណ៍ និងគេហទំព័រទេសចរណ៍សម្រាប់តំបន់ទន្លេសាប ដើម្បីផ្សព្វផ្សាយផែនទីគោលដៅទេសចរណ៍តំបន់ទន្លេសាប	ទន្លេសាប	រដ្ឋ	TBD	- ក. ទ. ច - DMO - រ. ប. ស	▪		

		ទេសចរណ៍តំបន់ទន្លេសាប	• បង្កើតសៀគ្វីទេសចរណ៍ទន្លេសាបដោយប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ AR/VR សម្រាប់ពន្យល់ពីគោលដៅទេសចរណ៍នីមួយៗ							
		៦- ធ្វើពិពិធកម្មផលិតផលទេសចរណ៍ច្នៃប្រឌិត និង ទាក់ទាញនៅតំបន់បឹងទន្លេសាប	• ជំរុញការបង្កើតសារមន្ទីរត្រី និងធនធានក្រោមទឹកនេះហៅថា "ផ្ទះទន្លេសាប" • បង្កើត**ប្រភេទទូកទេសចរណ៍ខ្នាតតូច**សៀគ្វីទេសចរណ៍ដែលអាចធ្វើដំណើរកម្សាន្តទស្សនាចរនៅក្នុងតំបន់បឹងទន្លេសាប (រយៈពេលយ៉ាងហោច២ថ្ងៃ ១យប់) • សិក្សាលទ្ធភាពរៀបចំឱ្យមានយន្តហោះឯកជនខ្នាតតូច ឬឧទ្ធម្ភាគចក្រ ដែលអាចចុះចតលើទឹកបាន សម្រាប់បម្រើដល់ការទស្សនាកម្សាន្តរបស់ភ្ញៀវលំដាប់ខ្ពស់នៅតាមគោលដៅទេសចរណ៍ធម្មជាតិនៅបឹងទន្លេសាប	ទន្លេសាប	រដ្ឋ-ឯកជន	១៥	- គ.ជ.អ.ទ - ក.ទ.ច - ប.ស្ថ - អ.ជ.ទ - DMO		▪	▪
៥.២	ការពង្រឹងគុណភាពបរិស្ថាន និងទេសភាពបឹងទន្លេសាប	៧- គ្រប់គ្រងសំណល់រឹង ក្នុងសហគមន៍បណ្តែតទឹក	• សិក្សាលទ្ធភាពបង្កើតឱ្យមានអង្គភាពប្រមូលសំរាម ឬក្រុមការងារសម្អាត ឬក្រុមបរិស្ថានស្ម័គ្រចិត្តនៅក្នុងសហគមន៍បណ្តែតទឹក • ត្រូវមានកាណូតប្រមូលសំរាមលើទឹក ប្រើសសម្រាប់សម្អាតទន្លេ បឹង អាងស្តុកទឹក ទំនប់ទឹកស្រះ និងប្រភពទឹកផ្សេងៗ រួមទាំងបង្កើតយុទ្ធនាការសហគមន៍បណ្តែតទឹកស្អាត ឬយុទ្ធនាការសហគមន៍បណ្តែតទឹកគ្មានថង់ប្លាស្ទីក និងគម្រោងធ្វើឱ្យប្រសើរឡើងនូវលំនៅឋានប្រជាពលរដ្ឋក្នុងសហគន៍បណ្តែតទឹក				- ប.ស្ថ - អ.ធ.ទ - រ.ប.ស - DMO	▪	▪	
		៨- គ្រប់គ្រងសំណល់រាវ ក្នុងសហគមន៍បណ្តែតទឹក	• សិក្សាបង្កើត "**គម្រោងផ្ទះបណ្តែតទឹកស្អាត**" ដើម្បីធ្វើឱ្យមានភាពប្រសើរឡើងនូវអនាម័យបរិស្ថាននៅក្នុងសហគមន៍បណ្តែតទឹក	ទន្លេសាប	រដ្ឋ	TBD	- ប.ស្ថ - អ.ធ.ទ - រ.ប.ស - DMO	▪		

			• បង្កើតស្ថានីយគ្រប់គ្រងកាកសំណល់ដើម្បីធ្វើប្រព្រឹត្តិកម្មកាកសំណល់ និងបង្វែរវាទៅកន្លែងដែលមានសុវត្ថិភាព និងប្រែក្លាយទៅជាផលិតផលដែលអាចលក់បានដូចជាជី ឬជីវឧស្ម័នជាដើម • សាងសង់បង្គន់អនាម័យនៅលើទឹកដើម្បីចាប់យកកាកសំណល់របស់មនុស្សមុនពេលវាអាចបំផ្លាញបរិស្ថានជុំវិញដោយធ្វើប្រព្រឹត្តិកម្មបឋមមុនបង្ហូរចូលទឹក។							
៥.៣	យន្តការគ្រប់គ្រងនិងអភិវឌ្ឍទេសចរណ៍ក្នុងតំបន់បឹងទន្លេសាប	៩- ត្រូវបង្កើត **"អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍"** តំបន់បឹងទន្លេសាប	• បង្កើត **"អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍"** ដែលនឹងក្លាយជាអ្នកអភិវឌ្ឍ និងគ្រប់គ្រងទេសចរណ៍ក្នុងតំបន់ទន្លេសាប។ អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែកនេះ ស្ថិតក្រោមទម្រង់ចម្រុះភាពជាដៃគូ រដ្ឋ-ឯកជន ឬភាពជាដៃគូ សហគមន៍-រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍ។	ទន្លេសាប	រដ្ឋ-ឯកជន និង ដៃគូអភិវឌ្ឍ	TBD	- គអទស	▪		
សរុប÷ យុទ្ធសាស្ត្រ ចំនួន០៣ សកម្មភាពអនុវត្តចំនួន០៩										
៦	**តំបន់ទេសចរណ៍សៀមរាបថ្មី**			ខេត្ត សៀមរាប						
៦.១	ការបង្កើតតំបន់ទេសចរណ៍សៀមរាបថ្មី	១- សិក្សា និងរៀបចំបង្កើតតំបន់ទេសចរណ៍សៀមរាបថ្មី	• សិក្សាលម្អិតលើទិដ្ឋភាពនគរូបនីយកម្ម, ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, យន្តការគ្រប់គ្រង និងអភិវឌ្ឍឱ្យបានច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ	ខេត្ត សៀមរាប	រដ្ឋ-ឯកជន	TBD	- គអទស		▪	▪
	សរុប÷ យុទ្ធសាស្ត្រ ចំនួន០១ សកម្មភាពអនុវត្តចំនួន០១									
	សរុប (I)÷យុទ្ធសាស្ត្រ ចំនួន១៩ សកម្មភាពអនុវត្ត ចំនួន៥៤									

II	យុទ្ធសាស្ត្រអភិវឌ្ឍន៍ផលិតផលទេសចរណ៍ថ្មីៗ									
១	ផលិតផលទេសចរណ៍វប្បធម៌បេតិកភណ្ឌសាសនា និងជំនឿ	១- បង្កើតសៀគ្វីនិងខ្សែធ្វើដំណើរទេសចរណ៍បេតិកភណ្ឌពិភពលោក	• បង្កើតសៀគ្វីទេសចរណ៍បេតិកភណ្ឌពិភពលោកអាចផ្សារភ្ជាប់រវាងតំបន់បេតិកភណ្ឌអង្គរ និងតំបន់បេតិកភណ្ឌព្រះវិហារ និងតំបន់បេតិកភណ្ឌសម្បូរព្រៃគុហ៍ • កសាងផ្លូវទេសចរណ៍បេតិកភណ្ឌឱ្យក្លាយជាផលិតផលទេសចរណ៍ដ៏ទាក់ទាញ (ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងសម្បទាទេសចរណ៍បម្រើឱ្យភ្ញៀវទេសចរ) • បង្កើតសៀគ្វីនិងខ្សែដំណើរទេសចរណ៍នៅខេត្តសៀមរាបអាចត្រូវផ្សារភ្ជាប់ដំណើរទេសចរណ៍បេតិភណ្ឌ និងម្ហូបអាហារ ,ដំណើរទេសចរណ៍នេះ ក៏អាចភ្ជាប់ជាមួយកន្លែងស្រាវជ្រាវ និងសារមន្ទីរផ្សេងៗគ្នាជាច្រើន, ត្រូវផ្សារភ្ជាប់ដំណើរទេសចរណ៍បេតិកភណ្ឌនេះជាមួយនឹងទេសចរយុវជន	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - អ.ធ.អ - វ.ឯ	▪	▪	▪
		២- បង្កើតសារមន្ទីរអរិយធម៌	• បង្កើតឱ្យមានអន្តរកម្មដោយឌីជីថលសម្រាប់ភ្ញៀវទេសចរ ជាមួយនឹង បច្ចេកវិទ្យាថ្មី សម្រាប់ភ្ញៀវទស្សនាចរ	ខេត្តសៀមរាប	រដ្ឋ	TBD	- ស.ក - វ.ប.ស - អ.ធ.អ	▪		
		៣-អភិវឌ្ឍទេសចរណ៍ច្នៃប្រឌិតផ្សារភ្ជាប់នឹងឧស្សាហកម្មច្នៃប្រឌិត	• បង្កើតកម្មវិធីលើកទឹកចិត្តទាក់ទាញភាពយន្តបរទេសឱ្យមកថតខ្សែភាពយន្តនៅខេត្តសៀមរាបដែលជាការចូលរួមដល់ការផ្សព្វផ្សាយទេសចរណ៍ដ៏មានឥទ្ធិពល និងលើកកម្ពស់ **"ទេសចរណ៍ភាពយន្ត"** នៅកម្ពុជា • បង្កើតកម្មវិធីគាំទ្រ ហិរញ្ញប្បទានលើកទឹកចិត្តការបណ្តុះបណ្តាលនិងផ្តេរបច្ចេកវិទ្យាដល់ឧស្សាហកម្មច្នៃប្រឌិត ដើម្បីគាំទ្រសិប្បករមូលដ្ឋាន	ខេត្តសៀមរាប	រដ្ឋ-ឯកជន	៥0	- ក.ទ.ច - អ.ធ.អ - DMO		▪	

			• រៀបចំឱ្យមានមជ្ឈមណ្ឌលបង្ហាត់បង្រៀនគុនល្បុក្កតោនេះដល់ភ្ញៀវទេសចរអន្តរជាតិ (កម្រិតមូលដ្ឋានខ្លី។) ក៏ដូចជាបង្កើតឱ្យមាន រោងបង្ហាញសិល្បៈគុនល្បុក្កតោ (កម្រិតស្តង់ដា) • បង្កើតវិទ្យាស្ថានសិក្សាម្ហូបអាហារ និងឧស្សាហកម្មច្នៃប្រឌិតជាផ្នែកមួយនៃសាលាជាតិវិជ្ជាជីវៈទេសចរណ៍ (សាខាខេត្តសៀមរាប)							
		៤- បង្កើត និងពង្រឹងឧបករណ៍និងមធ្យោបាយបកស្រាយពន្យល់បេតិកភណ្ឌ និងវប្បធម៌ដល់ភ្ញៀវទេសចរ	• លើកទឹកចិត្តឱ្យមានការផ្តល់សេវាកម្មសម្រាប់វិចិត្រករក្នុងស្រុកគួរតំនួរសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិផ្សារភ្ជាប់នឹងទីតាំងប្រាសាទអង្គរវត្ត និង/ឬទីតាំងប្រាសាទផ្សេងៗទៀត • បង្កើតឱ្យមានន្ធវមគ្គទ្វេសក័ទេសចរណ៍ពិសេសក្នុងតំបន់ទេសចរណ៍បេតិកភណ្ឌអង្គរដែលគួរត្រូវប្រើប្រាស់សម្រាប់ទេសចរអន្តរជាតិ និងអាចក្លាយជាមគ្គទ្វេសក័ទេសចរណ៍ក្នុងស្រុក • ប្រើប្រាស់កម្មវិធីទូរស័ព្ទបកស្រាយពន្យល់ ឬកម្មវិធីបច្ចេកវិទ្យា (AR) ឬ (VR) នៅតាមគោលដៅទេសចរណ៍វប្បធម៌ និងប្រាសាទនីមួយៗក្នុងតំបន់ទេសចរណ៍បេតិកភណ្ឌអង្គរ	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - អ.ធ.អ - វ.ឯ		▪	
២	ផលិតផលទេសចរណ៍បៃតង	៥- ជំរុញការអភិវឌ្ឍអេកូទេសចរណ៍ និងសហគមន៍ទេសចរណ៍	• អភិវឌ្ឍតំបន់សក្តានុពលអេកូទេសចរណ៍នៅក្នុងខេត្តសៀមរាបឱ្យបានច្រើន (ឧ. ព្រៃកោងកាងទឹកសាប...)	ខេត្តសៀមរាប	រដ្ឋ និងដៃគូអភិវឌ្ឍ	TBD	- ក.ទ.ច	▪	▪	
		៦- ជំរុញចលនាប្រឡងប្រណាំង “ទីក្រុងស្អាតរមណីយដ្ឋាន	• លើកទឹកចិត្តការប្រើប្រាស់មធ្យោបាយធ្វើដំណើរដែលគិតគូរដល់បរិស្ថាន • លើកទឹកចិត្តឱ្យមានការរៀបចំអគារដែលមានការគិតគូរដល់បរិស្ថាន និងប្រជាពលរដ្ឋគិតគូរដល់បរិស្ថានខ្ពស់ ក្នុងក្រុងសៀមរាប	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - គ.ជ.វ.ទ - រ.ប.ស - វ.ឯ		▪	

		ស្អាត សេវាល្អ បដិសណ្ឋារកិច្ច ល្អ" និងការរៀបចំ ក្រុងសៀមរាប ទៅជា "ទីក្រុង មេត្រីភាព បរិស្ថាន"								
		៧- ជំរុញយុទ្ធនា-ការដាំដើមឈើ "ទេសចរម្នាក់ ដើម ឈើមួយដើម" និងបង្កើតឱ្យមាន "សួនទេសចរណ៍"	• ជំរុញយុទ្ធនាការ **"ទេសចរម្នាក់ ដើមឈើមួយដើម" "គ្រួសារមួយគ្រួ ដើមឈើមួយដើម" "យុវជនម្នាក់ ដើមឈើមួយដើម" និង"ខេត្តមួយ សួនទេសចរណ៍មួយ"** • បង្កើតឱ្យមានសួនទេសចរណ៍ក្នុងតំបន់ទេសចរណ៍បេតិកភណ្ឌអង្គរ ឬក្នុងតំបន់ទេសចរណ៍ឧទ្យានជាតិភ្នំគូលែន	ខេត្ត សៀមរាប	រដ្ឋ-ឯកជន	TBD	- ក. ទ. ច - គ. ជ. វ. ទ - រ. ប. ស	▪		
		៨- អនុវត្តស្តង់ដា បៃតងក្នុង ឧស្សាហកម្ម ទេសចរណ៍ឱ្យ ស្របតាមស្តង់ដា បៃតង កម្ពុជា និងអាស៊ាន	• សម្រួលទម្រង់នៃការធ្វើធុរកិច្ច ដោយត្រូវចាប់ផ្តើមការយកចិត្ត ទុកដាក់ដល់ទស្សនាទាននៃ "ការទទួលខុសត្រូវរបស់សហគ្រាសលើ ផ្នែកសង្គម" • ស្តង់ដាបៃតងក្នុងនោះរួមមាន "ស្តង់ដារង្វាន់សម្តេចតេជោធុរកិច្ច បៃតង ក្នុងវិស័យទេសចរណ៍" និងស្តង់ដាបៃតងក្នុងឧស្សាហ៍កម្ម ទេសចរណ៍ (កម្រិតកម្ពុជា និងអាស៊ាន)	ខេត្ត សៀមរាប	រដ្ឋ-ឯកជន	TBD	- ក. ទ. ច - រ. ប. ស - វ. ឯ	▪		

៣	ផលិតផលទេសចរណ៍ម៉ាយ(MICE)	៩- រៀបចំឱ្យមានព្រឹត្តិការណ៍ម្តងម្កាល	• ព្រឹត្តិការណ៍ ឬ កិច្ចប្រជុំ សិក្ខាសាលាលក្ខណៈជាតិ តំបន់ និងអន្តរជាតិ, (ទីតាំងទទួលរៀបចំម៉ាយ) • ព្រឹត្តិការណ៍ពេលយប់នៅក្នុងតំបន់បេតិកភណ្ឌអង្គរម្តងម្កាល ពិសេសរដូវកាលដែលមានភ្ញៀវតិច	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - រ.ប.ស		▪	▪
		១០- រៀបចំឱ្យមានព្រឹត្តិការណ៍ទៀងទាត់	• ព្រឹត្តិការណ៍ម៉ារ៉ាតុង, អង្គរសង្ក្រាន្ត, មហោស្រពវប្បធម៌អន្តរជាតិ, តន្ត្រី, បុណ្យម្ហូបអាហារ, ការប្រកួតកីឡា	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - គជអក	▪	▪	▪
		១១- អភិវឌ្ឍសម្បទាហេដ្ឋា-រចនាសម្ព័ន្ធគាំទ្រផលិតផលទេសចរណ៍ម៉ាយ	• ទាក់ទាញវិនិយោគទីតាំងសាលរៀបចំកិច្ចប្រជុំកម្រិតអន្តរជាតិ និងកន្លែងតាំងពិព័រណកម្រិតអន្តរជាតិមួយនៅតំបន់ទ្រនាប់នៃក្រុងសៀមរាប និងក្នុងតំបន់ទេសចរណ៍សៀមរាបថ្មី • រៀបចំយន្តការសម្របសម្រួលបង្កលក្ខណៈងាយស្រួល និងលើកទឹកចិត្តទាក់ទាញក្រុមហ៊ុនដែលរៀបចំព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ រៀបចំកិច្ចប្រជុំសន្និសីទ និងពិព័រណ៍មកខេត្តសៀមរាប	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - DMO		▪	
៤	ផលិតផលទេសចរណ៍ជនបទ និងកសិ-ទេសចរណ៍	១២- ធ្វើសមាហរណកម្មក្នុងផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ជនបទ	• បង្កើតក្រុមការងារអន្តរក្រសួងមួយចំណុះឱ្យគណៈកម្មការជាតិអភិវឌ្ឍទេសចរណ៍ នឹងត្រូវមានការជួបប្រជុំគ្នាជាប្រចាំ ដើម្បីសម្របសម្រួលសកម្មភាពអភិវឌ្ឍន៍ផលិតផលទេសចរជនបទ និងកសិ-ទេសចរណ៍ និងចូលរួមពីអង្គការក្រៅរដ្ឋាភិបាល • បង្កើតសមាគមទេសចរណ៍ជនបទ និងកសិ-ទេសចរណ៍	ខេត្តសៀមរាប	រដ្ឋ	TBD	- ក.ទ.ច - ក.អ.ជ	▪		
		១៣- ធ្វើពិពិធកម្ម និងធ្វើទំនើបកម្មផលិតផលទេសចរណ៍	• យុទ្ធនាការលើកស្ទួយតម្លៃផលិតផលក្នុងស្រុក ផ្សារភ្ជាប់នឹងចំណេះធ្វើ និងវប្បធម៌ខ្មែរ, រៀបចំដំណើរកម្សាន្តជិះកង់ ក្នុងតំបន់បេតិកភណ្ឌអង្គរ,ជិរុញដំណើរកម្សាន្តបែបជិះរទេះគោក្នុងតំបន់បន្ទាយស្រី, រៀបចំដំណើរកម្សាន្តទេសចរណ៍បែបសម្រាកលំហែនៅ	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច	▪	▪	

		ជនបទ និង កសិ-ទេសចរណ៍	តាមកសិដ្ឋាន និងភូមិប្រជាជន, រៀបចំដំណើរទេសចរណ៍ចំណាប់អារម្មណ៍ពិសេសផ្តោតលើការថតរូប និងកសិ-ទេសចរណ៍, រៀបចំពិធីបុណ្យ និងព្រឹត្តិការណ៍ប្រមូលផលពាក់ព័ន្ធនឹងកសិកម្ម, រៀបចំព្រឹត្តិការណ៍បង្ហាញទេសចរណ៍ម្ហូបអាហារចាប់ពីកសិដ្ឋានរហូតដល់តុអាហារ, រៀបចំព្រឹត្តិការណ៍នៃថ្ងៃឈប់សម្រាកបើកបរដោយខ្លួនឯង ផ្អែកលើប្រធានបទចម្រុះ							
		១៤- ធានាគុណភាពផលិតផលទេសចរណ៍ ជនបទ និងកសិ-ទេសចរណ៍	• កម្មវិធីលើកទឹកចិត្ត សម្រាប់ការកែលម្អគុណភាព តាមរយៈការផ្តល់ការលើកទឹកចិត្តទីផ្សារ, កម្មវិធីផ្តល់ហិរញ្ញប្បទានលើកទឹកចិត្តដល់ប្រតិបត្តិករទេសចរណ៍ដែលអនុវត្តតាមស្តង់ដាគុណភាព, ការអនុវត្តស្តង់ដាគុណភាពទេសចរណ៍ជនបទ និងកសិ-ទេសចរណ៍ • បង្កើតឡាបិល ស្តីពីទេសចរណ៍ជនបទខេត្តសៀមរាប	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - រ.ប.ស	▪		
		១៥- បង្កើនការយល់ដឹងរបស់ភ្ញៀវទេសចរ	• បង្កើតផ្នែកជនបទ/ទេសចរណ៍ និងកសិ-ទេសចរណ៍នៅលើគេហទំព័រផ្លូវការរបស់ទេសចរណ៍ខេត្តសៀមរាប,ធ្វើបច្ចុប្បន្នភាពសៀវភៅមគ្គុទ្ទេសក៍ទេសចរណ៍ខេត្តសៀមរាប និងបង្កើនវត្តមានការផ្សព្វផ្សាយទេសចរណ៍លើប្រព័ន្ធផ្សព្វផ្សាយសង្គម, រៀបចំដំណើរទស្សនកិច្ចណែនាំគោលដៅទេសចរណ៍ (Familiarization Trip) សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ រួមទាំងអ្នកសរសេរ Blog ,ភ្ជាប់បណ្តាញជាមួយការីទេសចរណ៍ជំនាញខាងទេសចរណ៍ជនបទ,រៀបចំកម្មវិធីទូរស័ព្ទឆ្លាតវៃ ស្តីពីផ្លូវទេសចរណ៍បើកបរដោយខ្លួនឯង ក៏ដូចជាផ្លូវជិះកង់, ការរៀបចំកម្មវិធីលើកទឹកចិត្តក្រោយទស្សនា ដូចជាក្រុម Facebook ឬក្រុម Wechat Whatapp ដែលមានឈ្មោះថា “**មិត្តភក្តិរបស់**	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច	▪		

			សៀមរាប", អនុវត្តតាមវិធីសាស្ត្រទាក់ទាញទីផ្សារទេសចរណ៍ដែលបានកំណត់គោលដៅច្បាស់លាស់ដោយ "**បង្កើតថ្ងៃនៃទេសចរណ៍ជនបទ**"							
		១៦- លើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគមន៍មូលដ្ឋាន	• រៀបចំកម្មវិធីបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពនៅក្នុងការបង្កើតផែនការអាជីវកម្ម, កម្មវិធីអក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍ ផ្សព្វផ្សាយទីផ្សារតាមអ៊ីនធឺណិត និងទំនាក់ទំនងអតិថិជន, កម្មវិធីបណ្តុះបណ្តាលអភិវឌ្ឍន៍ផលិតផលទេសចរណ៍ និងកម្មវិធីពង្រឹងសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុ	ខេត្តសៀមរាប	រដ្ឋ-ឯកជន និងដៃគូអភិវឌ្ឍ	TBD	- ក.ទ.ច - រ.ប.ស	▪		
		១៧- បង្កើតមូលនិធិគាំទ្រទេសចរណ៍ជនបទ និងកសិ-ទេសចរណ៍	• បង្កើតគោលការណ៍ណែនាំសម្រាប់ការផ្តល់ថវិកាដល់ការអភិវឌ្ឍទេសចរណ៍ជនបទ, ជំរុញលើកទឹកចិត្តសម្រាប់កម្មវិធីការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុនជួយដល់ការអភិវឌ្ឍជនបទ, សហការជាមួយធនាគារអភិវឌ្ឍជនបទ ឬធនាគារសហគ្រាសធុនតូច និងមធ្យម ផ្តល់ហិរញ្ញប្បទានគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍ទេសចរណ៍ជនបទ	ខេត្តសៀមរាប	រដ្ឋ	TBD	- ក.ទ.ច	▪		
៥	ផលិតផលទេសចរណ៍កីឡា	១៨- បង្កើតព្រឹត្តិការណ៍ឬសកម្មភាពទេសចរណ៍កីឡាផ្សេងៗ ដ៏ទាក់ទាញជាច្រើនបន្ថែមទៀត	• បង្កើតឱ្យមានកញ្ចប់ទស្សនកិច្ចកីឡាដោយត្រូវរួមបញ្ចូលគ្នានូវសកម្មភាពកីឡាជាច្រើនផ្គួបជាមួយសកម្មភាពកម្សាន្តដ៏សម្បូរបែប (ការបរិភោគអាហារ ស្ប៉ា កន្លែងហាត់ប្រាណសុខភាព កីឡា និងការគយគន់ទេសភាព ។ល។ • គួរបង្កើតឱ្យមានព្រឹត្តិការណ៍កីឡាធំៗ • បង្កើតម៉ាកផលិតផលទេសចរណ៍កីឡានៅខេត្តសៀមរាបដោយផ្អែកលើកេរ្តិ៍ឈ្មោះខេត្ត (បង្កើតអត្តសញ្ញាណផ្ទាល់ចំពោះព្រឹត្តិការណ៍, បង្កើតម៉ាក និងបង្កើតគំនូសតាងក្រាហ្វិកនៃការរត់ប្រណាំងសម្រាប់ផលិតផលនាពេលអនាគត)	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - គ.ជ.អ.ទ - វ.ឯ	▪		

		១៩-បង្កើតផលិតផលទេសចរណ៍កីឡាផ្សេងៗទៀត	• ដំណើរកម្សាន្ត បែបឡើងភ្នំ និងដើរព្រៃ, ការជិះកង់កម្សាន្តនៅតាមដងផ្លូវនានាក្នុងក្រុងសៀមរាប តំបន់បេតិកភណ្ឌអង្គរ និងប៉ូលទាក់ទាញទេសចរណ៍នានា, ការជិះកង់លើភ្នំ, សកម្មភាពកីឡា នៅទន្លេសាប, ការបង្ហាញគុនល្បុក្កតោ • វិនិយោគលើទីលានវាយកូនហ្គោលកម្រិតអន្តរជាតិ	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - រ.ប.ស - គ.ជ.អ.ក		▪	
		២០-ជំរុញនិងអភិវឌ្ឍទេសចរណ៍ខាងក្នុង	• កសាងកីឡដ្ឋានអូឡាំពិកមួយ ក្នុងតំបន់ទេសចរណ៍សៀមរាបថ្មី	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - វ.ឯ		▪	
៦	ផលិតផលទេសចរណ៍វ័យចំណាស់ ទេសចរណ៍សុខភាព និងទេសចរណ៍ផ្នះទីពីរ	២១- បង្កើតដំណើរ ទស្សនកិច្ចសិក្សាសម្រាប់ទេសចរណ៍វ័យចំណាស់ប្រកបដោយភាពច្នៃប្រឌិត	• រៀបចំកញ្ចប់ទស្សនកិច្ចសម្រាប់ទេសចរវ័យចំណាស់គឺជា ការរួមផ្សំរវាងការរៀនសូត្រផ្សារភ្ជាប់នឹងសកម្មភាពទេសចរណ៍។ ភ្ញៀវទេសចរវ័យចំណាស់ នឹងចូលរៀនវគ្គខ្លីៗនៅសាកលវិទ្យាល័យនៅខេត្តសៀមរាប ដែលទទួលការវាយតម្លៃជាសាកលវិទ្យាល័យសម្រាប់ទេសចរវ័យចំណាស់ (U3As) ដែលអាចស្វែងយល់ពីបេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ ប្រពៃណីខ្មែរ ក្បាច់គុនល្បុក្កតោ កសិកម្ម ធម្មជាតិ ម្ហូបអាហារក្នុងតំបន់ ផ្សារភ្ជាប់ជាមួយដំណើរកម្សាន្តទៅកាន់ទីតាំងផ្ទាល់ ក្នុងអំឡុងពេលស្នាក់នៅរបស់ពួកគេ។	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - រ.ប.ស		▪	
			• បង្កើតយុទ្ធសាស្ត្រទេសចរណ៍ជនបទសម្រាប់មនុស្សវ័យចំណាស់, បង្កើតឱកាសសម្រាប់មនុស្សវ័យចំណាស់ក្នុងការទិញផលិតផលម្ហូបអាហារ, បង្កើនឱកាសសម្រាប់មនុស្សវ័យចំណាស់ក្នុងការទិញអចលនទ្រព្យ ដូចជា ផ្នះវិស្សមកាល ឬសម្រាប់ចូលនិវត្តន៍, ជំរុញបង្កើត និងផ្សព្វផ្សាយប្រភេទផលិតផលលើកកម្ពស់សុខភាពរបស់	ខេត្តសៀមរាប	រដ្ឋ	TBD	- ក.ទ.ច - រ.ប.ស		▪	

			ភ្ញៀវទេសចរវ័យចំណាស់ដូចជា ផលិតផលសម្រស់ និងផលិតផលសុខភាព							
		២២- អភិវឌ្ឍព្រឹត្តិការណ៍ទេសចរណ៍វ័យចំណាស់នៅខេត្តសៀមរាប	• រៀបចំពិព័រណ៍ទេសចរណ៍វ័យចំណាស់អន្តរជាតិនៅខេត្តសៀមរាបឱ្យបានទៀងទាត់ • បង្កើតសន្និសីទអន្តរជាតិ ស្តីពីទេសចរណ៍វ័យចំណាស់ ដោយសហការជាមួយបណ្តាញសាកលវិទ្យាល័យនៃយុគសម័យទី៣ (U3As), រៀបចំសន្និសីទអន្តរជាតិសមាគមអន្តរជាតិនៃសាកលវិទ្យាល័យយុគសម័យទី ៣ (AIUTA) នៅខេត្តសៀមរាប, រៀបចំការតាំងពិព័រណ៍ និងសិក្ខាសាលាសកលប្រចាំឆ្នាំស្តីពីទេសចរណ៍សុខភាព	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - រ.ប.ស		▪	
		២៣- បង្កលក្ខណៈងាយស្រួលសម្រួលដល់ការទាក់ទាញភ្ញៀវទេសចរវ័យចំណាស់	• សម្រួលឱ្យមានទិដ្ឋការរយៈពេលវែង និងចេញចូលច្រើនដង • បង្កើតឱ្យមានមជ្ឈមណ្ឌលសុខភាព មន្ទីរពេទ្យវេជ្ជសាស្ត្រ និងគ្លីនិកកម្រិតស្តង់ដា • សម្រួលសម្បទាទ្រទ្រង់ទេសចរណ៍នៅតាមគោលដៅទេសចរណ៍ • បង្កើតឱ្យមានសារមន្ទីរ ឬសកម្មភាពបង្ហាញអំពីវប្បធម៌ ប្រពៃណី សាសនា របៀបរបបរស់នៅ ម្ហូបអាហារដល់ភ្ញៀវទេសចរ និងមានជាការរៀបចំជាថ្នាក់បង្រៀន • បង្កើតឱ្យមានទីតាំងសមាធិនៅក្នុងតំបន់ទេសចរណ៍បេតិកភណ្ឌអង្គរ និងឧទ្យានជាតិភ្នំគូលែន • សិក្សារៀបចំឡាបិល បញ្ជាក់គុណភាពសម្រាប់សម្គាល់ប្រតិបត្តិករទេសចរណ៍ ដែលមាន **“ភាពជិតស្និទ្ធជាមួយភ្ញៀវទេសចរវ័យចំណាស់ទេសចរណ៍”**	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - រ.ប.ស		▪	

			• បង្កើតកិច្ចសហប្រតិបត្តិការអន្តរជាតិរវាងការិទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ និងសណ្ឋាគារក្នុងខេត្តសៀមរាប • បង្កើតតំបន់ទេសចរណ៍ពិសេសឱ្យមាន២ ឬពាក់ន្លែងក្នុងខេត្តសៀមរាប (មួយក្នុងក្រុងសៀមរាប តំបន់ទ្រនាប់ មួយទៀតអាចនៅក្នុងតំបន់ទេសចរណ៍សៀមរាបថ្មី)។							
	សរុប (II) ÷ យុទ្ធសាស្ត្រចំនួន ០៦ សកម្មភាពអនុវត្តចំនួន២៣									
III	យុទ្ធសាស្ត្រផ្សព្វផ្សាយ និងទាក់ទាញទេសចរណ៍ខេត្តសៀមរាប									
១	ការទាក់ទាញប្រភពទីផ្សារទេសចរណ៍សំខាន់ៗមកខេត្តសៀមរាប	១- ជំរុញការទាក់ទាញទីផ្សារទេសចរណ៍អន្តរជាតិសំខាន់ៗ	• សិក្សា និងផ្សព្វផ្សាយផ្តោតសំខាន់លើទីផ្សារមានសក្តានុពលខ្ពស់ និងកត្តារារាំងតិចតួច ក្នុងនោះរួមមាន÷ **ទីផ្សារទេសចរណ៍ចិន, អាស៊ាន, អាមេរិក, អង់គ្លេស, បារាំង, កូរ៉េ, ជប៉ុន, អាល្លឺម៉ង់, អូស្ត្រាលី និងរុស្ស៊ី** ដោយត្រូវទាក់ទាញទីផ្សារទេសចរលក្ខណៈបុគ្គល និងទេសចរជាក្រុមកម្រិតខ្ពស់មកខេត្តសៀមរាបឱ្យបានច្រើន • រៀបចំ**ផែនការយុទ្ធសាស្ត្រផ្សព្វផ្សាយ និងទាក់ទាញទេសចរណ៍** តាមទីផ្សារចំបងខាងលើ របស់ខ្លួន ដែលត្រូវធ្វើបច្ចុប្បន្នភាពស្របតាមការវិវត្តជាក់ស្តែង	កម្ពុជា/ខេត្តសៀមរាប	រដ្ឋ	TBD	- ក.ទ.ច - ក.ផ.ផ - ម.ទ.ស	▪	▪	▪
		២- ជំរុញការទាក់ទាញទីផ្សារទេសចរណ៍ក្នុងស្រុក	• បន្តជំរុញការរៀបចំព្រឹត្តិការណ៍ទេសចរណ៍ធំប្រចាំឆ្នាំក្នុងខេត្តសៀមរាបឱ្យបានច្រើន (ឧទ÷ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត, ព្រឹត្តិការណ៍កីឡា, ព្រឹត្តិការណ៍សាសនា។ល។) និងរៀបចំកញ្ចប់ទស្សនកិច្ចក្នុងស្រុករៀបចំទុកជាមុនដែលមានតម្លៃសមរម្យ	កម្ពុជា/ខេត្តសៀមរាប	រដ្ឋ	TBD	- ក.ទ.ច - ក.ផ.ផ - ម.ទ.ស	▪	▪	▪
២	ការផ្សព្វផ្សាយទេសចរណ៍ខេត្តសៀមរាប	៣- សិក្សា និងរៀបចំបង្កើតនូវយន្តការស្ថាប័ន	• បង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ (សាខាខេត្តសៀមរាប) ជាអង្គភាពគ្រប់គ្រង សម្របសម្រួល និងជំរុញការសិក្សា	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - ក.ផ.ផ - ម.ទ.ស	▪		

	តាមគ្រប់រូបភាព និងគ្រប់មធ្យោបាយ	ដើម្បីជំរុញផ្សព្វផ្សាយទេសចរណ៍ខេត្តសៀមរាប	ទីផ្សារ និងផ្សព្វផ្សាយគោលដៅទេសចរណ៍ខេត្តសៀមរាបក្រោមទម្រង់រដ្ឋ-ឯកជន-និងដៃគូអភិវឌ្ឍ • ពង្រឹងយន្តការប្រមូល និងវិភាគទិន្នន័យស្ថិតិទេសចរណ៍សម្រាប់បម្រើឱ្យការសិក្សាទីផ្សារ, ផ្សព្វផ្សាយទេសចរណ៍ និងវិនិយោគទេសចរណ៍				-វិ.ឯ			
		៤-បង្កើនការចូលរួមពិព័រណ៍ទេសចរណ៍ ឬព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗ និងការរៀបចំទស្សនកិច្ចសិក្សាស្វែងយល់នៅខេត្តសៀមរាប	• បង្កើនការចូលរួមពិព័រណ៍ទេសចរណ៍ ឬព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗ តាមទីផ្សារអាទិភាព ដើម្បីផ្សព្វផ្សាយអំពីគោលដៅទេសចរណ៍ខេត្តសៀមរាប • បង្កើនការរៀបចំទស្សនកិច្ចសិក្សាស្វែងយល់ជាលក្ខណៈ FAM Trip និង PressTrip សម្រាប់បណ្តាញសារព័ត៌មាន និងប្រតិបត្តិករទេសចរណ៍ប្រទេសគោលដៅធំៗដូចជា អឺរ៉ុប និងអាស៊ានបូកបី	ខេត្តសៀមរាប	រដ្ឋ	TBD	- ក.ទ.ច - ក្រ.កប ទ.សអ - ក.ផ.ផ - ម.ទ.ស	▪	▪	▪
		៥-សិក្សាបង្កើតមជ្ឈមណ្ឌលសន្និបាតខេត្តសៀមរាប និងជំរុញផ្សព្វផ្សាយទេសចរណ៍ម៉ាយ	• បង្កើតមជ្ឈមណ្ឌលសន្និបាតខេត្តសៀមរាបសម្រាប់ការរៀបចំព្រឹត្តិការណ៍ជាតិ និងអន្តរជាតិធំៗនៅខេត្តសៀមរាប • ជំរុញផ្សព្វផ្សាយទេសចរណ៍ម៉ាយសម្រាប់ទីផ្សារជប៉ុន អាស៊ាន និងទីផ្សារផ្សេងៗទៀត តាមរយៈការរៀបចំព្រឹត្តិការណ៍កិច្ចប្រជុំ និងសន្និសីទប្រចាំឆ្នាំនានា ទាំងកម្រិតតូច មធ្យម និងឈានដល់ការរៀបចំព្រឹត្តិការណ៍កិច្ចប្រជុំសន្និសីទកម្រិតធំៗ	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - រ.ប.ស - ម.ទ.ស -វិ.ឯ	▪		

		៦-ជំរុញការទាក់ទាញវិនិយោគផលិតផលទេសចរណ៍កម្រិតខ្ពស់នៅខេត្តសៀមរាប	• បង្កើនចំនួនរមណីយដ្ឋាន សណ្ឋាគារ និងភោជនីយដ្ឋានលំដាប់ខ្ពស់បន្ថែមទៀត ដើម្បីត្រៀមទទួលភ្ញៀវទេសចរជាតិ និងអន្តរជាតិកម្រិតខ្ពស់ និងប្រកបដោយគុណភាព	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - វ.ឯ	▪	▪	▪
		៧-ពង្រឹងប្រព័ន្ធចែកចាយព័ត៌មានទេសចរណ៍តាមតំបន់	• បង្កើតជាបណ្តាញមជ្ឈមណ្ឌលភ្ញៀវទេសចរខេត្តសៀមរាបដែលជាកន្លែងប្រមូលផ្តុំដោយព័ត៌មានផ្សព្វផ្សាយផលិតផល/គោលដៅទេសចរណ៍ និងសេវាកម្មនៅខេត្តសៀមរាប	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - រ.ប.ស - អ.ធ.អ - ម.ទ.ស - វ.ឯ	▪		
		៨-បង្កើនការរៀបចំចងក្រងបោះពុម្ពឯកសារ និងផ្សព្វ-ផ្សាយទេសចរណ៍ជាភាសាអង់គ្លេស បារាំង កូរ៉ែ ជប៉ុន និងចិន	• កែលម្អផែនទីធ្វើដំណើរទៅកាន់គោលដៅនីមួយៗក្នុងខេត្តសៀមរាប និងរៀបចំសៀវភៅម្ហូបអាហារពិសេសៗសម្រាប់ខេត្តសៀមរាបតាមតំបន់ និងសហគមន៍នីមួយៗ ជាដើម • សហការជាមួយក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងអន្តរជាតិ ដើម្បីផ្សព្វផ្សាយគោលដៅទេសចរណ៍ខេត្តសៀមរាប (ពិសេសផ្សព្វផ្សាយដល់ភ្ញៀវទេសចរដែលធ្វើដំណើរមកប្រទេសកម្ពុជា)	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - ក.ផ.ផ - ម.ទ.ស - វ.ឯ	▪		
		៩-បង្កើនឧត្តមភាពប្រកួតប្រជែងនៃគោល	• សិក្សាគោលនយោបាយតម្លៃសំបុត្រអង្គរ ការសិក្សារៀបចំបណ្តាទេសចរណ៍ និងជាកញ្ចប់ទស្សនកិច្ចរៀបចំទុកជាមុនដែលមានតម្លៃសមរម្យ	តំបន់បេតិកភណ្ឌអង្គរ	រដ្ឋ	TBD	- ក.ស. ហ.វ - គ្រ.អ	▪		

		ដៅទេសចរណ៍ខេត្តសៀមរាប					- ក.ទ.ច - ក.វ.វ.ស - ប.ស្ថ - រ.ប.ស - វ.ឯ			
		១០-បង្កើនកិច្ចសហការជាមួយដៃគូសារព័ត៌មានជាតិ និងអន្តរជាតិ	• ផ្សព្វផ្សាយពីទេសចរណ៍ខេត្តសៀមរាបទៅដល់ទីផ្សារទេសចរណ៍ធំៗ ពិសេសចិន និងកូរ៉េជាដើម	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ផ.ផ - ក.ទ.ច - ម.ទ.ស - វ.ឯ	▪		
		១១-ជំរុញផ្សព្វផ្សាយទេសចរណ៍ខេត្តសៀមរាបតាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល (Digital Marketing)	• ជំរុញការប្រើប្រាស់ថ្នាលឌីជីថលទេសចរណ៍ល្បីៗ ដោយធ្វើការផ្សព្វផ្សាយទេសចរណ៍ខេត្តសៀមរាបឱ្យកាន់តែមានភាពច្នៃប្រឌិតទៅកាន់ពិភពលោកនៅតាមគេហទំព័រល្បីៗនានាប្រកបដោយប្រសិទ្ធភាព ដោយត្រូវការចូលរួមពី “ឯកអគ្គរដ្ឋទូតសុច្ឆន្ទៈ ឬ ស្ថានតំណាងទេសចរណ៍” • សិក្សានូវវិធីសាស្ត្រនានាក្នុងការជំរុញដល់ភ្ញៀវទេសចរ (ឧទា÷ ការសាងសង់ទីតាំងថតរូប #ILoveSiemReap និងបំពាក់ប្រព័ន្ធ Wi-Fi នៅតាមគោលដៅទេសចរណ៍ ជាដើម) ចូលរួមផ្សព្វផ្សាយគោលដៅទេសចរណ៍ខេត្តសៀមរាបតាមបណ្តាញសង្គម • បន្តជំរុញដំណើរគេហទំព័រ និងកម្មវិធីទូរស័ព្ទរបស់ “Visit Cambodia” សម្រាប់ទេសចរក្នុងស្រុក ដែលក្រសួងទេសចរណ៍បានរៀបចំគេហទំព័រនេះឡើង ដើម្បីផ្តល់ព័ត៌មានអំពីដំណើរកម្សាន្ត	ខេត្តសៀមរាប	រដ្ឋ	TBD	- ក.ទ.ច - ក.ផ.ផ - ម.ទ.ស	▪		

			រមណីយដ្ឋាន កន្លែងបរិភោគ កន្លែងស្នាក់នៅ ផ្សារលក់ដូរ និងសេវាកម្មផ្សេងៗ។ល។ និងបន្តជំរុញគេហទំព័រ និងកម្មវិធីទូរស័ព្ទរបស់ “Kingdom of Wonder” និងកម្មវិធីទូរស័ព្ទផ្សេងទៀត ដើម្បីផ្សព្វផ្សាយដល់ភ្ញៀវទេសចរអន្តរជាតិ អំពីគោលដៅទេសចរណ៍ខេត្តសៀមរាបតាមប្រព័ន្ធឌីជីថល និងទំនើប • ជំរុញឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រើប្រាស់បណ្តាញសង្គម ដើម្បីផ្សព្វផ្សាយទេសចរណ៍ខេត្តសៀមរាប • ជំរុញយុទ្ធនាការផ្សព្វផ្សាយគោលដៅទេសចរណ៍ខេត្តសៀមរាបតាមអនឡាញ ដោយសហការជាដៃគូជាមួយទីភ្នាក់ងារទេសចរណ៍ និងវេទិកាអ្នកធ្វើដំណើរអនឡាញ							
		១២-សិក្សាបង្កើតម៉ាកទេសចរណ៍សម្រាប់តំបន់ទេសចរណ៍សំខាន់ៗនៅខេត្តសៀមរាប អមជាមួយការប្រើប្រាស់និងផ្សព្វផ្សាយ “កម្ពុជា÷ព្រះរាជាណាចក្រ	• គោលដៅទេសចរណ៍សក្តានុពលចំនួន ០៣ ត្រូវសិក្សាបន្ថែម ដើម្បីបង្កើតការផ្សព្វផ្សាយម៉ាកទេសចរណ៍នៅតាមតំបន់នោះ រួមមាន÷ តំបន់បន្ទាយស្រី (មានដូចជា ប្រាសាទបន្ទាយស្រី និងតំបន់ជុំវិញប្រាសាទដែលជាតំបន់កម្សាន្តបែបជនបទ និងកសិ-ទេសចរណ៍), តំបន់ភ្នំគូលែន (មានដូចជា ភ្នំធម្មជាតិដែលគ្របដណ្តប់ដោយព្រៃឈើបៃតង និងតំបន់បន្ទាប់បន្សំផ្សេងទៀត ដែលពាក់ព័ន្ធនឹងធម្មជាតិ និងសាសនា), តំបន់ទន្លេសាប (មានដូចជា បឹងទន្លេសាប សហគមន៍ទេសចរណ៍នានា តាមបឹងទន្លេសាបដែលប្រកបរបរនេសាទ គឺជាផលិតផលទេសចរណ៍បែបធម្មជាតិ និងអេកូទេសចរណ៍)	ខេត្តសៀមរាប/តំបន់បេតិកភណ្ឌអង្គរ	រដ្ឋ	TBD	- ក.ទ.ច - ក.វ.វ.ស - ក.ជ.ជ - រ.ប.ស - អ.ធ.អ - ម.ទ.ស	▪		

		អច្ឆរិយៈផ្តល់ភាពកក់ក្តៅ								
	សរុប (III) ÷ យុទ្ធសាស្ត្រចំនួន០២ សកម្មភាពអនុវត្តចំនួន១២									
IV	យុទ្ធសាស្ត្រពង្រឹងគុណភាព និងនិរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍នៅខេត្តសៀមរាប									
១	ការពង្រឹងគុណភាពទេសចរណ៍	១- ពង្រឹងគុណភាពសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍នៅខេត្តសៀមរាប	• ពង្រឹងការអនុវត្តប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារ និងសេវាស្នាក់នៅទេសចរណ៍ • ជំរុញការអនុវត្តស្តង់ដាសណ្ឋាគារបៃតង	ខេត្តសៀមរាប	រដ្ឋ	TBD	- ក.ទ.ច - រ.ប.ស - វ.ឯ		▪	
		២- ពង្រឹងគុណភាពភោជនីយដ្ឋាន	• ជំរុញការអនុវត្តយុទ្ធនាការ "ភោជនីយដ្ឋានស្អាត÷ ភោជនីយដ្ឋានគ្មានសំរាមជាក្រដាសនៅក្រោមតុ" • ជំរុញការអនុវត្តក្រមប្រតិបត្តិសម្រាប់អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋានស្អាត • ជំរុញអាជីវកម្មភោជនីយដ្ឋានទាំងអស់ចូលរួមចលនាប្រឡងប្រណាំង "ស្តង់ដាភោជនីយដ្ឋានស្អាត និងអាហារដ្ឋានទេសចរណ៍ស្អាត" ព្រមទាំងអនុវត្តប្រព័ន្ធចំណាត់ថ្នាក់ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ • អនុវត្តស្តង់ដាវិធីលក់ម្ហូបអាហារ និងប្រព័ន្ធចំណាត់ថ្នាក់សេវាកម្មតូបលក់អាហារ • ជំរុញចលនាប្រឡងប្រណាំង "**បដិសណ្ឋារកិច្ចល្អ**" ក្នុងវិស័យទេសចរណ៍	ខេត្តសៀមរាប	រដ្ឋ	TBD	- គ.ជ.វ.ទ - ក.ទ.ច - រ.ប.ស - វ.ឯ		▪	

		៣- ពង្រឹងគុណភាពមណ្ឌលកម្សាន្តមនុស្សពេញវ័យនៅខេត្តសៀមរាប	• ជំរុញឱ្យមណ្ឌលកម្សាន្តនៅខេត្តសៀមរាបទាំងអស់ចូលរួមអនុវត្តចំណាត់ថ្នាក់ស្តង់ដាមណ្ឌលកម្សាន្តមនុស្សពេញវ័យ • ជំរុញ និងលើកទឹកចិត្តដល់អ្នកវិនិយោគឱ្យខិតខំប្រឹងប្រែងអភិវឌ្ឍមណ្ឌលកម្សាន្តរបស់ខ្លួនប្រកបដោយស្តង់ដាជាតិ និងអន្តរជាតិ • មណ្ឌលកម្សាន្តមនុស្សពេញវ័យទាំងអស់នៅខេត្តសៀមរាបត្រូវគោរពតាមលក្ខខណ្ឌដែលបានកំណត់ក្នុងក្របខណ្ឌបទដ្ឋានគតិយុត្ត ស្តីពី "ចំណាត់ថ្នាក់មណ្ឌលកម្សាន្តមនុស្សពេញវ័យ" • រៀបចំបង្កើតតំបន់សម្រាប់មណ្ឌលកម្សាន្តមនុស្សពេញវ័យនៅជាយក្រុងសៀមរាប ឬទីតាំងសមស្របណាមួយ	ខេត្តសៀមរាប	រដ្ឋ	TBD	- ក. ទ. ច - ប. ស្ថ - រ. ប. ស		▪	
		៤- ពង្រឹងគុណភាពសេវាកម្មការីទេសចរ-ណ៍ និងទីភ្នាក់ងារទេសចរណ៍នៅខេត្តសៀមរាប	• ពង្រឹងគុណភាពសេវាកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ត្រូវការដាក់ចេញនូវក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌របស់ការី-ទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ណ៍ វិធានការទប់ស្កាត់សកម្មភាពលក់កញ្ចប់ទស្សនកិច្ចថ្លៃសូន្យ • ជំរុញបង្កើតឱ្យមានភាពសម្បូរបែបនូវកញ្ចប់ទស្សនកិច្ចប្រកបដោយគុណភាព • ជំរុញចូលរួមដល់ការលើកស្ទួយផលិតផលក្នុងស្រុក • ជំរុញការចូលរួមលើកតម្កើង និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា និងចូលរួមក្នុងចលនាប្រឡងប្រណាំងទេសចរណ៍ផ្សេងៗ	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក. ទ. ច - ប. ទ - រ. ប. ស - វិ. ឯ		▪	
		៥- ពង្រឹងគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍	• ពង្រឹងគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍នៅខេត្តសៀមរាប តាមរយៈការដាក់ចេញយន្តការពិន័យអន្តរការណ៍ជាប្រាក់ចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ ដែលប្រព្រឹត្តខុសក្រមប្រតិបត្តិវិជ្ជាជីវៈទេសចរណ៍ និងតាមរយៈយន្តការត្រួតពិនិត្យ និងតាមដានការអនុវត្តរបស់មគ្គុ-	ខេត្តសៀមរាប	រដ្ឋ	TBD	- ក. ទ. ច - ស. ម. ទ - រ. ប. ស		▪	

			ទេសក៍ទេសចរណ៍ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងត្រួតពិនិត្យ និងតាមដានសកម្មភាពមគ្គុទ្ទេសក៍ទេសចរណ៍ជាមួយការផ្តល់ និងកាត់ពិន្ទុចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ ទៅតាមកំហុសដែលមគ្គុទ្ទេសក៍បានប្រព្រឹត្ត							
		៦- ពង្រឹងគុណភាពហាងលក់វត្ថុអនុស្សាវរីយ៍នៅខេត្តសៀមរាប	• រៀបចំយន្តការបញ្ជាក់គុណភាព និងជំរុញម៉ាកផលិតផលខ្មែរ តាមរយៈ បង្កើតវិធីសាស្ត្រក្នុងការរក្សាកេរ្តិ៍ឈ្មោះម៉ាក និងដើម្បីឱ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍រួមទាំងការការពារពីរឹងមាំនៃកេរ្តិ៍ឈ្មោះម៉ាកនៅក្នុងទីផ្សារសំខាន់ៗ, ស្រាវជ្រាវការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម និងម៉ាកសម្ងួហភាពដើម្បីគាំទ្រដល់ការអភិវឌ្ឍស្តង់ដាដោយឧស្សាហកម្មទេសចរណ៍, ពង្រឹងសមត្ថភាពដល់វិស័យទេសចរណ៍ក្នុងការប្រើប្រាស់ប្រព័ន្ធកម្មសិទ្ធិបញ្ញា • ចាត់វិធានការចំពោះហាងលក់វត្ថុអនុស្សាវរីយ៍ដែលមានសកម្មភាពកញ្ចប់ទស្សនកិច្ចកម្សាន្ត "ថ្លៃសូន្យ" • ប្រើប្រាស់បច្ចេកវិទ្យាថ្មីៗនៅលើគ្រប់ផលិតផលវត្ថុអនុស្សាវរីយ៍ទាំងអស់ ដើម្បីតាមដានទីតាំងលក់ផលិតផល ប្រភពផលិត ព័ត៌មាននៃការផលិត និងការពារការក្លែងបន្លំផលិតផលក្លែងក្លាយ	ខេត្តសៀមរាប	រដ្ឋ	TBD	- ក្រ.ព.ណ - ក.ទ.ច - ឧ.វ.ប.ន - ក.វ.វ.ស - រ.ប.ស		▪	
		៧- ពង្រឹងខេត្តសៀមរាបជាគោលដៅទេសចរណ៍សុវត្ថិភាព	• បង្កើតឱ្យមានប្រព័ន្ធសង្គ្រោះទេសចរណ៍ សម្រាប់ទេសចរណ៍ខេត្តសៀមរាបដោយគ្របដណ្តប់លើគោលដៅទេសចរណ៍អាទិភាពទាំង ៦ • ត្រូវពង្រឹងការត្រួតពិនិត្យសុវត្ថិភាពសុខាភិបាលនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ក្នុងខេត្តសៀមរាប ពិសេសការគិតគូរលើសុវត្ថិភាពម្ហូបអាហារ និងការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ដើម្បីឆ្លើយតបនឹងជំងឺឆ្លងនានា (ជាអាទិ៍ជំងឺឆ្លងកូវីដ១៩)	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ស.ខ.ល - ក.ទ.ច - ម.ផ - រ.ប.ស - វ.ឯ - DMO	▪	▪	▪

			• ពង្រឹងប្រព័ន្ធសុខាភិបាល ឆ្លើយតបជំងឺឆ្លងនៅខេត្តសៀមរាប ជាអាទិ៍ ការត្រួតពិនិត្យសុខភាពនៅតាមច្រកទ្វារអន្តរជាតិ មណ្ឌលចត្តាឡីស័ក និងការធ្វើឱ្យប្រសើរឡើងនូវមន្ទីពេទ្យ មណ្ឌលសុខភាព • ជំរុញអនុវត្ត "**គោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**" នៅក្នុងភូមិសាស្ត្រខេត្តសៀមរាប ពិសេសនៅតាមគោលដៅទេសចរណ៍							
		៨- ពង្រឹងភាពធន់នៃវិស័យទេសចរណ៍ខេត្តសៀមរាប ឆ្លើយតបនឹងគ្រោះមហន្តរាយ វិបត្តិជំងឺឆ្លង និងវិបត្តិនានា	• រៀបចំ "**ផែនការយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យក្នុងវិស័យទេសចរណ៍**" អមជាមួយការពង្រឹងយន្តការអនុវត្ត ឆ្លើយតប នឹងគ្រោះមហន្តរាយធម្មជាតិ វិបត្តិជំងឺឆ្លង និងវិបត្តិនានា ដែលអាចកើតឡើងជាលក្ខណៈប្រធានស័ក្តិ បានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ម.ផ - រ.ប.ស - ត.ជ.ត.ម	▪		
២	ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍	៩ បង្កើនសមត្ថភាពផ្តត់ផ្គង់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍	• ពង្រឹងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ក្នុងថ្នាក់រៀន ដោយបន្តផ្តល់កិច្ចសហការ និងគាំទ្រដល់សាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍កំពុងដំណើរការនៅខេត្តសៀមរាប ព្រមជាមួយការបញ្ចូលមេរៀនទេសចរណ៍ នៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ នៅតាមបណ្តាវិទ្យាល័យ • ជំរុញការអនុវត្តកម្មវិធីបណ្តុះបណ្តាលខាងក្នុង ដោយត្រូវមានគ្រូបង្គោល និងជនបង្គោល មានការបញ្ចូលគ្នាត្រឹមត្រូវ និងទទួលស្គាល់ត្រឹមត្រូវជាផ្លូវការពីគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍	ខេត្តសៀមរាប	រដ្ឋ	១០	- ក.ទ.ច - អ.យ.ក - ស.រ.ទ	▪	▪	▪

			• ពង្រឹងការបណ្តុះបណ្តាលដែលផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែងនៅក្នុងកម្មវិធីសិក្សាទេសចរណ៍ (ទាមទារជាពិសេសលើវិស័យគ្រប់គ្រងសណ្ឋាគារ ម្ហូបអាហារ និងភេសជ្ជៈ) ដែលនិស្សិតត្រូវទទួលបានការបណ្តុះបណ្តាលជាក់ស្តែងក្នុងអំឡុងពេលសិក្សា និងមុនចុះកម្មសិក្សា • បង្កើតឱ្យមានកម្មវិធីសិក្សាតាមប្រព័ន្ធអនឡាញក្នុងវិស័យទេសចរណ៍ ក្នុងនោះមានមគ្គុទ្ទេសក៍ទេសចរណ៍ • អនុវត្តមូលនិធិបណ្តុះបណ្តាលក្នុងជំនាញវិជ្ជាជីវៈទេសចរណ៍បម្រើឱ្យការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៅខេត្តសៀមរាប • បង្កើត និងអនុវត្តកម្មវិធីឥណទានសិក្សាជំនាញទេសចរណ៍ • បង្កើតកម្មវិធីអាហារូបករណ៍ ឬកម្មវិធីដោះដូរបទពិសោធន៍ក្រៅប្រទេស ដើម្បីសិក្សាពីកម្មវិធីទេសចរណ៍ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ទីផ្សារទេសចរណ៍ ការគ្រប់គ្រងសណ្ឋាគារអន្តរជាតិ ការគ្រប់គ្រងព្រឹត្តិការណ៍ និងការគ្រប់គ្រងការកម្សាន្ត • បង្កើតកម្មវិធីអប់រំទេសចរណ៍ចល័តអំពី “ការគ្រប់គ្រងគុណភាព និងការអនុវត្តនៅតាមគោលដៅទេសចរណ៍ ពិសេសសម្រាប់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍”							
		១០- ពង្រឹងការបណ្តុះបណ្តាល និងរៀបចំប្រព័ន្ធអភិវឌ្ឍជំនាញវិជ្ជា	• រៀបចំវេទិកាអប់រំ និងបណ្តុះបណ្តាលក្នុងវិស័យទេសចរណ៍នៅខេត្តសៀមរាបប្រចាំឆ្នាំ (ដោយផ្សារភ្ជាប់ទៅនឹងពិព័រណ៍ការងារទេសចរណ៍ និងដំណើរទស្សនកិច្ចបច្ចេកទេសសិក្សា ការអនុវត្តល្អៗ និងបង្ហាញការអនុវត្តឧស្សាហកម្មទេសចរណ៍ប្រកបដោយភាពច្នៃប្រឌិតខ្ពស់ក្នុងខេត្តសៀមរាប)	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - ស.វ.ទ			

		ជីវៈទេសចរណ៍នៅខេត្តសៀមរាប	• ធ្វើបច្ចុប្បន្នភាពសមត្ថភាពគ្រូ អំពីជំនាញវិជ្ជាជីវៈទេសចរណ៍ផ្សារភ្ជាប់នឹងរបកគំហើញថ្មីៗពាក់ព័ន្ធនឹងវិស័យទេសចរណ៍វប្បធម៌។ល។ • បង្កើតបណ្តាញអ្នកជំនាញទេសចរណ៍នៅខេត្តសៀមរាបដែលមានការចូលរួមពីស្ថាប័នបណ្តុះបណ្តាលសាកលវិទ្យាល័យ សាលាបណ្តុះបណ្តាល និងវិស័យឯកជន • ធ្វើការស្ទង់មតិនិយោជិកជារៀងរាល់ឆ្នាំពីកម្មវិធីសិក្សាទេសចរណ៍ដើម្បីវាស់ស្ទង់ទស្សនៈរបស់និយោជិតក្នុងវិស័យទេសចរណ៍ ដើម្បីរៀបចំយុទ្ធសាស្ត្របណ្តុះបណ្តាលឱ្យឆ្លើយតបទីផ្សារទេសចរណ៍ • បង្កើតកម្មវិធី "កម្មសិក្សា" ក្នុងវិស័យទេសចរណ៍នៅខេត្តសៀមរាប • ដាក់ឱ្យដំណើរការប្រព័ន្ធវាយតម្លៃទទួលស្គាល់ការសិក្សាពីមុនរបស់អ្នកជំនាញទេសចរណ៍ ដោយអនុវត្តតាមកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈទេសចរណ៍ ផ្អែកលើស្តង់ដាសមត្ថភាពស្របតាមស្តង់ដាជាតិ និងអាស៊ាន • អនុវត្តកម្មវិធីបណ្តុះបណ្តាលបដិសណ្ឋារកិច្ចលួសម្រាប់បុគ្គលិកទេសចរណ៍ជួរមុខ • រៀបចំកម្មវិធីថ្នាក់ជាតិលើកទឹកចិត្តឱ្យមានការចូលរួមពីប្រតិបត្តិករទេសចរណ៍ចូលរួមអនុវត្តកម្មវិធីហ្វឹកហាត់ការងារដល់បុគ្គលិក							
		១១- ពង្រឹងការបណ្តុះបណ្តាល	• ពង្រឹងសហគ្រិនភាពក្នុងវិស័យទេសចរណ៍ តាមរយៈការបង្កើតវគ្គសិក្សាតាមអនឡាញលើភាពច្នៃប្រឌិតផលិតផលទេសចរណ៍ដល់អាជីវកម្មទេសចរណ៍អំពីជំនាញវិជ្ជាជីវៈទេសចរណ៍អនឡាញ	ខេត្តសៀមរាប	រដ្ឋ	TBD	- ក.ទ.ច - ស.វ.ទ			

		សហគ្រិនភាព គំនិតច្នៃប្រឌិត និងធុរកិច្ចថ្មីក្នុងវិស័យទេសចរណ៍	• ពង្រឹងសមត្ថភាពអាជីវករទេសចរណ៍នូវជំនាញអក្ខរកម្មឌីជីថល ស្របតាមបរិបទនៃឧស្សាហកម្ម៤.០ • បង្កើនការបណ្តុះបណ្តាលជំនាញឌីជីថល ដល់ប្រតិបត្តិករទេសចរណ៍ធុនតូចនិងមធ្យម និងក្នុងកម្រិតជំនាញវិជ្ជាជីវៈទេសចរណ៍នៅខេត្តសៀមរាប • បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលសហគ្រិនភាព និងធុរកិច្ចថ្មីនៅក្រុងសៀមរាបដែលអាចបញ្ចូលជាមួយសាលាជាតិវិជ្ជាជីវៈទេសចរណ៍ និងឧស្សាហកម្មច្នៃប្រឌិត • បង្កើតកម្មវិធីជំនួយបច្ចេកទេសដល់ការចាប់ផ្តើមអាជីវកម្មទេសចរណ៍នៅក្នុងសហគមន៍ទេសចរណ៍-អេកូទេសចរណ៍ដោយបណ្តុះឱ្យចេះសហគ្រិនភាព ដំណើរការនៃការបង្កើតអាជីវកម្ម របៀបបង្កើត និងសរសេរផែនការអាជីវកម្ម របៀបរកហិរញ្ញប្បទាន របៀបធ្វើទីផ្សារ។ល។ • បង្កើតកម្មវិធី “Tourism means business” សម្រាប់ប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាប • រៀបចំសិក្ខាសាលាស្តីពីការបង្កើតកញ្ចប់ទស្សនកិច្ចដោយផ្តោតលើទីផ្សារទេសចរណ៍ជាន់ខ្ពស់សម្រាប់ ប្រតិបត្តិករទេសចរណ៍							
		១២- ពង្រឹងគុណភាពបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍នៅតំបន់សៀមរាប និងតំបន់ជុំវិញ	• រៀបចំឱ្យមានកម្មវិធីពង្រឹងសមត្ថភាពតាមរយៈវគ្គវិក្រឹត្យការលើជំនាញវិជ្ជាជីវៈទេសចរណ៍ ដែលតម្រូវឱ្យមានការធ្វើបច្ចុប្បន្នភាពចំណេះដឹងឱ្យស្របតាមនិន្នាការទេសចរណ៍ ក្នុងនោះពង្រឹងសមត្ថភាពដល់មគ្គុទ្ទេសក៍ទេសចរណ៍ឱ្យបាន១ឆ្នាំម្តងៗ	ខេត្តសៀមរាប	រដ្ឋ	TBD	- ក. ទ. ច - អ. ធ. អ			

			• ជំរុញការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ឱ្យស្របតាមការព្យាករនៃតម្រូវការទីផ្សារ • ពង្រឹងយន្តការទ្រទ្រង់ការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍តំបន់សៀមរាប តាមរយៈ÷ បង្កើតប្រព័ន្ធបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ (ថ្មី) ដូចជាមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់សៀមរាប និងតំបន់ជុំវិញ (កម្រិតបរិញ្ញាបត្រ) រីឯមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ (កម្រិតថ្នាក់អនុបណ្ឌិត) • ត្រូវបែងចែកប្រភេទមគ្គុទ្ទេសក៍ទេសចរណ៍ទៅតាមប្រភេទនីមួយៗ • ពង្រឹងគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍តាមរយៈការរៀបចំឱ្យមានយន្តការប្រកួតប្រជែង "មគ្គុទ្ទេសក៍ទេសចរណ៍ឆ្នើម" ប្រចាំឆ្នាំ និងពង្រឹងការអនុវត្តប្រព័ន្ធត្រួតពិនិត្យមគ្គុទ្ទេសក៍ទេសចរណ៍ព្រមជាមួយនឹងការសិក្សាអំពីយន្តការឱ្យមានភាពប្រកួតប្រជែងក្នុងការផ្តល់សេវាកម្មមគ្គុទ្ទេសក៍រវាងមគ្គុទ្ទេសក៍ និងការផ្តល់ជម្រើសដល់ការបកស្រាយ និងពន្យល់ភ្ញៀវទេសចរតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប សំដៅពង្រឹងគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍នៅតំបន់សៀមរាប-អង្គរ							
		១៣- ពង្រឹងការចុះបញ្ជិកាក្នុងបេឡាជាតិសន្តិសុខសង្គមសម្រាប់បុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍	• ពង្រឹងការអនុវត្ត ការចុះបញ្ជិកា និងបង់ភាគទានរបបសន្តិសុខសង្គមនៃបេឡាជាតិសន្តិសុខសង្គម ដើម្បីធានាសុខុមាលភាពនិយោជិត, បុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍នៅខេត្តសៀមរាបចំពោះ ហានិភ័យការងារ, ការទទួលបានការថែទាំសុខភាព និងការធានាប្រាក់សោធន ដែលជាប្រយោជន៍ ជួយសម្រាលដល់	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ស.ហ.វ - ប.ស.ស - ក.ប - ក.ទ.ច - វ.ឯ	▪	▪	▪

		នៅខេត្តសៀមរាប ឱ្យបានទូលំទូលាយ	ការលំបាកនានា ដូចជា ជរាភាព, ទុព្វលភាព, មរណភាព ឬពេលជួបប្រទះយថាភាពផ្សេងៗទៀត ដូចជា ជំងឺ និងមាតុភាព ជាដើម							
៣	ការលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋាន តាមរយៈ ការអភិវឌ្ឍទេសចរណ៍	១៤- ធ្វើពិពិធកម្មកសិកម្ម បម្រើឱ្យវិស័យទេសចរណ៍	• ធ្វើពិពិធកម្មកសិកម្មលើការដាំដោះបន្លែ ផ្លែឈើ ចិញ្ចឹមសត្វ និងចិញ្ចឹមត្រី បម្រើឱ្យវិស័យទេសចរណ៍នៅខេត្តសៀមរាប • បង្កើតយន្តការ ឬប្រព័ន្ធបន្សីគ្នារវាងការផ្គត់ផ្គង់ និងតម្រូវការរវាងកសិករ ជាមួយមូលដ្ឋានអាជីវកម្មទេសចរណ៍ ដូចជា សណ្ឋាគារ និងភោជនីយដ្ឋាន ជាដើម	ខេត្តសៀមរាប	រដ្ឋ	TBD	- ក.ស.ក - ក.ទ.ច		▪	
		១៥- អភិវឌ្ឍសិប្បកម្ម និងវត្ថុអនុស្សាវរីយ៍ឱ្យទៅជា“ផលិតផលធ្វើនៅកម្ពុជា” ដែលមានគុណភាព	• ជម្រុញអភិវឌ្ឍផលិតផលធ្វើដោយដៃ មានគុណភាពខ្ពស់ ឬផលិតផលសិល្បៈនឹងត្រូវធ្វើឱ្យរស់ឡើងវិញនូវសិល្បៈ និងជំនាញប្រពៃណីខ្មែរ និងបង្កើតម៉ាកក្នុងស្រុក	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - ក.ស.ក		▪	
		១៦- បង្កើតប្រព័ន្ធគាំទ្រ	• បង្កើតប្រព័ន្ធគាំទ្រដល់ការធ្វើពិពិធកម្មកសិកម្ម និងការលើកកម្ពស់ផលិតផលក្នុងស្រុក។ ប្រព័ន្ធគាំទ្រដើរតួជាបណ្តាញនៅលើទីផ្សារខាងក្រៅសម្រាប់អ្នកផលិតក្នុងស្រុកហៅថា **“អន្តរការី”**។ • បង្កើតម៉ាកផលិតផលខ្មែរ(កេរ្តិ៍) បម្រើឱ្យវិស័យទេសចរណ៍ រួមមាន÷ ការផ្សារភ្ជាប់អន្តរសកម្មវិស័យទេសចរណ៍ និងកសិកម្ម (ការធ្វើពិពិធកម្មវិស័យកសិកម្ម និងការធ្វើឱ្យប្រសើរ), ការអភិវឌ្ឍផលិតផលក្នុងស្រុក និងម៉ាកទេសចរណ៍ក្នុងស្រុក (ការធ្វើឱ្យប្រសើរនូវវិស័យសិប្បកម្ម និងវត្ថុអនុស្សាវរីយ៍) • បង្កើតយន្តការអន្តរស្ថាប័ន ដោយបង្កើតក្រុមការងារអន្តរក្រសួងសម្រាប់ជំរុញការលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋាន÷ ការអភិវឌ្ឍ	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - គ.ជ.អ.ទ		▪	

			ជំនាញ និងបច្ចេកវិទ្យា និងបច្ចេកវិទ្យាដើម្បីលើកកម្ពស់ផលិតភាព និងគុណភាពផលិតផល, ការអភិវឌ្ឍសមត្ថភាពទីផ្សារដើម្បីទទួលបានព័ត៌មានទីផ្សារ, ការអភិវឌ្ឍសមត្ថភាពក្នុងការចរចាដើម្បីឱ្យមានការប្រាស្រ័យទាក់ទងជាមួយអ្នកទិញព្រមជាមួយនឹងអំណាចចរចាកាន់តែប្រសើរ, បង្កើតម៉ាកទេសចរណ៍ផលិតផលក្នុងស្រុកដែលមានគុណភាពនៅក្នុងទីផ្សារទេសចរណ៍, បង្កើតបណ្តាញសិប្បករ ផលិតករក្នុងស្រុក និងប្រព័ន្ធផ្គត់ផ្គង់រវាងអ្នកផ្គត់ផ្គង់ និងតម្រូវការ, ត្រូវបង្កើតយន្តការដើម្បីបង្វិតរវាងអ្នកផ្គត់ផ្គង់ក្នុងស្រុក និងទីផ្សារសក្តានុពលនាពេលអនាគត ដោយបង្កើតឱ្យមានបណ្តាញសិប្បករ ផលិតករក្នុងស្រុក និងយន្តការផ្សារផ្គងរវាងអ្នកផ្គត់ផ្គង់និងតម្រូវការ							
សរុប (IV) ÷ យុទ្ធសាស្ត្រចំនួន ០៣ សកម្មភាពអនុវត្តចំនួន១៦										
V	យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងបរិស្ថាននៅខេត្តសៀមរាប									
១	ការគ្រប់គ្រងសំរាមសំណល់រឹង	១- រៀបចំប្រព័ន្ធគ្រប់គ្រងសំរាមសំណល់រឹង នៅខេត្តសៀមរាប	• ពង្រឹងសមត្ថភាពអនុវត្តគោលការណ៍ “4R” នៅតាមខ្សែចង្វាក់នៃប្រព័ន្ធបច្ចេកទេសក្នុងការគ្រប់គ្រងសំរាម សំណល់រឹង នៅខេត្តសៀមរាប ដែលរួមមានទាំងកាត់បន្ថយបរិមាណសំណល់ ឱ្យបានជាអតិបរមាតាមដែលអាចធ្វើទៅបាន ដោយអនុវត្តវិធានការនៅដើមខ្សែ និងតម្រូវការកែច្នៃឡើងវិញនូវកាកសំណល់ដែលអាចកែច្នៃបាន នៅទីលានចាក់សំរាមនៅចុងខ្សែ • រៀបចំយន្តការស្ថាប័នអនុវត្តប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹង នៅខេត្តសៀមរាបសម្រាប់ឆ្នាំ២០២១-២០៣៥ តាមរយៈការដាក់ចេញនូវយន្តការថ្មីមួយ (ក្នុងនោះមានការសិក្សារៀបចំបង្កើត **“រដ្ឋាករស្ងួតគ្រប់គ្រងសំរាម សំណល់រឹង ខេត្តសៀមរាប”** ដែលជាអ្នក	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ប.ស្ថ - រ.ប.ស	▪	

			គ្រប់គ្រងដើមខ្សែ និង **"រដ្ឋាករគ្រប់គ្រងការទុកដាក់ចុងក្រោយ"** (ចុងខ្សែ) ដែលត្រូវសម្រេចដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា) • រៀបចំទីលានចាក់សំរាមថ្មីមួយទៀតនៅទីតាំងសមស្របនៅខេត្តសៀមរាប ក្នុងរយៈពេលមធ្យមប្រព័ន្ធគ្រប់គ្រងសំរាមសំណល់រឹងនៅខេត្តសៀមរាបត្រូវរៀបចំឡើងដោយមានភាពស៊ីចង្វាក់គ្នាតាំងពីដើមខ្សែ រហូតដល់ចុងខ្សែ							
		២-ប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការគ្រប់គ្រងសំរាមសំណល់រឹង នៅខេត្តសៀមរាប	• ប្រើប្រាស់បច្ចេកវិទ្យាតាមដាន និងការបង់ថ្លៃសេវាសំរាមដែលបានបញ្ចេញតាមរយៈឌីជីថល • ប្រើប្រាស់ប្រព័ន្ធជីភីអេស សម្រាប់តាមដានការប្រមូលសំរាមដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងកាកសំណល់ តាមរយៈការចែកចាយ និងការបង្ហោះ តាមកម្មវិធីនឹងបង្ហាញអ្នកប្រើប្រាស់នូវទីតាំងរថយន្តនៅលើប្រព័ន្ធ បានយ៉ាងងាយស្រួល • បង្កើតថ្មាលទីផ្សារសំរាមអនឡាញសម្រាប់ការទិញនិងលក់កាកសំណល់ • ប្រើប្រាស់បច្ចេកវិទ្យាតាមដាន និងត្រួតពិនិត្យការចាក់សំរាមខុសច្បាប់	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - រ.ប.ស - វ.ឯ		▪	
		៣-បង្កើតប្រព័ន្ធហិរញ្ញវត្ថុសម្រាប់កិច្ចគាំពារបរិស្ថាននៅខេត្តសៀមរាប	• បង្កើតឱ្យមាននិរន្តរភាពហិរញ្ញវត្ថុ ប្រព័ន្ធប្រមូលថ្លៃសេវារួមគ្នា ដើម្បីពង្រឹងហិរញ្ញប្បទានសម្រាប់ផ្នែកបរិស្ថានសំរាម សំណល់រឹង នៅខេត្តសៀមរាប • ពង្រឹងលទ្ធភាពប្រមូលចំណូល លើការបង់ថ្លៃរបស់ម្ចាស់សំណល់ និងចំណូលពន្ធរបស់រដ្ឋបាលខេត្ត	ខេត្តសៀមរាប	រដ្ឋ-ឯកជន-ប្រជាពលរដ្ឋ និងដៃគូអភិវឌ្ឍ	TBD	- ក.ទ.ច - ប.ស្ថ - កសហវ - រ.ប.ស		▪	
		៤ ពង្រឹងចលនាប្រឡងប្រណាំង	• បន្តជំរុញចលនាប្រឡងប្រណាំង "ទីក្រុងស្អាត" "ស្រុកស្អាត" និង "ទីប្រជុំជនស្អាត"	ខេត្តសៀមរាប	រដ្ឋ		- ក.ទ.ច - ប.ស្ថ		▪	

		"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ"	• ជំរុញយុទ្ធនាការ **"ការរស់នៅស្អាត"** និងយុទ្ធនាការ **"គ្មានថង់ប្លាស្ទិក"** នៅទីតាំងទេសចរណ៍សំខាន់ៗ ជាអាទិ៍÷ តំបន់អង្គរ, តំបន់ឧទ្យានជាតិភ្នំគូលែន និងមូលដ្ឋានអាជីវកម្មទេសចរណ៍នៅខេត្តសៀមរាបឆ្នើមនានា • ពង្រឹងការចូលរួមចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" និងលើកកម្ពស់ការប្រើប្រាស់ដែលមានការគិតគូរបរិស្ថានក្នុងឧស្សាហកម្មទេសចរណ៍នៅខេត្តសៀមរាប			TBD	- គ.ជ.វ.ទ - ក.អ.ជ - រ.ប.ស			
២	ការលើកកម្ពស់តំបន់បៃតងក្នុងខេត្តសៀមរាប	៥- រៀបចំកែលម្អនច្បារនិងអភិរក្សដើមឈើធំៗក្នុងក្រុងសៀមរាប	• បង្កើតគម្រោងអភិរក្សដើមឈើចាស់ៗនៅតាមផ្លូវនៅតំបន់កណ្តាលក្រុងសៀមរាប ដោយប្រើប្រាស់វិធីសាស្ត្រអនុវត្ត (ជាអាទិ៍÷ កំណត់អត្តសញ្ញាណ បញ្ជីសារពើភណ្ឌ ការរចនា និងការពារដោយវិធានការជាក់លាក់) និងក៏ដូចជាការការពារព្រៃឈើក្នុងតំបន់បេតិកភណ្ឌអង្គរផងដែរ។	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ទ.ច - ប.ស្ថ - រ.ប.ស		▪	
		៦-បង្កើតឱ្យមាន **"សួនទេសចរណ៍"**	• បង្កើតឱ្យមានសួនទេសចរណ៍តាមរយៈការដាក់ចេញជាយុទ្ធនាការ **"ទេសចរម្នាក់ ដើមឈើមួយដើម" "គ្រួសារមួយគ្រួ ដើមឈើមួយដើម"** និង **"យុវជនម្នាក់ ដើមឈើមួយដើម"**	ខេត្តសៀមរាប	រដ្ឋ	TBD	- ក.ទ.ច - រ.ប.ស	▪	▪	▪
៣	ការការពារប្រព័ន្ធអេកូឡូស៊ីធម្មជាតិ	៧-ពង្រឹងនិងពង្រីកភារកិច្ច កាតព្វកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលខេត្តលើការគ្រប់	• បញ្ជាបការយល់ដឹង និងផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃប្រព័ន្ធអេកូឡូស៊ីធម្មជាតិ • ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាបម្រើដល់ការអភិរក្សប្រព័ន្ធអេកូឡូស៊ីធម្មជាតិ នៅខេត្តសៀមរាប • សហការជាមួយក្រសួង-ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធ ដើម្បីអភិរក្សប្រព័ន្ធអេកូឡូស៊ីធម្មជាតិ	ខេត្តសៀមរាប	រដ្ឋ	TBD	- រ.ប.ស	▪	▪	▪

		គ្រង ការការពារ និងការថែរក្សាដែនព្រៃលិចទឹក និងព្រៃលិចទឹក								
		៨- រៀបចំឱ្យមានយន្តការអន្តរស្ថាប័នមួយ ដើម្បីសម្របសម្រួល ការពារ និងដោះស្រាយបញ្ហាប្រឈមនៃប្រព័ន្ធអេកូឡូស៊ីធម្មជាតិ	• កំណត់ឱ្យក្រុមការងារអន្តរក្រសួងគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការសម្របសម្រួល ការពារ និងដោះស្រាយបញ្ហាប្រឈមនៃប្រព័ន្ធអេកូឡូស៊ីធម្មជាតិនៅខេត្តសៀមរាប ពិសេសនៅតំបន់បឹងទន្លេសាប។ ក្រុមការងារអន្តរក្រសួងនេះ ត្រូវរៀបចំយន្តការតាមដាន និងត្រួតពិនិត្យ អមជាមួយសូចនាករគន្លឹះ និងរបាយការណ៍វឌ្ឍនភាពប្រចាំឆមាស និងប្រចាំឆ្នាំ	ខេត្តសៀមរាប	រដ្ឋ	TBD	- ក.គ.អ	▪	▪	▪
សរុប (V) ÷ យុទ្ធសាស្ត្រចំនួន០៣ សកម្មភាពអនុវត្តចំនួន០៨										
VI	យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងការតភ្ជាប់គាំទ្រវិស័យទេសចរណ៍									
១	ជំរុញការតភ្ជាប់ផ្ទៃក្នុង និងអន្តរជាតិ									
១.១	ការជំរុញការតភ្ជាប់ពីអន្តរជាតិមកខេត្តសៀមរាប	១- ពង្រឹងសមត្ថភាពក្រុមហ៊ុនអាកាសចរណ៍ជាតិរបស់កម្ពុជា	• បង្កើនលទ្ធភាពហោះទៅកាន់ទីផ្សារទេសចរណ៍អាទិភាព ទាំងទីផ្សារទេសចណ៍ក្នុងតំបន់ និងទីផ្សារទេសចណ៍ផ្លូវឆ្ងាយ	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- រេអស - វ.ឯ		▪	
		២- ពង្រឹង និងបង្កើនការធ្វើដំណើររយៈពេល	• ពិចារណាកែសម្រួលថ្លៃចុះចត និង/ឬ ការពន្យាររយៈពេលចូលចត មិនគិតថ្លៃឱ្យយូរជាងមុន ដើម្បីលើកទឹកចិត្តលើកទឹកចិត្ត និងទាក់	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ស.ក - រេអស - វ.ឯ		▪	

		ខ្លី សម្រាប់ភ្ញៀវទេសចរអន្តរជាតិហោះត្រង់មកខេត្តសៀមរាបឱ្យកាន់តែច្រើន	ទាញក្រុមហ៊ុនអាកាសចរណ៍នានា ឱ្យធ្វើការហោះហើរមកកាន់អាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាបបានកាន់តែច្រើន							
		៣- រៀបចំឱ្យមានការធ្វើដំណើរហោះហើរត្រង់ចម្ងាយឆ្ងាយសម្រាប់ទេសចរអន្តរជាតិ	• ពង្រឹងសមត្ថភាពព្រលានយន្តហោះខេត្តសៀមរាប ដោយត្រូវពិនិត្យយ៉ាងហ្មត់ចត់លើចត់លើលក្ខខណ្ឌបច្ចេកទេសនៃការចុះចតផ្សារភ្ជាប់ជាមួយនឹងសមត្ថភាពនៃអាកាសយានដ្ឋានបច្ចុប្បន្ន និងលក្ខខណ្ឌបច្ចេកទេសនៃសំឡេងរំញ័រដល់ប្រាសាទ ដែលកំណត់ដោយអាជ្ញាធរជាតិអប្សរា ដើម្បីបង្កើនលទ្ធភាព នៃការហោះហើរ ការចុះចតនៃប្រភេទយន្តហោះធុនធំ (ខ្នាតកូដ E ឬ F) នាពេលអនាគត	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ឈេអស វ.ឯ	▪		
			• ក្នុងរយៈពេលមធ្យម និងវែង ដាក់ឱ្យដំណើរការនូវព្រលានយន្តហោះថ្មីនៅខេត្តសៀមរាប ដែលអាចទទួលភ្ញៀវទេសចរតាមការព្យាករបស់ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប នាឆ្នាំ២០៣៥	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ឈេអស - វ.ឯ		▪	▪
		៤- សម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរណ៍ឱ្យមានភាពបត់បែន និងងាយស្រួល	• បង្កើនការសម្រួលការធ្វើដំណើរតាមច្រកទ្វារអន្តរជាតិឱ្យកាន់តែប្រសើរថែមទៀត • សម្រួលឱ្យមានការធ្វើដំណើរសម្រាប់ភ្ញៀវទេសចរមកពីប្រទេសជិតខាងពិសេសតាមផ្លូវគោក តាមរយៈការអនុញ្ញាតឱ្យប្រើប្រាស់រថយន្តចេញ-ចូលខេត្តសៀមរាបឱ្យបានកាន់តែងាយស្រួល សម្រួលដល់ទិដ្ឋាការធ្វើដំណើរដោយអាចប្រើប្រាស់បណ្ណឆ្លងកាត់ព្រំដែន ចូលមកកម្សាន្តក្នុងខេត្តសៀមរាបបាន។	ខេត្តសៀមរាប	រដ្ឋ	TBD	- ក្រ.កប ទ.សអ - ម.ផ - ក.ទ.ច - ស.ក - ឈេអស	▪	▪	▪

១.២	ការជំរុញការតភ្ជាប់ផ្ទៃក្នុង មកកាន់ខេត្តសៀមរាប	៥- ពង្រឹងការតភ្ជាប់ការហោះហើរបម្រើឱ្យចលនាទេសចរណ៍ក្នុងស្រុក	• បង្កើនសមត្ថភាពនៃការហោះហើរក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក • ពង្រីការតភ្ជាប់ផ្ទៃក្នុងនាពេលអនាគត (ខេត្តសៀមរាបត្រូវការតភ្ជាប់ការហោះហើរទៅកាន់ខេត្តមណ្ឌលគីរី និងខេត្តបាត់ដំបង)	ខេត្តសៀមរាប	រដ្ឋ-ឯកជន		- ឈេអស - វិ.ឯ		▪	
		៦- ពង្រឹងការតភ្ជាប់ផ្លូវគោក (ផ្លូវថ្នល់) និងបង្កើតឱ្យមានផ្លូវទេសចរណ៍តភ្ជាប់គោលដៅទេសចរណ៍នានាក្នុងខេត្តសៀមរាប	• បង្កើតឱ្យមានផ្លូវទេសចរណ៍តភ្ជាប់មកខេត្តសៀមរាបឱ្យបានច្រើន (សៀមរាប ប្រាសាទព្រះវិហារ ឆ្ពោះទៅភូមិភាគឦសាន្ត និងឡាវ, សៀមរាប ប្រាសាទសំបូរព្រៃគុហ៍ ឆ្ពោះទៅភ្នំពេញ,សៀមរាប បាត់ដំបង ប៉ោយប៉ែត ឆ្ពោះទៅបាងកក ,សៀមរាប ទៅប៉ូលទេសចរណ៍អាទិភាពផ្សេងៗក្នុងខេត្តសៀមរាប) ដើម្បីបម្រើឱ្យចលនាទេសចរណ៍ផ្ទៃក្នុង និងទេសចរធ្វើដំណើរដោយខ្លួនឯង (Self-driving Tours)។	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ស.ក - វិ.ឯ		▪	
		៧- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងបង្កើតឱ្យមានបទពិសោធន៍ល្អនៅតាមដងផ្លូវទេសចរណ៍	• បង្កើតឱ្យមានផលិតផលសម្បុរបែប និងការទាក់ទាញនៅតាមបណ្តោយផ្លូវទេសចរណ៍ • បង្កើតឱ្យមានផលិតផលទេសចរណ៍សម្បុរបែប និងភាពទាក់ទាញនៅតាមបណ្តោយផ្លូវទេសចរណ៍ • រៀបចំឱ្យមានស្ថានីយចំណត តាមបណ្តោយផ្លូវទេសចរណ៍ • បន្តពង្រឹងសុវត្ថិភាពចរាចរណ៍ • បំពាក់សញ្ញាចរាចរណ៍ និងស្លាកសញ្ញាផ្តល់ព័ត៌មានលើផ្លូវតភ្ជាប់គោលដៅទេសចរណ៍ទាំងអស់ រចនាឡើងដោយប្រើបច្ចេកវិទ្យាថ្មីៗក្នុងបរិបទឧស្សាហកម្ម ៤.០, ពង្រឹងផែនការគ្រប់គ្រងចរាចរណ៍នៅ	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ស.ក - វិ.ឯ		▪	

			តាមគោលដៅទេសចរណ៍ដោយត្រូវពង្រឹងការអនុវត្ត និងផ្សព្វផ្សាយច្បាប់ចរាចរណ៍ដល់ភ្ញៀវទេសចរឱ្យបានត្រឹមត្រូវ និងទូលំទូលាយ • សម្រួលនីតិវិធីក្នុងការចេញ-ចូល រថយន្តទេសចរណ៍ ពិសេសរថយន្តគ្រួសារមកកាន់ខេត្តសៀមរាប តាមរយៈការបង្កើតឱ្យមានមជ្ឈមណ្ឌលសម្របសម្រួលទេសចរនៅតាមច្រកទ្វារអន្តរជាតិដែលមានការតភ្ជាប់មកកាន់ខេត្តសៀមរាប • សម្រួលឱ្យមានបណ្ណចេញ-ចូល តាមរយៈការប្រើប្រាស់បណ្ណឆ្លងកាត់ព្រំដែន សម្រាប់ភ្ញៀវទេសចរ (ថៃ ឡាវ) ដែលរស់នៅតាមបណ្តាខេត្តជាប់ព្រំដែនរបស់កម្ពុជា ចូលមកកម្សាន្តនៅខេត្តសៀមរាប							
		៨- សិក្សាលទ្ធភាពការតភ្ជាប់ផ្លូវដែកនាពេលអនាគត	• សិក្សារៀបចំឱ្យមានផ្លូវដែកល្បឿនលឿន ពី ខេត្តសៀមរាប-ភ្នំពេញ ឬខេត្តសៀមរាប-ខេត្តព្រះសីហនុ • សិក្សាពីលទ្ធភាពបង្កើតរថភ្លើងអគ្គិសនី តភ្ជាប់ទៅតំបន់ទេសចរណ៍អាទិភាពទាំង ៦ នៅខេត្តសៀមរាបផងដែរ ក្នុងរយៈពេលវែង	ខេត្តសៀមរាប	រដ្ឋ-ឯកជន	២០០០	- ស.ក - កសហវ - វ.ឯ			▪
២	ការធ្វើឱ្យប្រសើរឡើងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទេសចរណ៍ឱ្យបានជាអតិបរមា									
២.១	ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតបម្រើឱ្យវិស័យទេសចរណ៍ខេត្តសៀមរាប	៩- ថែរក្សាប្រភពធនធានទឹកដើម្បីបម្រើការផ្គត់ផ្គង់ទឹកស្អាត	• ធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ទឹកក្នុងក្រុងសៀមរាបចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងនូវបរិមាណទឹកបារាយណ៍ដែលមានស្រាប់ និងនាពេលអនាគតសម្រាប់ទឹកនៅបឹងទន្លេសាបដើម្បីឆ្លើយតបនឹងតម្រូវការទឹកនាពេលអនាគត • បង្កើនប្រសិទ្ធភាពក្នុងការរក្សាធនធានទឹក ចាំបាច់ត្រូវរៀបចំផែនការអភិវឌ្ឍអាងទន្លេ/ស្ទឹងទាំងមូល ក៏ដូចជាតំបន់ស្រុកទឹកក្រោមដី	ខេត្តសៀមរាប	រដ្ឋ	TBD	- រ.ស.ស - រ.ប.ស	▪		

		១០- កែលម្អភាពស្អាតនៃទន្លេ និងបរិស្ថានទឹក	• បង្កើតកម្មវិធីស្តារ និងថែរក្សាស្ទឹងសៀមរាបឱ្យមានចីរភាពដើម្បីបម្រើឱ្យជាប្រយោជន៍ទេសចរណ៍ និងជាប្រភពទ្រទ្រង់ការផ្គត់ផ្គង់ទឹកស្អាតផងដែរ	ខេត្តសៀមរាប	រដ្ឋ	TBD	- រ. ស. ស - ក្រ. ប - រ. ប. ស		▪	
		១១- ធ្វើឱ្យកាន់តែប្រសើរឡើងនូវសេវាកម្មផ្គត់ផ្គង់ទឹក ដើម្បីពង្រីកវិសាលភាពក្នុងការគ្រប់គ្រងទឹកស្អាតទៅកាន់អ្នកប្រើប្រាស់	• រៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រង និងប្រើប្រាស់ទឹកនៅខេត្តសៀមរាប ២០២១-២០៣៥ ដោយត្រូវមានការតាមដានស្ថានភាពទឹក និងធានាឱ្យបាននូវនិរន្តរភាពនៃធនធានទឹក ប្រព័ន្ធគ្រប់គ្រង ក៏ដូចជាការប្រើប្រាស់ទឹកទាំងនៅលើដី និងទឹកនៅក្រោមដី ដើម្បីត្រៀមឆ្លើយតបនឹងកំណើននៃការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋ ភ្ញៀវទេសចរ និងការប្រើប្រាស់ផ្សេងៗទៀត ក៏ដូចជាដើម្បីថែទាំប្រាសាទក្នុងតំបន់បេតិកភណ្ឌអង្គរ ផងដែរ	ខេត្តសៀមរាប	រដ្ឋ	TBD	- រ. ស. ស		▪	
២. ២	ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីបម្រើឱ្យវិស័យទេសចរណ៍ខេត្តសៀមរាប	១២- ជំរុញការផ្គត់ផ្គង់អគ្គិសនីឱ្យស្របតាមតម្រូវការឧស្សាហកម្មទេសចរណ៍ខេត្តសៀមរាប	• ធ្វើការលើកទឹកចិត្តឱ្យអគ្គិសនីកម្ពុជា រៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រង និងប្រើប្រាស់ថាមពលអគ្គិសនីនៅខេត្តសៀមរាបឆ្នាំ ២០២១-២០៣៥ មួយច្បាស់លាស់ ស្របតាមចក្ខុវិស័យដោយសម្រេចឱ្យបានការផ្គត់ផ្គង់អគ្គិសនី ១០០% នៅទូទាំងខេត្តសៀមរាបនៅឆ្នាំ២០៣៥ • ធ្វើការលើកទឹកចិត្តឱ្យមានការគិតគូរលើការប្រើប្រាស់ថាមពលបៃតង និងការប្រើប្រាស់ថាមពលកកើតឡើងវិញ ដូចជា ថាមពលប្រើពន្លឺព្រះអាទិត្យ ប៉ុន្តែអាចធានានូវ ស្ថិរភាព គុណភាព និងនិរន្តរភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនី	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- អ. ក		▪	
២. ៣	ការកែលម្អហេដ្ឋារចនា	១៣- គម្រោងកែលម្អហេដ្ឋារចនា	• កែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវក្នុងក្រុងសៀមរាបជាអាទិភាពមានចំនួន ៣៨ខ្សែ នៃគណៈកម្មការអន្តរក្រសួងដើម្បីសិក្សា និងអនុវត្តគម្រោង	ខេត្តសៀមរាប	រដ្ឋ	150	- គ. ស. ផ. ស - រ. ប. ស		▪	

	សម្ព័ន្ធផ្លូវភ្ជាប់គោលដៅទេសចរណ៍ឱ្យស័ក្តិសមជា "ផ្លូវទេសចរណ៍"	សម្ព័ន្ធផ្លូវក្នុងក្រុងសៀមរាប	ស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន ៣៨ខ្សែ នៅក្រុងសៀមរាប ក្នុងនោះដែរផ្លូវនីមួយៗត្រូវគិតគូរ÷ ផ្លូវសម្រាប់ការបែងចែកការធ្វើដំណើររបស់រថយន្ត, ផ្លូវទេសចរណ៍ថ្មើរជើង, ផ្លូវសម្រាប់ម៉ូតូ, ផ្លូវសម្រាប់ជិះកង់, ផ្លូវសម្រាប់ជនពិការ, សួនអមសងខាងផ្លូវ, ការបំពាក់សម្បទាទេសចរណ៍ចាំបាច់							
		១៤- ពង្រីក និងកែលម្អផ្លូវតភ្ជាប់ទៅកាន់តំបន់ទេសចរណ៍អាទិភាព	• ស្ថាបនាកំណាត់ផ្លូវអង្គរឃ្យងយូ (ផ្លូវ ៦០ ម) ភ្ជាប់ទៅផ្លូវN. ៦៦ និងបន្តទៅផ្លូវស្រុកនៃឃុំកន្ត្រាំង (ប្រវែងប្រមាណ ៦,៦ គ.ម) ដើម្បីភ្ជាប់តំបន់ទេសចរណ៍សៀមរាបថ្មី និងព្រលានយន្តហោះអន្តរជាតិសៀមរាបអង្គរ មកក្រុងសៀមរាប, • ស្ទើពង្រីក និងកែលម្អផ្លូវដែលមានស្រាប់ ដូចជា ផ្លូវ N.៦៦, ផ្លូវ N.៦៤, ផ្លូវម៉ាឡៃ, ផ្លូវយុទ្ធសាស្ត្រ សម្តេចតេជោ (ផ្លូវសាលានគរបាល) • ពង្រីកនិងកែលម្អទទឹងផ្លូវស្រុកដែលមានស្រាប់ទៅតំបន់ទេសចរណ៍ប្រាសាទបន្ទាយស្រី ចម្ងាយ៤គ.ម ចាប់ពីចំណុចប្រសព្វរង្វង់មូលភ្នំគូលែន • ពង្រីក និងកែលម្អទទឹងផ្លូវស្រុកដែលមានស្រាប់ទៅតំបន់ទេសចរណ៍សៀមរាបថ្មី ចម្ងាយ ២៥គ.ម ចាប់ពីចំណុចប្រសព្វផ្លូវ N.6 ត្រង់ផ្សារអង្គ្រងនៃភូមិអង្គ្រង រហូតទៅដល់ជើងភ្នំគូលែន • ង្រីក និងកែលម្អទទឹងផ្លូវស្រុកដែលមានស្រាប់ទៅតំបន់ទេសចរណ៍បឹងទន្លេសាប • ពង្រីក និងកែលម្អទទឹងផ្លូវស្រុកដែលមានស្រាប់ទៅតំបន់ទេសចរណ៍ភ្នំគូលែន	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ស.ក - រ.ប.ស		▪	▪

២.៤	ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសេវាទូរគមនាគមន៍ និងសេវាអ៊ីនធឺណិតបម្រើឱ្យវិស័យទេសចរណ៍	១៥- ពង្រីកការផ្តល់សេវាកម្មអ៊ីនធឺណិតល្បឿនលឿននៅតាមតំបន់អាទិភាព	• ជំរុញបំពាក់អង់តែនទូរស័ព្ទ និងអ៊ីនធឺណិត នៅតាមតំបន់ទេសចរណ៍អាទិភាពទាំងអស់ ដោយផ្សារភ្ជាប់ការប្រើប្រាស់បច្ចេកវិទ្យាល្បឿនលឿន ជាអាទិ៍បច្ចុប្បន្នមាន បច្ចេកវិទ្យា 4G និង 5G	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ក.ប.ទ -ខ.វ.ប.ន -វ.ឯ			▪
		១៦- ត្រូវបំពាក់ឱ្យមាន Wi-Fi នៅទីតាំងសាធារណៈនានា	• រយៈពេលមធ្យម និងវែង ត្រូវមាន Wi-Fi នៅតាមគោលដៅទេសចរណ៍នានា ដូចជា តំបន់បេតិកភណ្ឌអង្គរ និងតាមរមណីយដ្ឋានទេសចរណ៍សំខាន់ៗ រហូតដល់សហគមន៍	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	-ក.ប.ទ -រ.ប.ស -វ.ឯ		▪	▪
		១៧- ចាប់យកនិន្នាការីកចម្រើននៃទម្រង់សេដ្ឋកិច្ចចែករំលែក	• ជម្រុញឱ្យក្រុមហ៊ុនបង្កើតកម្មវិធីឆ្លាត ភ្ជាប់ទំនាក់ទំនងរវាងអ្នកមានតម្រូវការជួល និងអ្នកមានរបស់ជួលដោយធានានូវសុវត្ថិភាព និងមធ្យោបាយទូទាត់អនឡាញ	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- ខ.វ.ប.ន - ក.ប.ទ - ក.ទ.ច - រ.ប.ស - វ.ឯ		▪	▪
		១៨- ចាប់យកប្រភេទបច្ចេកវិទ្យាឌីជីថលសម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍នៅតាមតំបន់ទេសចរណ៍អាទិភាព	• ប្រើប្រាស់ទំនើបកម្មដ៏រហ័សនៃបច្ចេកវិទ្យានៅតំបន់អង្គរ ដើម្បីសម្រួលការកកស្ទះ និងរំហួរភ្ញៀវទេសចរជាតិ និងអន្តរជាតិ ព្រមជាមួយការផ្តល់សេវាកម្មទេសចរណ៍ប្លែកៗ និងច្នៃប្រឌិត • គ្រប់គ្រងគោលដៅទេសចរណ៍ និងវិភាគទិន្នន័យទេសចរណ៍នៅខេត្តសៀមរាប សំដៅបង្កើនការផ្សព្វផ្សាយ វិនិយោគទេសចរណ៍ និងតម្រូវការនៃទីផ្សារទេសចរណ៍គោលដៅ • ផ្សព្វផ្សាយទេសចរណ៍ខេត្តសៀមរាបតាមរយៈបច្ចេកវិទ្យាឌីជីថល • ពង្រីកហេដ្ឋារចនាសម្ព័ន្ធឌីជីថលគាំទ្រ	ខេត្តសៀមរាប	រដ្ឋ-ឯកជន	TBD	- គជអទ - ក.ទ.ច - អ.ធ.អ - រ.ប.ស - វ.ឯ		▪	

			• បង្កើតកម្មវិធីលើទូរស័ព្ទនិងការបំពាក់បច្ចេកវិទ្យាឌីជីថលបម្រើឱ្យការផ្គត់ផ្គង់ និងប្រើប្រាស់សេវាកម្មទេសចរណ៍នៅខេត្តសៀមរាប							
សរុប (VI) ÷ យុទ្ធសាស្ត្រ ចំនួន ០៦ សកម្មភាពអនុវត្តចំនួន ១៨										
VII	ផែនការសកម្មភាព និងអភិបាលកិច្ចសម្រាប់ទ្រទ្រង់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តសៀមរាប									
១	យន្តការស្ថាប័ន	២-បង្កើត **"គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ"**	• ការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍ខេត្តសៀមរាប ២០២១-២០៣៥ ត្រូវដឹកនាំ និងសម្របសម្រួលដោយ **"គណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ"** ដែលជាអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ អមជាមួយការបង្កើតឱ្យមានអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក (Sub-DMOs) នៅតាមតំបន់ទេសចរណ៍អាទិភាពចំនួន ៦ • រៀបចំកញ្ចប់ថវិកា, ធនធានមនុស្ស, កន្លែងធ្វើការសម្រាប់លេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ	ខេត្តសៀមរាប	រដ្ឋ	TBD	- គ.ជ.អ.ទ - ក.ទ.ច - រ.ប.ស - គអឧស	▪		
២	យន្តការហិរញ្ញប្បទានសម្រាប់ទ្រទ្រង់ដល់ការអភិវឌ្ឍទេសចរណ៍ខេត្តសៀមរាប	៣- គិតគូរដល់យន្តការហិរញ្ញប្បទានគាំទ្រសម្រាប់ការអនុវត្តតាមផែនការសកម្មភាពនីមួយៗ	• កំណត់ប្រភពថវិកា និងហិរញ្ញប្បទានសក្តានុពល សម្រាប់ទ្រទ្រង់ដល់ការអនុវត្តតាមផែនការសកម្មភាពនីមួយៗនៃផែនការមេនេះ ដែលអាចកៀរគរបានមកពីប្រភពថវិការដ្ឋ, វិស័យឯកជន និងដៃគូអភិវឌ្ឍនានា។	ខេត្តសៀមរាប	រដ្ឋ	TBD	- ក.ទ.ច - គអឧស - វ.ឯ	▪	▪	▪
៣	រៀបចំឱ្យមានកម្មវិធីកសាងសមត្ថភាព	៤- បង្កើតកម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាព	• បណ្តុះបណ្តាលអ្នករៀបចំផែនការ និងគោលនយោបាយ ពិសេសរៀបចំបណ្តុះបណ្តាលមន្ត្រីជំនាញរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តសៀមរាប ក្នុងដំណើរការអភិវឌ្ឍខេត្តសៀមរាប ។	ខេត្តសៀមរាប	រដ្ឋ		- ក.ទ.ច - គអឧស	▪	▪	▪

		និងបង្កើនការយល់ដឹងអំពីគោលការណ៍សំខាន់ៗនៃការអភិវឌ្ឍទេសចរណ៍ខេត្តសៀមរាប ទាំងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់តំបន់	• បណ្តុះបណ្តាលអ្នកគ្រប់គ្រងគោលដៅទេសចរណ៍ ផ្នែកឯកជន និងភ្ញៀវទេសចរឱ្យយល់ដឹងអំពីកិច្ចអភិរក្ស និងអភិវឌ្ឍន៍ទេសចរណ៍នៅខេត្តសៀមរាបស្របតាមគោលការណ៍ និរន្តរភាព និងបរិយាបន្ន។ • បណ្តុះបណ្តាលអ្នកជំនាញទេសចរណ៍ពាក់ព័ន្ធដូចមានចែងក្នុងផែនការសកម្មភាពនៃការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍នៅខេត្តសៀមរាប។ • ការបង្កើតវេទិកាថ្នាក់ជាតិស្តីពីទេសចរណ៍ខេត្តសៀមរាបដែលធ្វើជារៀងរាល់ឆ្នាំដើម្បីពង្រឹងការផ្លាស់ប្តូរ និងការផ្សព្វផ្សាយបទពិសោធន៍ ចំណេះដឹង ចំណេះធ្វើ ជំនាញឯកទេសថ្មីៗ និងផលិតផលក្នុងវិស័យទេសចរណ៍។							
៤	យន្តការតាមដាន និងត្រួតពិនិត្យ	៥- តាមដាន និងត្រួតពិនិត្យការអនុវត្តដោយក្រុមការងារអន្តរក្រសួង ធ្វើឡើងនៅពាក់កណ្តាលអាណត្តិ (២០២៨)	• ពិនិត្យឡើងវិញពីការវិវត្តនៃការអនុវត្តផែនការសកម្មភាពនៃផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ២០២១-២០៣៥ • ពិនិត្យឡើងវិញនូវផែនការអភិវឌ្ឍន៍ក្នុងតំបន់ទេសចរណ៍អាទិភាពនីមួយៗដែលប្រតិបត្តិដោយអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ ដោយឡែកនីមួយៗធ្វើបច្ចុប្បន្នភាពនៃផែនការអភិវឌ្ឍដោយរាប់បញ្ចូលទាំងគម្រោងអាទិភាពនានាក្នុងករណីចាំបាច់។	ខេត្តសៀមរាប	រដ្ឋ	TBD	- ក.ទ.ច - រ.ប.ស - គអឧស		▪	
សរុប (VII) ÷ យុទ្ធសាស្ត្រ ចំនួន ០៤ សកម្មភាពអនុវត្តចំនួន០៤										

សរុបរួម÷ គោលដៅយុទ្ធសាស្ត្រចំនួន ៧, យុទ្ធសាស្ត្រចំនួន ៤៣, សកម្មភាពអនុវត្តចំនួន ១៣៥

II. តារាងគម្រោងសកម្មភាពអាទិភាព

១. គម្រោងស្តីពី ការកាត់បន្ថយភាពធ្ងន់ធ្ងាយសេដ្ឋកិច្ចពីការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប..... 62
២. គម្រោងស្តីពី ការគ្រប់គ្រងរំហួរភ្ញៀវទេសចរជាតិ និងអន្តរជាតិក្នុងតំបន់បេតិកភណ្ឌអង្គរ..... 64
៣. គម្រោងស្តីពី ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រការអភិវឌ្ឍទេសចរណ៍ឌីជីថលនៅខេត្តសៀមរាប..... 66
៤. គម្រោងស្តីពី ការអភិវឌ្ឍខ្សែទស្សនាទេសចរណ៍មហិទ្ធិបពិតនៅឧទ្យានជាតិភ្នំគូលែន..... 68
៥. គម្រោងស្តីពី ការបង្កើតផ្លូវទស្សនាទេសចរណ៍បេតិកភណ្ឌខ្មែរ..... 70
៦. គម្រោងស្តីពី ការកែលម្អស្នឹងសៀមរាបជាស្នឹងទេសចរណ៍បៃតង..... 72
៧. គម្រោងស្តីពី ការកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងសៀមរាបគាំទ្រវិស័យទេសចរណ៍..... 74
៨. គម្រោងស្តីពី ការបង្កើតតំបន់ទ្រនាប់ (សៀមរាបខាងកើត)..... 77
៩. គម្រោងស្តីពី ការអភិវឌ្ឍកំពង់ផែទេសចរណ៍ និងសម្បទាទេសចរណ៍នៅភ្នំក្រោម (ចុងឃ្នាស)..... 79
១០. គម្រោងស្តីពី ការបង្កើតតំបន់ប្រមូលផ្តុំមណ្ឌលកម្សាន្តមនុស្សពេញវ័យខេត្តសៀមរាប "បុរីកម្សាន្តខេត្តសៀមរាប"..... 81
១១. គម្រោងស្តីពី ការបង្កើតតំបន់ទេសចរណ៍សៀមរាបថ្មី..... 83
១២. គម្រោងស្តីពី ការបង្កើតព្រលានយន្តហោះថ្មីនៅខេត្តសៀមរាប (ព្រលានយន្តហោះអន្តរជាតិសៀមរាប-អង្គរ..... 85
១៣. គម្រោងស្តីពី ការអភិវឌ្ឍទេសចរណ៍ដែលធ្វើដំណើរដោយខ្លួនឯង..... 87
១៤. គម្រោងស្តីពី ការកែលម្អ និងពង្រឹងការអភិវឌ្ឍផលិតផលទេសចរណ៍នៅតំបន់បឹងទន្លេសាប..... 89
១៥. គម្រោងស្តីពី ការបង្កើតបណ្ណាទេសចរណ៍សៀមរាប..... 91
១៦. គម្រោងស្តីពី ការពង្រឹងសមត្ថភាពផ្សព្វផ្សាយទេសចរណ៍នៅខេត្តសៀមរាប..... 93
១៧. គម្រោងស្តីពី ការបង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍សាខាខេត្តសៀមរាប..... 95
១៨. គម្រោងស្តីពី ការកែលម្អបរិស្ថានស្អាត និងទីក្រុងស្អាតខេត្តសៀមរាប..... 97
១៩. គម្រោងស្តីពី ការបង្កើតសារមន្ទីរអរិយធម៌ខ្មែរ..... 99
២០. គម្រោងស្តីពី ការពង្រឹងគុណភាពសេវាកម្មទេសចរណ៍នៅខេត្តសៀមរាប..... 101

សកម្មភាពអាទិភាពទី១÷ គម្រោងស្តីពី "ការកាត់បន្ថយភាពធ្លុះធ្លាយសេដ្ឋកិច្ចពីការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ ការលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋាន

ល.រ	ចំណងជើងគម្រោង		ក្រុមទទួលបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.១	ការកាត់បន្ថយភាពធ្លុះធ្លាយសេដ្ឋកិច្ចពីការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប		ប្រតិបត្តិករទេសចរណ៍ និងប្រជាពលរដ្ឋមូលដ្ឋាន	រដ្ឋ និងដៃគូអភិវឌ្ឍ	អាទិភាព ១ និង ២
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**វិធីសាស្ត្រនៃការអនុវត្ត÷**		
ខេត្តសៀមរាប		• ក្រសួងទេសចរណ៍ • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ • ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ • រដ្ឋបាលខេត្តសៀមរាប • ប្រជាកសិករ • ដៃគូអភិវឌ្ឍ • ប្រតិបត្តិករទេសចរណ៍ (សណ្ឋាគារ ភោជនីយដ្ឋាន មគ្គុទ្ទេសក៍ ...) • DMO's	• បង្កើតអន្តរការីសម្របសម្រួលនិងផ្សារភ្ជាប់រវាងប្រតិបត្តិករទេសចរណ៍ និងអ្នកផលិតក្នុងស្រុក • បង្កើតបណ្តាញសិប្បករ កសិករដែលមានស្នាដៃឆ្នើមទទួលបានស្លាកសញ្ញាទេសចរណ៍បៃតង និងថ្នៃប្រឌិតក្នុងនោះត្រូវជំរុញចលនាប្រឡងប្រណាំងរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី សម្រាប់ធុរកិច្ចបៃតងដែលមានស្នាដៃឆ្នើមប្រើប្រាស់ផលិតផលក្នុងស្រុក • បង្កើតម៉ាកសម្រាប់ប្រើប្រាស់ផលិតផលក្នុងស្រុក (ឧ. កេរ្តិ៍) បម្រើឱ្យវិស័យទេសចរណ៍ • កំណត់អត្តសញ្ញាណដៃគូសក្តានុពលដែលជាតួអង្គសំខាន់ៗក្នុងគម្រោងនេះ (សហគមន៍ជនបទ អង្គការក្រៅរាជរដ្ឋាភិបាល។ ល។) • ពង្រីងគម្រោងខ្សែក្រវាត់បៃតង ក្នុងតំបន់បន្ទាយស្រី និងបណ្តាស្រុកផ្សេងៗទៀត • បង្កើតថ្នាលបច្ចេកវិទ្យា ដើម្បីតភ្ជាប់រវាងតម្រូវការក្នុងឧស្សាហកម្មទេសចរណ៍ និងការផ្គត់ផ្គង់ផលិតផលក្នុងស្រុក • ផ្សេរបច្ចេកវិទ្យាបណ្តុះបណ្តាល និងផ្តល់យោបល់ គាំទ្រកសិករ សិប្បករ ដើម្បីផលិតផលិតផលឱ្យមានគុណភាព • សម្រួលដល់ហិរញ្ញប្បទានកម្ចីសម្បទានសម្រាប់តួអង្គក្នុងគម្រោងនេះ។	
សារវន្តភាព÷ វិស័យទេសចរណ៍កម្ពុជា បានកំពុងដើរតួយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។ ទន្ទឹមនឹងនេះ ការទាញ			**សមាសភាពអនុវត្តគម្រោង÷** • ជំរុញការប្រើប្រាស់ផលិតផលកសិកម្មក្នុងស្រុក បម្រើឱ្យឧស្សាហកម្មទេសចរណ៍ខេត្តសៀមរាប តាមរយៈការធានាឱ្យមានការផ្គត់ផ្គង់ក្នុងស្រុក ប្រកបដោយគុណភាព ជឿជាក់ និងចីរភាពតាមរយៈការបង្កើតយន្តការអន្តរការី។		

<table>
<tr><td>យកផលប្រយោជន៍សេដ្ឋកិច្ចសង្គមពីឧស្សាហកម្មទេសចរណ៍នៅខេត្តសៀមរាប នៅមានកម្រិតនៅឡើយ ក្នុងនោះភាពធ្ងន់ធ្ងាយសេដ្ឋកិច្ចក្នុងវិស័យទេសចរណ៍មានក្នុងរង្វង់ប្រមាណ (២៥%-៣០%)នៅឡើយ។ ផ្ទុយទៅវិញ ខេត្តសៀមរាបមានសក្តានុពលជាច្រើនដែលអាចរៀបចំ ឬអភិវឌ្ឍឡើងដើម្បីទាញយកផលប្រយោជន៍សេដ្ឋកិច្ច ពីវិស័យទេសចរណ៍តាមរយៈការបង្កើតអន្តរសកម្មរវាងវិស័យកសិកម្ម និងវិស័យទេសចរណ៍ និងការជំរុញឧស្សាហកម្មថ្មៃប្រឌិត (ក្នុងនោះមានសិប្បកម្ម វត្ថុអនុស្សាវរីយ៍...)</td><td>• លើកកម្ពស់សិប្បកម្មកែច្នៃ និងឧស្សាហកម្មច្នៃប្រឌិត (ពិសេសវត្ថុអនុស្សាវរីយ៍) បម្រើឱ្យឧស្សាហកម្មទេសចរណ៍
• ពង្រឹងគុណភាព និងការបណ្តុះបណ្តាលជំនាញដល់កសិករ សិប្បករ...អមជាមួយការបង្កើតបច្ចេកវិទ្យា ចាំបាច់។
• លើកកម្ពស់វិស័យម្ហូបអាហារ បម្រើឱ្យភ្ញៀវទេសចរ
• អភិវឌ្ឍ និងលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម បម្រើឱ្យឧស្សាហកម្មទេសចរណ៍
• បង្កើតស្លាកឡាបិល បញ្ជាក់គុណភាពសម្រាប់ផលិតផលក្នុងស្រុកផ្គត់ផ្គង់ឱ្យឧស្សាហកម្មទេសចរណ៍</td></tr>
<tr><td>គោលបំណង÷
ផ្តល់ផលប្រយោជន៍ដល់ប្រជាជននៅតំបន់ជនបទតាមរយៈឥទ្ធិពលសេដ្ឋកិច្ចពីទេសចរណ៍ និងកាត់បន្ថយនូវភាពក្រីក្រពោលគឺកាត់បន្ថយភាពធ្ងន់ធ្ងាយសេដ្ឋកិច្ចពីវិស័យទេសចរណ៍។</td><td>លទ្ធផលនៃគម្រោង÷
• បង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋមូលដ្ឋាននិងកាត់បន្ថយភាពក្រីក្រតាមរយៈវិស័យទេសចរណ៍
• បង្កើនការពេញចិត្តរបស់ភ្ញៀវទេសចរ និងការទទួលបានបទពិសោធន៍ល្អៗបន្ថែមទៀតតាមរយៈការប្រើប្រាស់ផលិតផលក្នុងស្រុក
• លើកកម្ពស់ភាពច្នៃប្រឌិត នវានុវត្តន៍ និងឧស្សាហកម្មច្នៃប្រឌិតនៅខេត្តសៀមរាប
• អភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានចូលរួមបង្កើនចំណែកនៃឧស្សាហកម្មទេសចរណ៍ក្នុងចរន្តសេដ្ឋកិច្ចខេត្តសៀមរាប។</td></tr>
<tr><td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះ មិនមានផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។

គម្រោងពាក់ព័ន្ធផ្សេងទៀត÷
• ចលនាប្រឡងប្រណាំងរង្វាន់សម្តេចតេជោ នាយករដ្ឋមន្ត្រី ក្នុងធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ដែលមានស្មាដៃធ្ងឹម ក្នុងការប្រើប្រាស់ផលិតផលក្នុងស្រុក
• គម្រោងខ្សែក្រវាត់បៃតងក្នុងតំបន់បន្ទាយស្រី តំបន់បេតិកភណ្ឌអង្គររបស់អង្គការ GIZ។ល។</td><td>របៀបវារៈ / រយៈពេល÷
អនុវត្តគម្រោងក្នុងរយៈពេលខ្លី និងមធ្យមដោយសហការជាមួយប្រតិបត្តិករទេសចរណ៍ សហគមន៍ជនបទ និងដៃគូអភិវឌ្ឍ។</td><td>ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ ២-៣លានដុល្លារអាមេរិក។</td></tr>
</table>

សកម្មភាពអាទិភាពទី២÷ គម្រោងស្តីពី "ការគ្រប់គ្រងហ្វូងភ្ញៀវទេសចរជាតិ និងអន្តរជាតិក្នុងតំបន់បេតិកភណ្ឌអង្គរ"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ តំបន់បេតិកភណ្ឌអង្គរ

ល.រ	ចំណងជើងគម្រោង		ក្រុមទទួលបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.២	ការគ្រប់គ្រងរំហួរភ្ញៀវទេសចរជាតិ និងអន្តរជាតិក្នុងតំបន់ទេសចរណ៍បេតិកភណ្ឌអង្គរ		ភ្ញៀវទេសចរចូលទស្សនាតំបន់បេតិកភណ្ឌអង្គរ	រដ្ឋ	អាទិភាពទី ១
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**វិធីសាស្ត្រនៃការអនុវត្ត÷** • ផ្សារភ្ជាប់ការគ្រប់គ្រងរំហួរភ្ញៀវជាមួយការអនុវត្តគោលនយោបាយ "សំបុត្រអង្គរ"។ • រៀបចំសម្បទាទ្រទ្រង់ ដូចជាការរៀបចំឱ្យមាន Parvis នៅមុខប្រាសាទដើម្បីងាយស្រួលក្នុងការគ្រប់គ្រងរំហួរភ្ញៀវ។ • ការប្រើប្រាស់បច្ចេកវិទ្យាដើម្បីសម្រួលការគ្រប់គ្រងរំហួរភ្ញៀវ និងគ្រប់គ្រងសមត្ថភាពផ្ទុកភ្ញៀវទេសចរនៅតាមប្រាសាទនីមួយៗ ដែលអាចដាក់នៅតាមច្រកចូលនៃប្រាសាទ។ល។		
តំបន់បេតិកភណ្ឌអង្គរ		• អាជ្ញាធរជាតិអប្សរា • ក្រុះស្ថានអង្គរ			
សារវៈ÷ បច្ចុប្បន្នរំហួរទេសចរអន្តរជាតិមានច្រើននៅតាមប្រាសាទសំខាន់ៗតែប៉ុណ្ណោះ ជាពិសេសនៅប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន និងប្រាសាទតាព្រហ្ម។ ការកកស្ទះនៃរំហួរភ្ញៀវទេសចរ គឺបណ្តាលមកពីលំនាំនៃដំណើរកម្សាន្តរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិមានភាពប្រហាក់ប្រហែលគ្នាឬចំពេលតែមួយដែលចំណុចកកស្ទះនេះ ធ្វើឱ្យមានការលើកឡើង និងការយល់ឃើញខុសៗគ្នា ពីសំណាក់ភ្ញៀវទេសចរពិសេសនៅលើបណ្តាញសង្គម។			**សមាសភាពអនុវត្តគម្រោង÷** • ផ្សារភ្ជាប់គោលនយោបាយសំបុត្រអង្គរ និងការគ្រប់គ្រងរំហួរភ្ញៀវ • រៀបចំដាក់ E-Gate សម្រាប់គ្រប់គ្រងរំហួរភ្ញៀវទេសចរនៅបរិវេណមុខប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន និងប្រាសាទតាព្រហ្ម និងមានជាកម្មវិធីទូរស័ព្ទ សម្រាប់ទទួលបានព័ត៌មានអំពីរំហួរភ្ញៀវទេសចរនៅតំបន់នោះ • រៀបចំសម្បទា ដូចជាការរៀបចំមជ្ឈមណ្ឌល (Parvis) សម្រាប់សម្រួលដល់ការគ្រប់គ្រងរំហួរភ្ញៀវនៅតាមប្រាសាទសំខាន់ៗ		
គោលបំណង÷ គោលបំណងនៃគម្រោងនេះ នឹងជួយសម្រួលដល់ការគ្រប់គ្រងរំហួរភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដើម្បីចូលរួមដល់កិច្ចអភិរក្សសម្បត្តិបេតិភណ្ឌអង្គរឱ្យបានគង់វង្សយូរអង្វែងស្របតាមទស្សនាទាន **"អភិវឌ្ឍដើម្បីអភិរក្ស អភិរក្សដើម្បីអភិវឌ្ឍ"** និងគាំទ្រគោលនយោបាយនៃការអភិវឌ្ឍទេសចរណ៍ប្រកបដោយគុណភាព។			**លទ្ធផលនៃគម្រោង÷** • ដោះស្រាយការកកស្ទះនៃចំនួនអ្នកទស្សនានៅតាមប្រាសាទ ក្នុងម៉ោងដែលមានចំនួនភ្ញៀវទេសចរទស្សនាច្រើន និងអំឡុងពេលរដូវកាលកំណើនទេសចរខ្ពស់ ដោយមានការត្រួតពិនិត្យរំហួរអ្នកទស្សនានៅតាមប្រាសាទ និងរំហួរចរាចរនៅក្នុងតំបន់បេតិកភណ្ឌវប្បធម៌។ • កាត់បន្ថយការខូចខាតលើប្រាសាទអារ្យធម៌ដ៏បុរាណនានា ដោយសារភ្ញៀវទេសចរទស្សនាច្រើន។		

<table>
<tr><td colspan="2"></td><td colspan="2">• បង្កើនសមត្ថភាពនៃការគ្រប់គ្រងតំបន់ទាំងនោះ និងលើកកម្ពស់ការយល់ដឹងអំពីតុណតម្លៃជាប្រវត្តិសាស្ត្រ និងបុរាណវិទ្យានៃបេតិកភណ្ឌខ្មែរ។
• បង្កើតរូបភាពវិជ្ជមានសៀមរាប-អង្គរលើបណ្តាញសារព័ត៌មាន និងជាបច្ច័យទាក់ទាញភ្ញៀវទេសចរកម្រិតខ្ពស់ និងគុណភាព។</td></tr>
<tr><td colspan="2">ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះ មិនមានផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។</td><td>របៀបវារៈ / រយៈពេល÷
អនុវត្តរយៈពេលខ្លី ចន្លោះពី២ ទៅ ៣ឆ្នាំ ដោយអាជ្ញាធរជាតិអប្សរា សហការជាមួយគ្រឹះស្ថានអង្គរ។</td><td>ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ ១-២លានដុល្លារអាមេរិក</td></tr>
<tr><td colspan="2">គម្រោងពាក់ព័ន្ធផ្សេងទៀត÷
ផែនការគ្រប់គ្រងទេសចរណ៍អង្គរ (TMP) របស់អាជ្ញាធរជាតិអប្សរា។</td></tr>
</table>

សកម្មភាពអាទិភាពទី៣÷ គម្រោងស្តីពី "ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រការអភិវឌ្ឍទេសចរណ៍ឌីជីថលនៅខេត្តសៀមរាប (Digital Tourism)"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ ផលិតផលទេសចរណ៍ឌីជីថល

<table>
<tr><th>ល.រ</th><th colspan="2">ចំណងជើងគម្រោង</th><th>ក្រុមទទួលបានផលពីគម្រោង</th><th>ថវិការំពឹងទុក</th><th>អាទិភាពនៃគម្រោង</th></tr>
<tr><td>ស.អ.៣</td><td colspan="2">ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រការអភិវឌ្ឍទេសចរណ៍ឌីជីថលនៅខេត្តសៀមរាប</td><td>ឧស្សាហកម្មទេសចរណ៍</td><td>រដ្ឋ-ឯកជន</td><td>អាទិភាព ១ និង ២</td></tr>
<tr><td colspan="2">ទីតាំងគម្រោង</td><td>ភ្នាក់ងារអនុវត្តគម្រោង</td><td colspan="3" rowspan="2">វិធីសាស្ត្រនៃការអនុវត្ត÷
• ការវិនិយោគលើបច្ចេកវិទ្យាឌីជីថលទំនើបៗគាំទ្រដល់ផលិតផលទេសចរណ៍ឌីជីថល ដូចមានចែងក្នុងចំណុចទី៣ ជំពូក២។ ឧទាហរណ៍មានដូចខាងក្រោម÷
- បច្ចេកវិទ្យា Virtual Reality (VR)/Augmented Reality (AR)
- បច្ចេកវិទ្យា 3D
- បច្ចេកវិទ្យា Internet of Thing (IoTs)
- បច្ចេកវិទ្យា Audio Record និង QR Code
- បច្ចេកវិទ្យា Smart & Wearable Devices ឬ Voice Technology
- បច្ចេកវិទ្យា Artifical Intelligence (AI)
- ប្រព័ន្ធគ្រប់គ្រង Data base ក្នុងវិស័យទេសចរណ៍ខេត្តសៀមរាប។
• ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសេវាទូរគមនាគមន៍ និងសេវាអ៊ីនធឺណិតឱ្យមាននៅទីតាំងសាធារណៈ និងនៅតាមតំបន់ទេសចរណ៍អាទិភាពក្នុងខេត្តសៀមរាប÷
- ការពង្រីកការផ្តល់សេវាកម្មអ៊ីនធឺណិតល្បឿនលឿន (Broadband) នៅតាមតំបន់ទេសចរណ៍អាទិភាពក្នុងខេត្តសៀមរាប
- ត្រូវបំពាក់ឱ្យមាន Wi-Fi នៅទីតាំងសាធារណៈនានាក្នុងក្រុងសៀមរាប និងតំបន់ទេសចរណ៍បេតិកភណ្ឌអង្គរ និងតាមរមណីយដ្ឋានទេសចរណ៍សំខាន់ៗក្នុងខេត្តសៀមរាប
- ការបង្កើតកម្មវិធីលើទូរស័ព្ទ និងការបំពាក់បច្ចេកវិទ្យាឌីជីថលសមស្របនានានៅតាមមូលដ្ឋានអាជីវកម្ម និងគោលដៅទេសចរណ៍នានា ក្នុងខេត្តសៀមរាប។ល។</td></tr>
<tr><td colspan="2">ខេត្តសៀមរាប</td><td>• ក្រសួងទេសចរណ៍
• ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
• រដ្ឋបាលខេត្តសៀមរាប
• អាជ្ញាធរជាតិអប្សរា
• វិស័យឯកជន
• DMO's</td></tr>
<tr><td colspan="2">សាវតារ÷</td><td colspan="3">សមាសភាពអនុវត្តគម្រោង÷</td></tr>
</table>

<table>
<tr><td>ការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប ត្រូវផ្សារភ្ជាប់នឹងការអភិវឌ្ឍទេសចរណ៍ឌីជីថលនាពេលអនាគត។ ក្នុងន័យនេះ មានការលើកឡើងថា ជំហានឆ្ពោះទៅរកចំនួន៥ ដែលឧស្សាហកម្មទេសចរណ៍នៅខេត្តសៀមរាបគួរអនុវត្តរួមមាន÷
• ផ្តោតការយកចិត្តទុកដាក់ទៅលើការវិវត្តនៃឧស្សាហកម្ម ៤.០ ក្នុងគំរូធុរកិច្ចរបស់ខ្លួន។
• ធ្វើការកំណត់អំពីឥទ្ធិពលនៃបច្ចេកវិទ្យាមកលើការអភិវឌ្ឍវិស័យទេសចរណ៍ពិសេសលើការប្រែប្រួលនៃតម្រូវការរបស់ភ្ញៀវទេសចរ។
• ត្រៀមខ្លួនសម្រាប់ការឈានជើងចូលទីផ្សារនៃឧស្សាហកម្មទេសចរណ៍ និងការធ្វើដំណើរ ក្នុងបរិបទនៃសេដ្ឋកិច្ចឌីជីថល។
• ត្រូវយកចិត្តទុកដាក់លើទំនាក់ទំនង B2B ដូចគ្នាទៅនឹងទំនាក់ទំនង B2C ក្នុងវិស័យទេសចរណ៍ តាមរយៈការប្រើប្រាស់ថ្នាលបច្ចេកវិទ្យា។
• ត្រូវយកចិត្តទុកដាក់ក្នុងការប្រើប្រាស់ទិន្នន័យដើម្បីប្រមើមើលពីហានិភ័យក្នុងការដោះស្រាយបញ្ហា ដែលអាចកើតនៅតាមតំបន់ទេសចរណ៍អាទិភាពនីមួយៗ។</td><td>• គម្រោងគោលដៅទេសចរណ៍ឆ្លាតនៅតំបន់ទេសចរណ៍អាទិភាពក្នុងខេត្តសៀមរាប
• គម្រោងអភិវឌ្ឍទីក្រុងឆ្លាតនៅក្រុងសៀមរាប និងតំបន់ទេសចរណ៍សៀមរាបថ្មី
• គម្រោងប្រព័ន្ធគ្រប់គ្រងទិន្នន័យទេសចរណ៍ និងស្ថិតិទេសចរណ៍
• គម្រោងផ្សព្វផ្សាយទេសចរណ៍តាមប្រព័ន្ធឌីជីថល
• គម្រោងបង្កើតធុរកិច្ចថ្មីៗ គាំទ្រទេសចរណ៍ខេត្តសៀមរាប។ល។</td></tr>
<tr><td>គោលបំណង÷
• ធ្វើពិពិធកម្មផលិតផល និងសេវាកម្មនៅខេត្តសៀមរាប និងនិរន្តរភាពផ្សព្វផ្សាយទេសចរណ៍តាមរយៈបច្ចេកវិទ្យាទំនើបៗ
• ផ្តល់បទពិសោធន៍ពិសេសប្លែកៗ និងថ្មីៗដល់ភ្ញៀវទេសចរ
• បង្កើនភាពប្រកួតប្រជែងទេសចរណ៍កម្ពុជា។</td><td>លទ្ធផលនៃគម្រោង÷
• បង្កើនភាពប្រកួតប្រជែងទេសចរណ៍ខេត្តសៀមរាប
• គ្រប់គ្រងទិន្នន័យទេសចរណ៍ និងស្ថិតិទេសចរណ៍ខេត្តសៀមរាប
• បង្កើនសមត្ថភាពផ្សព្វផ្សាយទេសចរណ៍ឌីជីថល។ល។</td></tr>
<tr><td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះមិនមានផលប៉ះពាល់ដល់ផ្នែកបរិស្ថាន និងសង្គម ។</td><td rowspan="2">របៀបវារៈ / រយៈពេល÷
អនុវត្តរយៈពេលមធ្យម និងវែង ដោយក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋបាលខេត្តសៀមរាប អាជ្ញាធរជាតិអប្សរា និងផ្នែកឯកជន។</td><td rowspan="2">ថ្លៃដើមនៃគម្រោង÷
គម្រោងនៃការអភិវឌ្ឍនេះ ពិបាកប៉ាន់ប្រមាណថ្លៃដើមនៃគម្រោង ព្រោះផ្អែកលើបច្ចេកវិទ្យាជាក់ស្តែងនិងការផ្គត់ផ្គង់សេវាកម្មរបស់ក្រុមហ៊ុនអន្តរជាតិ ឬក្នុងស្រុក។</td></tr>
<tr><td>គម្រោងពាក់ព័ន្ធផ្សេងទៀត÷
អាជ្ញាធរជាតិអប្សរាកំពុងរៀបចំឱ្យមានអង់តែនទូរស័ព្ទនៅក្នុងតំបន់បេតិកភណ្ឌអង្គរ។</td></tr>
</table>

សកម្មភាពអាទិភាពទី៤÷ គម្រោងស្តីពី "ការអភិវឌ្ឍខ្សែទស្សនាទេសចរណ៍មហិទ្ធិបពិតនៅឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម-"ភ្នំគូលែន"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ តំបន់ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម-"ភ្នំគូលែន"

ល.រ	ចំណងជើងគម្រោង		ក្រុមទទួលបានផលពីគម្រោង	អាទិភាពនៃគម្រោង
ស.អ.៤	ការអភិវឌ្ឍខ្សែទស្សនាចរទេសចរណ៍មហិទ្ធិបពិតនៅតំបន់ឧទ្យានជាតិភ្នំគូលែន		ប្រតិបត្តិករទេសចរណ៍សហគមន៍ទេសចរណ៍ និងភ្ញៀវទេសចរ	អាទិភាព ១
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**វិធីសាស្ត្រនៃការអនុវត្ត÷**	
ឧទ្យានជាតិភ្នំគូលែន និងតំបន់ជុំវិញ		• ក្រសួងទេសចរណ៍ • ក្រសួងបរិស្ថាន • អាជ្ញាធរជាតិអប្សរា • អាជ្ញាធរគ្រប់គ្រងឧទ្យានជាតិ • ប្រតិបត្តិករទេសចរណ៍ • DMO's	• ការកែលម្អផ្លូវតភ្ជាប់បម្រើឱ្យខ្សែទស្សនានេះ • ការដាក់ស្លាកសញ្ញាទិសដៅ និងបង្ហាញទីតាំង • ការលើកស្ទួយការចាប់អារម្មណ៍ទេសចរណ៍ក្នុងខ្សែទស្សនាចរទេសចរណ៍តាមរយៈការផ្សព្វផ្សាយ • ពង្រឹងគុណភាពនៃការផ្តត់ផ្គង់ទេសចរណ៍ក្នុងតំបន់ឧទ្យានជាតិភ្នំគូលែន និងតំបន់ជុំវិញ (កន្លែងស្នាក់នៅ កន្លែងកម្សាន្ត.....) អមជាមួយការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព • បង្កើតមគ្គុទ្ទេសក៍ទេសចរណ៍បម្រើឱ្យខ្សែទស្សនាចរនេះ • បង្កើតកម្មវិធីផ្សព្វផ្សាយទេសចរណ៍តាមប្រព័ន្ធឌីជីថល • អភិវឌ្ឍផលិតផលទេសចរណ៍បម្រើឱ្យខ្សែទស្សនានេះ	
សារវាន្ត÷ ប្រើប្រាស់ធនធានធម្មជាតិ វប្បធម៌ និងចរិតលក្ខណៈនៃទឹកដីឧទ្យានជាតិភ្នំគូលែន ដើម្បីអភិវឌ្ឍជាសកម្មភាពទេសចរណ៍ (ធម្មជាតិ សាសនា) រួមផ្សំការកម្សាន្តបែបកីឡាផ្សងព្រេងដែលអាចផ្តល់ឱ្យភ្ញៀវទេសចរអាចស្វែងយល់ពីភាពសម្បូរបែប អំពីឧទ្យានជាតិភ្នំគូលែន និងបទពិសោធន៍ល្អៗ។			**សមាសភាពអនុវត្តគម្រោង÷** • បង្កើតឱ្យមានផលិតផលទេសចណ៍ ដំណើរកម្សាន្តឡើងភ្នំ ក្នុងទម្រង់ជាវង់ទស្សនា និងដំណើរវិលជុំ • រៀបចំកញ្ចប់ទស្សនកិច្ចសម្រាប់ទេសចរណ៍ផ្សងព្រេងផ្សារភ្ជាប់ជាមួយទេសចរណ៍សាសនា • ដាក់ស្លាកសញ្ញាទិសដៅ និងបង្ហាញទីតាំង • បង្កើតឱ្យមានមគ្គុទ្ទេសក៍ក្នុងតំបន់ឧទ្យានជាតិភ្នំគូលែន • កែលម្អផ្លូវទស្សនាចរ (ផ្លូវដើរ ផ្លូវជិះកង់ និងម៉ូតូ) • ការសាងសង់មណ្ឌលពិព័រណ៍ ទីតាំងសមាធិ និងសេវាកម្មទេសចរណ៍ទ្រទ្រង់នៅក្នុងតំបន់ឧទ្យានជាតិភ្នំគូលែន។ល។	
គោលបំណង÷			**លទ្ធផលនៃគម្រោង÷**	

<table>
<tr><td>• ធ្វើពិពិធកម្មការផ្គត់ផ្គង់ទេសចរណ៍ជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យកាន់តែសម្បូរបែប (សៀមរាប÷ លើសពីប្រាសាទ)
• ប្រែក្លាយតំបន់ឧទ្យានជាតិភ្នំគូលែន គឺជាតំបន់ទេសចរណ៍ដ៏ទាក់ទាញសម្រាប់ខេត្តសៀមរាប និងពន្យារការទស្សនាឧទ្យានជាតិភ្នំគូលែនឱ្យបានយ៉ាងតិច ៣ថ្ងៃ ២យប់។</td><td colspan="2">• អាចពន្យារការស្នាក់នៅរបស់ភ្ញៀវទេសចរយ៉ាងហោច ១ថ្ងៃបន្ថែម
• បង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋមូលដ្ឋាន តាមរយៈការប្រកបរបរបម្រើឱ្យភ្ញៀវទេសចរ និងចូលរួមដល់កិច្ចអភិរក្ស និងថែរក្សាធនធានធម្មជាតិ
• តាមរយៈពិពិធកម្មទេសចរណ៍ថ្មីៗទាំងនេះនឹងអាចទាក់ទាញភ្ញៀវទេសចរមកកម្សាន្តកាន់តែច្រើន
• ប្រែក្លាយតំបន់នេះជាតំបន់ទេសចរណ៍អាទិភាពក្នុងខេត្តសៀមរាប។</td></tr>
<tr><td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះ មិនមានប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។</td><td rowspan="2">របៀបវារៈ / រយៈពេល÷
អនុវត្តរយៈពេលខ្លី ដោយDMO និងក្រសួងបរិស្ថាន សហការជាមួយអាជ្ញាធរជាតិអប្សរា និងផ្នែកឯកជន។</td><td rowspan="2">ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ ១ លានដុល្លារអាមេរិក។</td></tr>
<tr><td>ហេតុផល÷
សំណើដែលធ្វើឡើងដោយប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាបដែលបានលើកឡើងក្នុងកិច្ចប្រជុំការងារនៃលេខាធិការដ្ឋាននៃគណៈកម្មាធិការអន្តរក្រសួងនៅ ខែ កក្កដា ឆ្នាំ ២០១៩ ដែលបានបង្ហាញថាភ្ញៀវទេសចរអន្តរជាតិនឹងចាប់អារម្មណ៍ ប្រសិនបើផលិតផលដើរកម្សាន្តឡើងភ្នំ ត្រូវបានបង្កើតឡើងនៅក្នុងឧទ្យានជាតិភ្នំគូលែន។</td></tr>
</table>

សកម្មភាពអាទិភាពទី៥÷ គម្រោងស្តីពី "ការបង្កើតផ្លូវទស្សនាទេសចរណ៍បេតិកភណ្ឌខ្មែរ"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ ផលិតផលទេសចរណ៍វប្បធម៌

ល.រ	ចំណងជើងគម្រោង		ក្រុមទទួលបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.៥	ការបង្កើតផ្លូវទស្សនាទេសចរណ៍បេតិកភណ្ឌខ្មែរ		ភ្ញៀវទេសចរ ប្រជាពលរដ្ឋមូលដ្ឋាន វិស័យឯកជន និង អាជីវកម្មក្នុងវិស័យទេសចរណ៍	រដ្ឋ-ដៃគូអភិវឌ្ឍ	អាទិភាព ១
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**សមាសធាតុនៃគម្រោង÷** ទំហំនៃគម្រោងនេះ រួមមានតំបន់ចំនួន ៥ដូចខាងក្រោម÷		
តំបន់ភាគពាយព្យ (ខេត្តចំនួន ៥)		• ក្រសួងទេសចរណ៍ • ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ • ក្រសួងបរិស្ថាន • អាជ្ញាធរជាតិអប្សរា • អាជ្ញាធរខេត្តព្រះវិហារ • រដ្ឋបាលខេត្តពាក់ព័ន្ធ • គ្រឹះស្ថានអង្គរ	• តំបន់ឧទ្យានជាតិភ្នំគូលែន - ពង្រឹង និងរៀបចំការអភិវឌ្ឍទេសចរណ៍ក្នុងឧទ្យានជាតិភ្នំគូលែន • តំបន់បេតិកភណ្ឌអង្គរ - ការគ្រប់គ្រងទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌអង្គរ • តំបន់សម្បុរបែបក្នុងទីក្រុង និងទេសចរណ៍វប្បធម៌ក្នុងក្រុងសៀមរាប តំបន់ទេសចរណ៍បន្ទាយស្រី និងតំបន់ទេសចរណ៍សៀមរាបថ្មី - ការរៀបចំសារមន្ទីរវប្បធម៌ប្រពៃណីអង្គរ និងអរិយធម៌ខ្មែរ - ការរៀបចំមជ្ឈមណ្ឌលសិក្សាពីធម្មជាតិ និងសួនរុក្ខសាស្ត្រ និងសារមន្ទីរស្រូវ - ការរៀបចំពង្រឹងសម្បទាទេសចរណ៍សៀមរាប និងតំបន់ជុំវិញ (ស្ថាប័នបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងស្រាវជ្រាវ) - ការអភិវឌ្ឍឱ្យមានមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ផ្សារភ្ជាប់នឹង Parvis • បឹងទន្លេសាប និងតំបន់ជនបទ - ការកែលម្អសម្បទាទេសចរណ៍នៅចុងឃ្នាស (ស្តង់ព័ត៌មានទេសចរណ៍ បង្គន់សាធារណៈ ស្ថានសង្គ្រោះ កន្លែងសម្រាកចំណតយានយន្ត) - ការកែលម្អតំបន់ភ្នំក្រោម (សម្បទាសម្រាប់កន្លែងមើលទេសភាព កន្លែងសម្រាក បង្គន់សាធារណៈចំណតយានយន្ត • តំបន់ប្រាសាទនានាដែលស្ថិតនៅឆ្ងាយពីតំបន់បេតិកភណ្ឌអង្គរ (ការអភិវឌ្ឍបណ្តាញបេតិកភណ្ឌខ្មែរ)		
សាវតារ÷ ភាគច្រើននៃប្រាសាទតំបន់បេតិកភណ្ឌអង្គរនៅប្រទេសកម្ពុជា ត្រូវបានសាងសង់នៅចន្លោះសតវត្សទី ៧ និង ១៤ នៅខេត្តសៀមរាប និងខេត្តជុំវិញ (ខេត្តព្រះវិហារ កំពង់ធំ បាត់ដំបង បន្ទាយមានជ័យ និងឧត្តរមានជ័យ)។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ភ្ញៀវទេសចរអាចទៅទស្សនាមិនត្រឹមតែប្រាសាទអង្គរវត្ត និងប្រាសាទដទៃទៀតនៅក្នុងតំបន់បុរាណអង្គរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចទៅទស្សនាប្រាសាទជាច្រើនផ្សេងទៀត ដូចជា ប្រាសាទបេងមាលា ប្រាសាទកោះកេរ្តិ៍ ក្បាលស្ពាន ភ្នំគូលែន បន្ទាយឆ្មារ និងប្រាសាទសម្បុរព្រៃគុហ៍ សម្រាប់ដំណើរកម្សាន្តរយៈពេលមួយថ្ងៃ។ ដំណើរកម្សាន្តទៅកាន់ប្រាសាទបុរាណខ្មែរឆ្ងាយៗ និងការបង្កើតសៀគ្វីទេសចរណ៍បេតិកភណ្ឌខ្មែរ គឺជាធនធានទេសចរណ៍ដ៏មានសក្តានុពល					

<table>
<tr><td>សម្រាប់ស្វែងយល់និងអនុវត្តតាមផ្លូវទេសចរណ៍បេតិកភណ្ឌខ្មែរ។ ទោះជាយ៉ាងណាតំបន់ប្រាសាទឆ្ងាយៗ ភាគច្រើន នៅខ្វះស្ថាកសញ្ញាបង្ហាញតំបន់ទេសចរណ៍ រឹងសម្បទាទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មនៅពុំមានគ្រប់គ្រាន់សម្រាប់បម្រើដល់វិស័យទេសចរណ៍នៅឡើយ។</td><td>- ការកែលម្អ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍នានានៅប្រាសាទព្រះវិហារ ប្រាសាទសម្បូរព្រៃគុហ៍ ប្រាសាទបេងមាលា ភ្នំគូលែន ក្បាលស្ពាន ប្រាសាទកោះកេរ្តិ៍ ប្រាសាទបន្ទាយឆ្មារ និងតំបន់ប្រាសាទនៅខេត្តបាត់ដំបង។ ល។
- រៀបចំឱ្យមានស្ថានីយចំណតលើផងផ្លូវភ្ជាប់បណ្តាញទេសចរណ៍បេតិកភណ្ឌពិភពលោកទាំងនេះ
- បង្កើតឱ្យមានផលិតផលទេសចរណ៍ទាក់ទាញនានាពិសេសឱ្យមាននៅប្រាសាទព្រះវិហារ ប្រាសាទសម្បូរព្រៃគុហ៍។
- រៀបចំបណ្តុំទស្សនាចរណ៍កញ្ចប់បេតិកភណ្ឌពិភពលោកនេះ (ផ្នែកមួយនៃបណ្តាញទេសចរណ៍សៀមរាប)។</td></tr>
<tr><td>គោលបំណងនៃគម្រោង÷
• បង្កើតផ្លូវទស្សនាចរទេសចរណ៍តភ្ជាប់បេតិកភណ្ឌពិភពលោករបស់កម្ពុជា (តំបន់បេតិកភណ្ឌអង្គរ ប្រាសាទព្រះវិហារ ប្រាសាទសំបូរព្រៃគុហ៍)
• ផ្សព្វផ្សាយដំណើរកម្សាន្តទេសចរណ៍ និងសៀគ្វីទេសចរណ៍បេតិកភណ្ឌរបស់ខ្មែរពិសេសបេតិកភណ្ឌពិភពលោកតាមរយៈការកែលម្អ និងអភិវឌ្ឍសម្បទាផ្តល់ សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍គាំទ្រ។</td><td>លទ្ធផលនៃគម្រោង÷
• ខេត្តសៀមរាបក្លាយជាគោលដៅទេសចរណ៍បេតិកភណ្ឌពិភពលោកដែលមានភាពទាក់ទាញច្រើនជាងមុន ដោយមានផលិតផលទេសចរណ៍ចម្រុះ ការអភិវឌ្ឍបណ្តាញបេតិកភណ្ឌខ្មែរ និងតំបន់ទាក់ទាញទេសចរណ៍បន្ថែមសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។ គម្រោងនេះ នឹងជួយបំបែកវិហ្សរនៃភ្ញៀវទេសចរប្រមូលផ្តុំទៅកាន់ឧទ្យានជាតិអង្គរក្នុងរដូវកាលមានភ្ញៀវទេសចរខ្ពស់ និងជួយបង្កើនរយៈពេលស្នាក់នៅរបស់ទេសចរភ្ញៀវក្នុងខេត្តសៀមរាប។
• បង្កើនវិហ្សរទស្សនារបស់ភ្ញៀវទេសចរទៅកាន់តំបន់បេតិកភណ្ឌពិភពលោកផ្សេងទៀតរបស់កម្ពុជា ដែលជាបច្ច័យនាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដល់ខេត្ត ដែលស្ថិតក្នុងផ្លូវទេសចរណ៍បេតិកភណ្ឌខ្មែរនេះ។</td></tr>
<tr><td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះ មិនមានផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន និងសង្គម។</td><td>របៀបវារៈ / រយៈពេល÷
អនុវត្តរយៈពេលខ្លី ដោយក្រសួងទេសចរណ៍សហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងបរិស្ថាន អាជ្ញាធរជាតិអប្សរា អាជ្ញាធរ និងវិស័យឯកជន។</td><td>ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ ១លានដុល្លារអាមេរិក (ដោយមិនគិតបញ្ចូលការរៀបចំសម្បទាទេសចរណ៍ទ្រទ្រង់ក្នុងកញ្ចប់ផ្លូវទេសចរណ៍បេតិកភណ្ឌនេះ)។</td></tr>
</table>

សកម្មភាពអាទិភាពទី៦÷ គម្រោងស្តីពី "ការកែលម្អស្ទឹងសៀមរាបជាស្ទឹងទេសចរណ៍បៃតង"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ ការអភិវឌ្ឍតំបន់ទេសចរណ៍ក្រុងសៀមរាប

ល.រ	ចំណងជើងគម្រោង		ក្រុមឧទ្ទិសបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.៦	ការកែលម្អស្ទឹងសៀមរាបជាស្ទឹងទេសចរណ៍បៃតង		ប្រជាជន ភ្ញៀវទេសចរ ប្រតិបត្តិការទេសចរណ៍	រដ្ឋ	អាទិភាព ១ និង ២
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**វិធីសាស្ត្រនៃការអនុវត្ត÷** • កំណត់ទីតាំងនៃដងស្ទឹង តំបន់ដែលមានសក្តានុពលបម្រើឱ្យវិស័យទេសចរណ៍ • ផ្អែកលើលក្ខណៈប្រវត្តិសាស្ត្រ តំបន់មួយចំនួននៃដងស្ទឹងត្រូវអភិរក្សស្ថានភាពដើមនៃតំបន់ • ធ្វើការសិក្សាពីផលប៉ះពាល់ និងសក្តានុពលនៃហេដ្ឋារចនាសម្ព័ន្ធនីមួយៗ ដើម្បីងាយស្រួលក្នុងការវាយតម្លៃ និងដាក់ចេញនូវស្តង់ដាបច្ចេកទេស សមាមាត្រនឹងការប្រើប្រាស់ • កំណត់សកម្មភាព នៃសេវាកម្មទេសចរណ៍អាទិភាព • កំណត់ទីតាំង និងវិធីសាស្ត្រនៃបច្ចេកទេសស្តារស្ទឹងសៀមរាបនៅចំណុចដែលមានបញ្ហារាំងស្ទះ។		
តំបន់បន្ទាយស្រី, ក្រុងសៀមរាប, តំបន់បេតិកភណ្ឌអង្គរ		• រដ្ឋបាលខេត្តសៀមរាប • ក្រសួងទេសចរណ៍ • ក្រសួងបរិស្ថាន • ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ • អាជ្ញាធរជាតិអប្សរា			
សារវន្តភាព÷ ស្ទឹងសៀមរាប ត្រូវបានចាត់ទុកថា ជាស្ទឹងប្រវត្តិសាស្ត្រមួយដ៏សំខាន់សម្រាប់ខេត្តសៀមរាប។ ស្ទឹងសៀមរាប កកើតឡើងដោយសារការប្រសព្វគ្នារវាងអូរធំៗចំនួន២ គឺ អូរធំ និងអូរក្បាលស្ពាន។ ស្ទឹងសៀមរាប ស្ថិតក្នុងចំណោមស្ទឹងសំខាន់ទាំងបី ដែលហូរកាត់តំបន់អង្គរ ដោយធ្វើដំណើរពីជើងទៅត្បូង។ ស្ទឹងនេះ ស្ថិតនៅខាងកើតស្ទឹងពួក និងខាងលិចស្ទឹងរលួស។ ដោយសារដងស្ទឹងសៀមរាបមានភាពល្អឯក និងមានប្រវត្តិសាស្ត្រដ៏ឃ្លាតឆ្ងាយ ស្ទឹងនេះបានជះឥទ្ធិពលដល់សក្តានុពលទេសចរណ៍នៃតំបន់សៀមរាបអង្គរ។ សក្តានុពលទេសចរណ៍នៃស្ទឹងសៀមរាប គួរតែត្រូវបានរៀបចំគិតគូរកែប្រែឱ្យក្លាយជាផលិតផលទេសចរណ៍ថ្មី ដែលទាក់ទាញស្របតាមយុទ្ធនាការ "សៀមរាប÷ ក្រៅពីប្រាសាទ"។		**សមាសភាពអនុវត្តគម្រោង÷** • បែងចែកអនុតំបន់អាទិភាពសម្រាប់ការអភិវឌ្ឍ (រយៈពេលខ្លី មធ្យម និងវែង)គោរព និងរក្សាទេសភាពរបស់អនុតំបន់របស់ដងស្ទឹង ជាពិសេសតំបន់ក្បែរអង្គរ។ គម្រោងនេះមាន ៣ ដំណាក់កាល÷ - **ដំណាក់កាលទី១ (២០២០-២០២២)÷** ពង្រឹងការអភិវឌ្ឍផ្នែកកណ្តាលនៃស្ទឹងសៀមរាប - **ដំណាក់កាលទី២ (២០២២-២០២៤)÷** នៅផ្នែកខាងលើរៀបចំសកម្មភាពទេសចរណ៍ (ក្នុងតំបន់ទេសចរណ៍បេតិកភណ្ឌអង្គរ) - **ដំណាក់កាលទី៣ (២០២៤-២០២៨)÷** រៀបចំផ្នែកខាងក្រោមឆ្ពោះទៅបឹងទន្លេសាប • សិក្សាពីសមិទ្ធផល និងផលប៉ះពាល់បរិស្ថាន • បង្កើតផលិតផល និងសកម្មភាពទេសចរណ៍ថ្មីៗនៅតាមដងស្ទឹងសៀមរាប • រក្សាទេសភាពដងស្ទឹង ក្នុងគោលបំណងអភិរក្ស • រៀបចំជាសៀគ្វីនៃតំបន់ដងស្ទឹងជាសៀគ្វីទេសចរណ៍		

<table>
<tr><td></td><td colspan="3">• រៀបចំហេដ្ឋារចនាសម្ព័ន្ធនៅត្រង់ផ្នែកអាទិភាពដើម្បីទ្រទ្រង់សកម្មភាពទេសចរណ៍ ប៉ុន្តែត្រូវតែជាមានការគិតគូរកត្តាបរិស្ថានខ្ពស់
• ស្តារស្ទឹងសៀមរាបនៅផ្នែកកណ្តាល និងផ្នែកខាងក្រោម
• កែលម្អផ្លូវអមសងខាងស្ទឹងសៀមរាប (នៅផ្នែកកណ្តាល ស្ថិតក្នុងក្រុងសៀមរាប) ជាផ្លូវមានភាពទាក់ទាញទេសចរណ៍ក្នុងបរិបទនៃទីក្រុងទំនើប។</td></tr>
<tr><td>គោលបំណង÷ គម្រោងការកែលម្អដងស្ទឹងសៀមរាបនេះ មានគោលបំណង÷
• កែលម្អសោភណភាព និងលើកកម្ពស់សោភណភាពតាមដងស្ទឹង
• បង្កើតសម្បទាទេសចរណ៍តាមដងស្ទឹង
• ទាក់ទាញការធ្វើដំណើររបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យមកច្រើនដង
• បង្កើតសកម្មភាពទេសចរណ៍ នៅតាមដងស្ទឹង
• រៀបចំបរិស្ថានស្អាត និងអនាម័យតាមដងស្ទឹង
• បង្កើតនិងបង្កើនភាពទាក់ទាញទេសចរណ៍ស្ទឹងសៀមរាបជាស្ទឹងប្រណីត។</td><td colspan="3">លទ្ធផលនៃគម្រោង÷
• ស្ទឹងសៀមរាបមានលក្ខណៈប្រសើរឡើង និងមានលក្ខណៈប្រណីតធៀបនៅក្នុងតំបន់ និងពិភពលោក
• អាចពន្យារការស្នាក់នៅរបស់ភ្ញៀវទេសចរពីព្រោះថាមានផលិតផលទេសចរណ៍ថ្មីៗបន្ថែមទៀត
• បង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋមូលដ្ឋាន តាមរយៈការប្រកបរបរបម្រើឱ្យភ្ញៀវទេសចរ
• តាមរយៈពិពិធកម្មទេសចរណ៍ថ្មីៗទាំងនេះនឹងអាចទាក់ទាញភ្ញៀវទេសចរមកកម្សាន្តកាន់តែច្រើន
• ប្រែក្លាយតំបន់ស្ទឹងសៀមរាបជាតំបន់ទេសចរណ៍ប្រកបដោយនិរន្តរភាព និងបៃតង
• លើកកម្ពស់សោភណភាព បរិស្ថានស្អាត នៅស្ទឹងសៀមរាប និងតំបន់ជុំវិញនោះ
• រក្សាអនាម័យស្ទឹងសៀមរាប</td></tr>
<tr><td>ផលប៉ះពាល់ផ្នែកបរិស្ថាន ÷
គម្រោងនេះ មិនមានផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថានទេ។</td><td rowspan="3">របៀបវារៈ / រយៈពេល÷
អនុវត្តរយៈពេលខ្លី និងមធ្យម ដោយគណៈកម្មាធិការជាតិអភិវឌ្ឍទេសចរណ៍ រដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរជាតិអប្សរា ក្រោមកិច្ចសហការជាមួយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងបរិស្ថាន និងក្រសួងសាធារណៈការ និងដឹកជញ្ជូន។</td><td rowspan="3">ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ ១០-២០លាន ដុល្លារអាមេរិក។</td></tr>
<tr><td>ហេតុផល÷
ការកែលម្អស្ទឹងសៀមរាបគឺជាកត្តាសំខាន់មួយសម្រាប់ទីក្រុងទេសចរណ៍បេតិកភណ្ឌប្រវត្តិសាស្ត្រមួយនេះដើម្បីកសាងនូវកេរ្តិ៍ឈ្មោះបន្ថែម និងធ្វើពិពិធកម្មផលិតផលទេសចរណ៍ (ទេសចរណ៍ទីក្រុង) សម្រាប់ផ្សព្វផ្សាយលើទីផ្សារអន្តរជាតិ និងជំរុញចលនាទេសចរណ៍ក្នុងស្រុកស្របជាមួយសក្តានុពលទេសចរណ៍នៃស្ទឹងសៀមរាបសម្រាប់បង្កើនភាពទាក់ទាញទេសចរណ៍នាពេលអនាគត។</td></tr>
<tr><td>គម្រោងពាក់ព័ន្ធផ្សេងទៀត÷
មានគម្រោងស្តារ និងកែលម្អស្ទឹងសៀមរាប (ផ្នែកកណ្តាល និងម្តុំផ្សារចាស់) ក្រោមហិរញ្ញប្បទានរបស់ទីភ្នាក់ងារអភិវឌ្ឍបារាំង (AFD) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)។</td></tr>
</table>

សកម្មភាពអាទិភាពទី៧÷ គម្រោងស្តីពី "ការកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងសៀមរាបគាំទ្រទិសំយទេសចរណ៍"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ ការអភិវឌ្ឍទេសចរណ៍តំបន់ក្រុងសៀមរាប

ល.រ	ចំណងជើងគម្រោង		ក្រុមឧទ្ទេសបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.៧	ការកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងសៀមរាបគាំទ្រវិស័យទេសចរណ៍		ប្រជាពលរដ្ឋ ភ្ញៀវទេសចរ ប្រតិបត្តិករទេសចរណ៍	រដ្ឋ	អាទិភាព ១
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**វិធីសាស្ត្រនៃការអនុវត្ត÷**		
ក្រុងសៀមរាប		• គណៈកម្មការអន្តក្រសួង ដើម្បីសិក្សា និងអនុវត្តគម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន ៣៨ខ្សែក្នុងក្រុងសៀមរាប ខេត្តសៀមរាប • រដ្ឋបាលខេត្តសៀមរាប	កំណត់ប្រភេទទីតាំងផ្លូវអាទិភាព និងធ្វើការសិក្សាកែលម្អ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធនិងអនុវត្ត/ដាក់ឱ្យដំណើរការដោយគិតគួរដល់ផ្លូវទេសចរណ៍ថ្មើរជើង ផ្លូវសម្រាប់ការបែងចែកការធ្វើដំណើររបស់រថយន្ត ផ្លូវសម្រាប់ម៉ូតូ ផ្លូវសម្រាប់ជិះកង់ ផ្លូវសម្រាប់ជនពិការ សួនទេសចរណ៍ ការបំពាក់សម្បទាទេសចរណ៍ និងសម្បទាមួយចំនួនដែលបម្រើឱ្យវិស័យទេសចរណ៍សម្រាប់ក្រុងសៀមរាប។		
សារវន្តរ÷ ហេដ្ឋារចនាសម្ព័ន្ធក្នុងទីក្រុងសៀមរាប ត្រូវបានលើកឡើងជាញឹកញាប់ដោយ ប្រជាជន ភ្ញៀវទេសចរ ប្រតិបត្តិករទេសចរណ៍ និងភាគីពាក់ព័ន្ធ ពីបញ្ហាផ្លូវខូចជាពិសេសនៅ រដូវវស្សា (ពិសេសជាងនេះគឺការមិនទាន់មានការរៀបចំបែងចែក ផ្លូវថ្មើរជើង ផ្លូវរថយន្ត ផ្លូវសម្រាប់ម៉ូតូ ផ្លូវសម្រាប់ជិះកង់ ផ្លូវសម្រាប់ជនពិការ) រីឯការរៀបចំសួនទេសចរណ៍ និងការបំពាក់សម្បទាទេសចរណ៍តាមទីសាធារណៈពិសេសចំណតរថយន្តនៅមិនទាន់ស្របតាមស្តង់ដាបម្រើឱ្យភ្ញៀវទេសចរនៅឡើយ សម្រាប់ទីក្រុងទេសចរណ៍បេតិកភណ្ឌប្រវត្តិសាស្ត្រដ៏ល្បីល្បាញមួយនេះ។		**សមាសភាពអនុវត្តគម្រោង÷** • កែលម្អ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធ**ផ្លូវក្នុងទីក្រុង**ដោយគិតគួរដល់ផ្លូវទេសចរថ្មើរជើង ផ្លូវសម្រាប់ការបែងចែកការធ្វើដំណើររបស់រថយន្ត ផ្លូវសម្រាប់ម៉ូតូ ផ្លូវសម្រាប់ជិះកង់ ផ្លូវសម្រាប់ជនពិការ ការបំពាក់សម្បទាទេសចរណ៍និងសម្បទាមួយចំនួនដែលបម្រើឱ្យវិស័យទេសចរណ៍សម្រាប់ក្រុងសៀមរាប។ ការកែលម្អនេះស្របតាមផែនការមេ កែលម្អឡើងវិញផ្លូវ៣៨ខ្សែក្នុងក្រុងសៀមរាប របស់គណៈកម្មការអន្តរក្រសួងដើម្បីសិក្សា និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន ៣៨ខ្សែ នៅក្រុងសៀមរាប ខេត្តសៀមរាប។ • **កែលម្អសួនច្បារនៅក្នុងក្រុងសៀមរាប÷** (១). សួនព្រះរាជដំណាក់ទល់មុខ VICTORIA ANGKOR, (២). សួនព្រះអង្គចេកព្រះអង្គចម និង(៣). សួន Inthanin សម្រាប់ការហាត់ប្រាណ។ • **កែលម្អចំណតរថយន្តក្នុងក្រុងសៀមរាប÷** (១). ចំណតរថយន្តអាងក្រពើចាស់ (ចំណតរ៉ឺម៉កកង់បី និងរថយន្តក្រុងខ្នាតតូច), (២). ចំណតរថយន្តអាងក្រពើចាស់ (ចំណតរថយន្តក្រុង), (៣). ចំណតរថយន្តសួនមុខរាជដំណាក់ (មណ្ឌលផ្តល់ព័ត៌មានថ្មីជាប់មាត់ស្ទឹង), (៤). ចំណតរថយន្តសួននាគព័ន្ធផ្លូវឆ្ពោះទៅភ្នំក្រោម (សម្រាប់ទោចក្រយានយន្ត និងរថយន្តធុនតូច) និង(៥). ចំណតរថយន្តបុរីសៀងណាំ។	

	• ស្ថាបនាកំណាត់ផ្លូវអង្គរឃ្យូងយូ (ផ្លូវ ៦0m) ភ្ជាប់ទៅផ្លូវ N. ៦៦ និងបន្តទៅផ្លូវស្រុកនៃឃុំកន្ត្រាំង (ប្រវែងប្រមាណ ៦.៦ km) ដើម្បីភ្ជាប់តំបន់ទេសចរណ៍សៀមរាបថ្មី និងព្រលានយន្តហោះអន្តរជាតិសៀមរាបអង្គរមកក្រុងសៀមរាប។ • ពង្រីក និងកែលម្អផ្លូវដែលមានស្រាប់ ដូចជា ផ្លូវ N.៦៦, ផ្លូវ N.៦៤, ផ្លូវម៉ាឡៃ, ផ្លូវយុទ្ធសាស្ត្រសម្តេចតេជោ (ផ្លូវសាលានគរបាល) ដែលជាបណ្តាញផ្លូវដឹកជញ្ជូនសេដ្ឋកិច្ច និងទេសចរណ៍ដ៏សំខាន់ ផ្សារភ្ជាប់រវាងតំបន់ទេសចរណ៍សៀមរាបថ្មី ព្រលានយន្តហោះអន្តរជាតិសៀមរាបអង្គរ មកក្រុងសៀមរាប បន្ទាយស្រី ភ្នំគូលែន អន្លង់វែង ចុងស្រងាំ (ព្រំដែនថៃ) និងផ្លូវជាតិលេខ ៦ ដែលគួរតែពង្រីកទទឹងផ្លូវ រួមទាំងបំពាក់សម្បទាទ្រទ្រង់ ដូចជា អំពូលបំភ្លឺផ្លូវ ដាំដើមឈើអមតាមដងផ្លូវជាដើម • ពង្រីក និងកែលម្អទទឹងផ្លូវស្រុកដែលមានស្រាប់ ទៅតំបន់ទេសចរណ៍ប្រាសាទបន្ទាយស្រី ចម្ងាយ ៤គម ចាប់ពីចំណុចប្រសព្វរង្វង់មូលភ្នំគូលែន • ពង្រីក និងកែលម្អទទឹងផ្លូវស្រុកដែលមានស្រាប់ទៅតំបន់ទេសចរណ៍សៀមរាបថ្មី ចម្ងាយ ២៥គម ចាប់ពីចំណុចប្រសព្វផ្លូវ N.6 ត្រង់ផ្សារអង្គ្រងនៃភូមិអង្គ្រង រហូតទៅដល់ជើងភ្នំគូលែន • ពង្រីក និងកែលម្អទទឹងផ្លូវស្រុកដែលមានស្រាប់ទៅតំបន់ទេសចរណ៍បឹងទន្លេសាប រួមមាន÷ ផ្លូវ N.63 ទៅតំបន់ទេសចរណ៍ភ្នំក្រោមនិងកំពង់ផែចុងឃ្នាស ចម្ងាយ ១៧គម ចាប់ពីក្រុងសៀមរាប, ផ្លូវទៅតំបន់ទេសចរណ៍កំពង់ផែកំពង់ភ្នក ចម្ងាយ ១៦គម ចាប់ពីចំណុចប្រសព្វផ្លូវ N.6, ផ្លូវទៅតំបន់ទេសចរណ៍កំពង់ផែកំពង់ឃ្លាំង ចម្ងាយ ១៦គម ចាប់ពីចំណុចប្រសព្វផ្លូវ N.6 • ពង្រីក និងកែលម្អផ្លូវស្រុកដែលមានស្រាប់ទៅតំបន់ទេសចរណ៍ភ្នំគូលែន ចម្ងាយ ១៦គម ចាប់ពីចំណុចប្រសព្វរង្វង់មូលភ្នំគូលែន។
គោលបំណង÷ គម្រោងការកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងសៀមរាប មានគោលបំណង បង្កើត និងបង្កើនភាពទាក់ទាញទេសចរណ៍ទីក្រុងតាមរយៈ÷ • កែលម្អសោភណភាព និងលើកកម្ពស់សោភណភាពតាមដងផ្លូវ សួនច្បារ និងចំណតរថយន្ត • បង្កើតសម្បទាទេសចរណ៍តាមដងផ្លូវ • សម្រួលការធ្វើដំណើររបស់ភ្ញៀវទេសចរថ្មើរជើង • បង្កើតសកម្មភាពទេសចរណ៍ និងពាណិជ្ជកម្មនៅតាមដងផ្លូវ	**លទ្ធផលនៃគម្រោង÷** • ផ្លូវក្នុងក្រុងសៀមរាបមានលក្ខណៈប្រសើរឡើង និងមានលក្ខណៈស្តង់ដាធៀបនៅក្នុងតំបន់ និងពិភពលោក • កែលម្អសួនក្នុងក្រុងសៀមរាបឱ្យកាន់តែមានភាពទាក់ទាញ • កែលម្អចំណតរថយន្តក្នុងក្រុងសៀមរាបដែលឥតភ្ជាប់ពីតំបន់ឬខេត្តជាគោលដៅទេសចរណ៍ផ្សេងទៀត • តាមរយៈការកែលម្អនេះនឹងអាចទាក់ទាញភ្ញៀវទេសចរមកកម្សាន្តកាន់តែច្រើន និងអាចពន្យារពេលស្នាក់នៅរបស់ភ្ញៀវទេសចរឱ្យកាន់តែច្រើនបន្ថែមទៀត • លើកកម្ពស់សោភណភាព បរិស្ថានស្អាត នៅក្រុងសៀមរាប • រក្សាសណ្តាប់ធ្នាប់ក្នុងទីក្រុង។

• រៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវទេសចរណ៍ សួនច្បារ និងចំណតរថយន្ត • កែលម្អសោភណភាពតាមសួនច្បារក្នុងទីក្រុង។		
ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷ គម្រោងនេះ មានផលប៉ះពាល់ដល់បរិស្ថាន និងសង្គមតិចតួចបំផុត។	**របៀបវារៈ / រយៈពេល÷** អនុវត្តគម្រោងដោយប្រើ រយៈពេលខ្លី	**ថ្លៃដើមនៃគម្រោង÷** គម្រោងនេះ គ្រោងប្រើប្រាស់ថវិកា ប្រមាណ (១៥០លាន ដុល្លារអាមេរិក) និង២០លានដុល្លារទៀត (សម្រាប់ការកែលម្អ សួនច្បារ និងចំណតរថយន្ត)។
គម្រោងពាក់ព័ន្ធផ្សេងទៀត÷ បច្ចុប្បន្នរដ្ឋបាលខេត្តសៀមរាបក៏បានកំពុងកែលម្អ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវក្នុងក្រុងសៀមរាប និងសួនច្បារផងដែរ។		

សកម្មភាពអាទិភាពទី៨÷ គម្រោងស្តីពី "ការបង្កើតតំបន់ទ្រនាប់" (សៀមរាបខាងកើត)

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ ការអភិវឌ្ឍទេសចរណ៍ក្រុងសៀមរាប

ល.រ	ចំណងជើងគម្រោង	ក្រុមទទួលបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.៨	ការបង្កើតតំបន់ទ្រនាប់ (សៀមរាបខាងកើត-Siem Reap East)	ភ្ញៀវទេសចរ ប្រជាពលរដ្ឋ ប្រតិបត្តិករទេសចរណ៍	វិស័យឯកជន	អាទិភាព ២ និង ៣

ទីតាំងគម្រោង	ភ្នាក់ងារអនុវត្តគម្រោង	**វិធីសាស្ត្រនៃការអនុវត្ត÷**
ក្រុងសៀមរាប (ស្ថិតនៅប៉ែកខាងកើត)	• គណៈកម្មាធិជាតិអភិវឌ្ឍន៍ទេសចរណ៍ • ផ្នែកឯកជន	ការបង្កើតតំបន់ទ្រនាប់មានឈ្មោះថាសៀមរាបខាងកើត-Siem Reap East នេះត្រូវតែជាក្រុងទេសចរណ៍ទ្រនាប់ទំនើបឆ្លាត ប៉ុន្តែត្រូវមានការគិតគូរបរិស្ថាន និងវប្បធម៌ខ្ពស់។ ដូច្នេះត្រូវមានប្តង់ស្ថាបត្យកម្ម និងប្តង់អភិវឌ្ឍលម្អិតមួយដោយឡែកដែលត្រូវសម្រេចដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាលដោយឡែក។

សារវតារ÷

ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍទេសចរណ៍ខេត្តសៀមរាបជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព លំដាប់ពិភពលោក និងផ្តល់ជាការចងចាំដល់ភ្ញៀវទេសចរក្រៅពីការគិតគូរអំពីភាពទាក់ទាញនៃតំបន់បេតិកភណ្ឌប្រាង្គប្រាសាទអង្គរវត្ត និងតំបន់កណ្តាលនៃក្រុងសៀមរាប។ គួរពិចារណាលើការពង្រីកការអភិវឌ្ឍក្រុងសៀមរាបទៅកាន់តំបន់ទ្រនាប់។ ដើម្បីលើកកម្ពស់ក្រុងសៀមរាបនេះឱ្យក្លាយជាគោលដៅទេសចរណ៍ទីក្រុងបេតិកភណ្ឌប្រវត្តិសាស្ត្រ ត្រូវបង្កើតឱ្យមានតំបន់ទ្រនាប់មួយ ដើម្បីកាត់បន្ថយសម្ពាធនៃការអភិវឌ្ឍក្នុងតំបន់កណ្តាលនៃក្រុងសៀមរាប។

សមាសភាពអនុវត្តគម្រោង÷

អភិវឌ្ឍតំបន់ទ្រនាប់ "សៀមរាបខាងកើត" ត្រូវមានហេដ្ឋារចនាសម្ព័ន្ធ ដូចខាងក្រោម÷

- បង្កើតផលិតផលទេសចរណ៍បែបធុរកិច្ចក្នុងវិស័យទេសចរណ៍ម៉ាយ
- ពង្រីកផលិតផលទេសចរណ៍ប្រកបដោយភាពច្នៃប្រឌិតបន្ថែម
- អភិវឌ្ឍផ្នែកមួយចំនួននៅក្រុងសៀមរាបខាងកើត ឱ្យក្លាយជាកន្លែងសម្រាប់ទេសចរយុវជនផ្សារភ្ជាប់នឹងការបណ្តុះបណ្តាល និងអប់រំកម្រិតខ្ពស់
- បង្កើតឱ្យមានតំបន់លំនៅឋានសម្រាប់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរអន្តរជាតិសម្រាប់ប្រភេទផ្ទះទីពីរ។
- បង្កើតឧទ្យានបៃតងផ្សារភ្ជាប់នឹងផ្លូវបុរាណ "ផ្លូវបុរាណអង្គរ"
- បង្កើតឱ្យមានមជ្ឈមណ្ឌលពិព័រណ៍កម្រិតអន្តរជាតិមួយ។

គោលបំណង÷

ដើម្បីប្រែក្លាយក្រុងសៀមរាបជា "ទីក្រុងដែលរស់រវើកជាងគេនៅអាស៊ីអាគ្នេយ៍" និងដើម្បីឆ្លើយតប នឹងចក្ខុវិស័យនៃកំណើននៃភ្ញៀវទេសចរឆ្ពោះទៅឆ្នាំ (២០៣៥) ប្រកបដោយគុណភាព និរន្តរភាព និងការទទួលខុសត្រូវ។

លទ្ធផលនៃគម្រោង÷

ទទួលបានតំបន់ទេសចរណ៍ទ្រនាប់មួយដែលទំនើបឆ្លាតស្របតាមទិសដៅនៃការអភិវឌ្ឍទីក្រុងបែបឆ្លាត។

ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷ គម្រោងនេះ ត្រូវមានការសិក្សា និងវាយតម្លៃផលប៉ះពាល់បរិស្ថាន-សង្គម។	រយៀបវារៈ/រយៈពេល÷ អនុវត្តគម្រោងដោយប្រើរយៈពេល១០-១៥ឆ្នាំ (២០២១-២០៣៥) ក្រោមការត្រួតពិនិត្យរបស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍, រដ្ឋបាលខេត្តសៀមរាប ក្រសួងទេសចរណ៍ និងអាជ្ញាធរជាតិអប្សរា។	ថ្លៃដើមនៃគម្រោង÷ គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ ៥០០-៧០០លានដុល្លារអាមេរិក។
ហេតុផល÷ ដើម្បីធ្វើឱ្យខេត្តសៀមរាបកាន់តែមានភាពទាក់ទាញទេសចរណ៍ គួរតែមានការគិតគូរធ្វើយ៉ាងណាកុំឱ្យការអភិវឌ្ឍក្រុងសៀមរាបទទួលរងសម្ពាធពីការអភិវឌ្ឍក្នុងរយៈពេលមធ្យម និងវែង ពិសេសតំបន់កណ្តាលនៃក្រុងសៀមរាបតែម្តង។ ដូច្នេះ ក្រុងសៀមរាបចាំបាច់ត្រូវពង្រីកទៅកាន់តំបន់ទ្រនាប់។ ការពង្រីកទៅកាន់តំបន់ទ្រនាប់ ដោយបង្កើតជាតំបន់ទ្រនាប់បែបទំនើបមួយស្របតាមគោលការណ៍និរន្តរភាព និងកិច្ចអភិរក្សរបស់គណៈកម្មការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ (ICC-Angkor)។ បច្ចុប្បន្នក្រុងសៀមរាបមាន(១)-ព្រំប្រទល់នៅប៉ែកខាងជើងជាមួយនឹងតំបន់ការពារអប្សរា ១ និង ២ ដែលជាតំបន់នគរូបនីយកម្មត្រូវបានរឹតបន្តឹងក្នុងលក្ខណសម្បត្តិជាតំបន់បេតិកភណ្ឌ, (២)- ព្រំប្រទល់ប៉ែកខាងលិចជាប់ជាមួយនឹងតំបន់មានសក្តានុពលកសិកម្ម ដែលទទួលបានការផ្គត់ផ្គង់ទឹកពីបារាយណ៍ណ៍ខាងលិច និង(៣)- ភាគខាងត្បូងនៃតំបន់ទីក្រុង គឺជាតំបន់ជនបទដែលតភ្ជាប់ទៅនឹងជម្រាលវាលស្មៅ ភ្នំក្រោម និងតំបន់ជន់លិចទឹកយូរអង្វែងដែលស្ថិតនៅជុំវិញបឹងទន្លេសាប។ ដូច្នេះ ទិសដៅនៃការពង្រីកតំបន់ទ្រនាប់នេះនឹងឆ្ពោះទៅកាន់ “ទិសខាងកើត” តាមបណ្តោយផ្លូវ ៦០ ម៉ែត្រ។ គម្រោងសៀមរាបខាងកើត គួរពិចារណារៀបចំឡើងលើផ្ទៃដីទំហំ ២០០-៣០០ ហិចតា និងត្រូវតែជាទីក្រុងបែបទំនើបឆ្លាត និងបៃតងស្របតាមទស្សនាទាន “អភិវឌ្ឍដើម្បីអភិរក្ស អភិរក្សដើម្បីអភិវឌ្ឍ”។		
គម្រោងពាក់ព័ន្ធផ្សេងទៀត÷ មិនទាន់មានការអភិវឌ្ឍតំបន់ទ្រនាប់នៅខេត្តសៀមរាបនៅឡើយ។		

សកម្មភាពអាទិភាពទី៩÷ គម្រោងស្តីពី "ការអភិវឌ្ឍកំពង់ផែទេសចរណ៍ និងសម្បទាទេសចរណ៍នៅភ្នំក្រោម (ចុងឃ្នាស)"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ តំបន់ទេសចរណ៍ទន្លេសាប

ល.រ	ចំណងជើងគម្រោង		ក្រុមទទួលបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.៩	ការអភិវឌ្ឍផែទេសចរណ៍ និងសម្បទាទេសចរណ៍នៅភ្នំក្រោម		សហគមន៍ទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ និងភ្ញៀវទេសចរ	រដ្ឋ-ឯកជន	អាទិភាព ១ និង ២
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**វិធីសាស្ត្រនៃការអនុវត្ត÷**		
តំបន់បឹងទន្លេសាបខេត្តសៀមរាប		• គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ • រដ្ឋបាលខេត្តសៀមរាប • DMO	• រៀបចំកំពង់ផែទេសចរណ៍ចុងឃ្នាសឱ្យស្របតាមស្តង់ដាកំពង់ផែទេសចរណ៍ (ការអភិវឌ្ឍកំពង់ផែទសចរណ៍នេះត្រូវមានប្តង់មេអភិវឌ្ឍអមជាមួយប្តង់ស្ថាបត្យកម្មលម្អិត) • បំពាក់ឱ្យមានសម្បទាទេសចរណ៍គាំទ្រដល់កំពង់ផែទេសចរណ៍នេះ ពិសេសរៀបចំឱ្យមានការសម្រាកលំហែភ្ញៀវ និងហ្វូបចុក។ល។ • បន្ថែមនូវសេវាកម្មទេសចរណ៍ ត្រូវមានផលិតផលទេសចរណ៍ថ្មីៗ (ក្នុងនោះការបង្កើតឱ្យមានសារមន្ទីរបឹងទន្លេសាប)		
សារវាៈ÷ បឹងទន្លេសាប ជាបឹងមួយក្នុងចំណោមបឹងទឹកសាបដ៏ធំបំផុតនៅលើពិភពលោកដែលចំណាយពេលធ្វើដំណើរប្រមាណ ២៥នាទី (ចម្ងាយ ១៥ Km) **នៅភាគខាងត្បូងនៃខេត្តសៀមរាប។** នៅបឹងទន្លេសាប មានសេវាទូកដឹកភ្ញៀវទេសចរខ្នាតតូចដែលធ្វើសកម្មភាពដោយប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ និងទស្សនាភូមិនេសាទបណ្តែតទឹក។ តំបន់បឹងទន្លេសាបនេះមានសក្តានុពលអេកូទេសចរណ៍ធម្មជាតិ និងអេកូទេសចរណ៍ខ្ពស់។ បើគិតតាមទស្សនៈ **"អេកូទេសចរណ៍"** តំបន់នេះអាចមានមូលដ្ឋានអភិវឌ្ឍ **"ភូមិទេសចរណ៍ធម្មជាតិ"**។ ចំណុចដ៏ល្អមួយសម្រាប់ទស្សនាទេសភាពបឹងទន្លេសាប និងតំបន់ជុំវិញ គឺចំណុចកំពូលនៃភ្នំក្រោម។ លើសពីនេះទៅទៀត លើកំពូលភ្នំក្រោម មានប្រាសាទបុរាណដ៏ទាក់ទាញមួយ គឺជាតំបន់ដែលមានប្រវត្តិនៃការសាងសង់ទីតាំង និងរចនាបថល្អឯក។ ដើម្បីលើកកម្ពស់សោភណភាព និងបង្កើនភាពទាក់ទាញបន្ថែម ផែនការមេបានស្នើឡើងនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងបង្កើតសកម្មភាពទេសចរថ្មីៗដើម្បីប្រែក្លាយតំបន់បឹងទន្លេសាបជាតំបន់ទេសចរណ៍ប្រកបដោយនិរន្តរភាព។			**សមាសភាពអនុវត្តគម្រោង÷** • កែលម្អផែទូកទេសចរណ៍ ឱ្យមានភាពងាយស្រួលសម្រាប់ភ្ញៀវទេសចរ និងរៀនចំសណ្តាប់ធ្នាប់នៃទូកស្របតាមស្តង់ដា • បង្កើតស្ពានច្បារ (តំបន់បៃតង) នៅកំពង់ផែចុងឃ្នាស • រៀបចំអគាររដ្ឋបាលសម្រាប់ធ្វើការងារ និងគ្រប់គ្រងតំបន់ផែទេសចរណ៍ • បង្កើតភោជនីយដ្ឋាន បម្រើឱ្យភ្ញៀវទេសចរ (កម្រិតខ្ពស់ប្រណីត) • បង្កើតផ្ទះលំហែកម្រិតខ្ពស់ • បង្កើតផ្សារសហគមន៍ (ដើម្បីលក់ផលិតផលក្នុងស្រុក និងផ្សារពេលយប់) • បង្កើតស្ថានីយប្រេងឥន្ធនៈ • បង្កើតសារមន្ទីរទន្លេសាប ប្រើប្រាស់បច្ចេកវិទ្យាទំនើបឌីជីថល (AR; VR) ដែលបញ្ចូលនូវខ្លឹមសារសារមន្ទីរនេសាទ÷ ដោយការនេសាទ គឺជាសកម្មភាពប្រពៃណីរបស់ប្រជាជនខ្មែរតាំងពីសម័យយូរលង់ណាស់មកហើយ ពោលគឺមានន័យថាត្រីជាប្រភពអាហារចម្បង។ ក្នុងន័យនេះ ការបង្ហាញអំពីបច្ចេកទេសនេសាទផ្សេងៗគ្នា អាចផ្តល់បទពិសោធន៍ថ្មីៗសម្រាប់ភ្ញៀវទេសចរអន្តរជាតិ។ល។ • បង្កើតមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍		

<table>
<tr><td></td><td colspan="2">• បង្កើតអាហារដ្ឋាន (បែបវិថីម្ហូបអាហារ-Food street) ហាងកាហ្វេ
• បង្កើតចំណតរ៉ឺម៉កកង់បី ម៉ូតូ កង់, ចំណតរថយន្តលក្ខណៈគ្រួសារ និងចំណតរថយន្តក្រុង។
• ពង្រឹងសេវាកម្មទូកទេសចរណ៍។ល។</td></tr>
<tr><td>គោលបំណង÷
ការកែលម្អកំពង់ផែទេសចរណ៍ភ្នំក្រោម (ចុងឃ្នាស) មានគោលបំណង÷
• ធ្វើពិពិធកម្មផលិតផលទេសចរណ៍ដើម្បីបង្កើនរយៈពេលស្នាក់នៅយូរជាងមុន (យ៉ាងហោចបន្ថែមឱ្យបាន ១ ថ្ងៃ ធៀបក្នុងពេលបច្ចុប្បន្ន)
• លើកកម្ពស់ទន្លេសាបជាតំបន់ទេសចរណ៍ធម្មជាតិដ៏ទាក់ទាញ
• គ្រប់គ្រងរំហួរទេសចរណ៍ក្នុងតំបន់ទន្លេសាបដោយប្រែក្លាយជាមេដែកទាញទៅកាន់គោលដៅទេសចរណ៍/សហគមន៍ទេសចរណ៍ផ្សេងៗទៀតនៅក្នុងតំបន់បឹងទន្លេសាប
• អភិវឌ្ឍទេសចរណ៍ប្រកបដោយការទទួលខុសត្រូវដែលធានាបាននូវនិរន្តរភាពលើសកម្មភាពទេសចរណ៍។</td><td colspan="2">លទ្ធផលនៃគម្រោង÷
• អាចពន្យារការស្នាក់នៅរបស់ភ្ញៀវទេសចរ តាមរយៈការបង្កើតខ្សែទស្សនាចរផ្លូវទឹក ដោយប្រើប្រាស់បឹងទន្លេសាប (កំពង់ផែទេសចរណ៍ចុងឃ្នាស) ជាខ្សែតភ្ជាប់តំបន់ទេសចរណ៍ក្នុងតំបន់ទន្លេសាប
• បង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋមូលដ្ឋាន តាមរយៈការប្រកបមុខរបរបម្រើឱ្យភ្ញៀវទេសចរ
• តាមរយៈពិពិធកម្មទេសចរណ៍ថ្មីៗទាំងនេះនឹងអាចទាក់ទាញភ្ញៀវទេសចរមកកម្សាន្តកាន់តែច្រើន
• ប្រែក្លាយតំបន់នេះជាតំបន់ទេសចរណ៍ប្រកបដោយនិរន្តរភាព
• ចូលរួមចំណែកក្នុងការអភិរក្សជីវៈចម្រុះប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប
• ធានាបាននូវភាពស្អាត អនាម័យ កាត់បន្ថយការបំពុលទឹក
• ទទួលបានការរៀបចំផែទេសចរណ៍ដែលមានរចនាបថ និងភាពតង់វង្យយូរអង្វែង
• ភាពចម្រុះនៃសកម្មភាពទេសចរណ៍</td></tr>
<tr><td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះ មិនមានផលប៉ះពាល់ដល់ផ្នែកបរិស្ថាន និងសង្គម</td><td rowspan="3">របៀបវារៈ / រយៈពេល÷
រយៈពេលខ្លី និងមធ្យម (២០២១-២០២៤) ដោយគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ និងរដ្ឋបាលខេត្តសៀមរាបនិងវិនិយោគិនឯកជន។</td><td rowspan="3">ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ ១០-១៥ លានដុល្លារអាមេរិក។</td></tr>
<tr><td>ហេតុផល÷
ខេត្តសៀមរាបមានចំណុចពិសេសចាំបាច់ត្រូវធ្វើការអភិវឌ្ឍទេសចរណ៍ថ្មីៗ ដោយត្រូវគិតគូរទាំងការផ្គត់ផ្គង់ និងភាពទាក់ទាញនៃផលិតផលទេសចរណ៍ប្រកបដោយគុណភាព ដើម្បីបំពេញសេចក្តីត្រូវការរបស់ភ្ញៀវទេសចរទៅថ្ងៃអនាគត។ តំបន់ទន្លេសាប គឺជាសក្តានុពលទេសចរណ៍បែបធម្មជាតិ និងអេកូទេសចរណ៍ដ៏ទាក់ទាញ។ តំបន់ភ្នំក្រោម (ចុងឃ្នាស) ជាចំនុចគន្លឹះក្នុងការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាពនៅក្នុងតំបន់ទន្លេសាប។</td></tr>
<tr><td>គម្រោងពាក់ព័ន្ធផ្សេងទៀត÷
បច្ចុប្បន្នក្រុមហ៊ុន ស៊ូ ជីង បានទទួលសិទ្ធិវិនិយោគតំបន់ចុងឃ្នាស។</td></tr>
</table>

សកម្មភាពអាទិភាពទី១០÷ គម្រោងស្តីពី "ការបង្កើតតំបន់ប្រមូលផ្តុំមណ្ឌលកម្សាន្តមនុស្សពេញវ័យខេត្តសៀមរាប "បុរីកម្សាន្តខេត្តសៀមរាប"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ តំបន់ទេសចរណ៍ក្នុងក្រុងសៀមរាប

ល.រ	ចំណងជើងគម្រោង		ក្រុមទទួលបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.១០	បង្កើត "បុរីកម្សាន្តខេត្តសៀមរាប"		ភ្ញៀវទេសចរ ប្រតិបត្តិករទេសចរណ៍ ប្រជាពលរដ្ឋ	ឯកជន	អាទិភាព ១ និង ២
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**វិធីសាស្ត្រនៃការអនុវត្ត÷** • កំណត់ និងវិភាគទិន្នន័យស្ថិតិមណ្ឌលកម្សាន្តដែលមានស្រាប់ និងតម្រូវការគម្រោងថ្មី (ខារ៉ាអូខេ ឌីស្កូតែក រង្គសាលបៀហ្គាដិន) និងត្រូវកំណត់រយៈពេលនៃការផ្លាស់ប្តូរទៅទីតាំងថ្មីនេះតាមដំណាក់កាលនីមួយៗ • កំណត់ និងធ្វើការវិភាគលើស្ថានភាពទីតាំងភូមិសាស្ត្រថ្មី ដោយផ្អែកលើកត្តាសេដ្ឋកិច្ច បរិស្ថាន វប្បធម៌ និងភាពអាចចូលទៅដល់ (ដូចមានកំណត់ក្នុងឯកសារផែនការមេ) • រៀបចំតំបន់ប្រមូលផ្តុំ គម្រោងប្លង់ ការរចនា កំណត់ប្រភេទដែលត្រូវមាន និងប្រភេទសម្បទាដែលត្រូវបំពាក់ និងការណែនាំផ្សេងៗទៀតនៅក្នុងតំបន់ប្រមូលផ្តុំថ្មីនោះ • រៀបចំប្លង់អភិវឌ្ឍតំបន់កម្សាន្តខេត្តសៀមរាប។	
ក្រុងសៀមរាប		• ក្រសួងទេសចរណ៍ • រដ្ឋបាលខេត្តសៀមរាប • DMO's			
សារវន្ត÷ បញ្ហាការបំពុលដោយសំឡេងក្រុងសៀមរាប (ពីមណ្ឌលកម្សាន្តមួយចំនួនពិសេសខារ៉ាអូខេ) ជាប្រធានបទមួយដែលតែងតែលើកឡើងពីប្រជាពលរដ្ឋ ភ្ញៀវទេសចរ និងអាជីវកម្មសណ្ឋាគារ ឬអ្នកទទួលរងផលប៉ះពាល់នឹងការរំខានដោយសំឡេងនេះចេញពីមណ្ឌលកម្សាន្តមនុស្សពេញវ័យ(មានទីតាំងខ្លះនៅជិតវត្តអារាម សណ្ឋាគារ កន្លែងស្នាក់នៅរបស់ប្រជាពលរដ្ឋ) ជាដើម។ ដោយឡែកមណ្ឌលកម្សាន្តមនុស្សពេញវ័យនេះក៏បានបម្រើសេវាដល់ប្រភេទភ្ញៀវទេសចរដែលចូលចិត្តការ កម្សាន្តនាពេលរាត្រីបន្ទាប់ពីទស្សនាអង្គរ និងគោលដៅទេសចរណ៍នានានៅក្នុងទីក្រុងសៀមរាបផងដែរ។ ដូច្នេះ ដើម្បីរក្សាឱ្យបាននៅវត្ថុបំណងទាំងពីរនេះ ការរៀបចំឱ្យមានតំបន់ប្រមូលផ្តុំទីតាំងមណ្ឌលកម្សាន្តនេះគឺផ្តល់ភាពងាយស្រួល និងផ្តល់ជម្រើសថ្មី		**សមាសភាពអនុវត្តគម្រោង÷** បង្កើតតំបន់ប្រមូលផ្តុំ ទីតាំងមណ្ឌលកម្សាន្តមនុស្សពេញវ័យស្ថិតនៅភូមិជ្រាវ សង្កាត់ជ្រាវ ក្រុងសៀមរាប (ដូចមានកំណត់អ័ក្សអរដោនេចែងក្នុងផែនការមេ)។		

<table>
<tr><td colspan="2">សម្រាប់ប្រភេទភ្ញៀវទេសចរ និងក៏ដូចជាអាចរក្សានូវភាពស្ងប់ស្ងាត់នៃទីក្រុងសៀមរាបស័ក្តិសមជាទីក្រុងបេតិកភណ្ឌ និងជាគោលដៅទេសចរណ៍ប្រកបគុណភាព។</td><td></td></tr>
<tr><td>គោលបំណង÷
• បង្កើតតំបន់ “បុរីកម្សាន្តរាត្រីខេត្តសៀមរាប” នេះ ក្នុងគោលបំណងកាត់បន្ថយ ផលប៉ះពាល់ជាអវិជ្ជមានទាំងឡាយដែលបង្កឡើងពីមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ពិសេសការបំពុលសំឡេង ឬការរំខានដោយសំឡេង ស្របតាមស្មារតីនៃអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ស្តីពី “ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ” ។
• អាចជួយបង្កើតទីតាំងផលិតផលទេសចរណ៍ថ្មីមួយ និងបង្កើនសកម្មភាពសេដ្ឋកិច្ចពេលរាត្រីសម្រាប់ខេត្តសៀមរាប។</td><td>លទ្ធផលនៃគម្រោង÷
លទ្ធផលនៃគម្រោងគឺធ្វើឱ្យ÷
• មានតំបន់ប្រមូលផ្តុំមណ្ឌលកម្សាន្តមនុស្សពេញវ័យដែលមានផលប៉ះពាល់អវិជ្ជមានកម្រិតទាប
• ទាក់ទាញប្រភេទភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលចិត្តការកម្សាន្តនាពេលរាត្រី
• បង្កើតការងារ និងបង្កើនចំណូលសេដ្ឋកិច្ចពេលរាត្រីបន្ថែម
• កាត់បន្ថយការបំពុលដោយសំឡេងក្នុងក្រុងសៀមរាប។</td></tr>
<tr><td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះ មិនមានផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។</td><td rowspan="2">របៀបវារៈ / រយៈពេល÷
អនុវត្តរយៈពេលខ្លី និងមធ្យម ដោយរដ្ឋបាលខេត្តសៀមរាប និងក្រសួងទេសចរណ៍សហការជាមួយផ្នែកឯកជន។</td><td rowspan="2">ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ៥លានដុល្លារអាមេរិក។</td></tr>
<tr><td>គម្រោងពាក់ព័ន្ធផ្សេងទៀត÷
បច្ចុប្បន្នមានមណ្ឌលកម្សាន្តមនុស្សពេញវ័យដូចជាខាវ៉ាអូខេ ឌីស្កូតែក បៀរហ្គាដិន រង្គសាលចំនួន៤២ ស្ថិតក្នុងក្រុងសៀមរាប និងមានផ្សារាត្រីមួយស្ថិតនៅកណ្តាលក្រុងសៀមរាប។</td></tr>
</table>

សកម្មភាពអាទិភាពលើ១៖ គម្រោងស្តីពី "ការបង្កើតតំបន់ទេសចរណ៍សៀមរាបថ្មី"

តារាងសង្ខេបគម្រោង

ផ្នែក÷ តំបន់ទេសចរណ៍អាទិភាព (ក្រៅពីអង្គរ)

ល.រ	ចំណងជើងគម្រោង		ក្រុមឧទ្ទិលបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.១១	គម្រោងបង្កើតតំបន់ទេសចរណ៍សៀមរាបថ្មី		ប្រជាពលរដ្ឋមូលដ្ឋាន វិស័យសាធារណៈ និងអាជីវកម្មក្នុងវិស័យទេសចរណ៍ខេត្តសៀមរាប	រដ្ឋ-ឯកជន	អាទិភាព ២ និង ៣
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**សមាសធាតុនៃគម្រោង÷** • ការជ្រើសរើសទីតាំងសម្រាប់ការរៀបចំតំបន់ទេសចរណ៍សៀមរាបថ្មី • ការរៀបចំប្លង់ទិដ្ឋភាពទូទៅនៃគម្រោង • ប្លង់ទីតាំង (ដែលស្ថិតនៅក្នុងតំបន់ប្រសព្វរវាងស្រុកចំនួន៣ រួមមាន ឃុំបល្ល័ង្ក និងឃុំចាន់ស នៃស្រុកប្រាសាទបាគង ឃុំខ្នារពោធិ៍នៃស្រុកសូទ្រនិគម និងឃុំត្បែងនៃស្រុកបន្ទាយស្រី ដែលប្រមូលផ្តុំដោយភូមិចំនួន ៥ ដូចជា ភូមិក្រពើ ភូមិបុស្សធំ ភូមិសំរោង ភូមិថ្មដល់ និងភូមិចាន់សខាងជើង • ប្លង់ក្រុង • ផែនការអនុវត្ត • ផែនការប្រតិបត្តិការ និងគ្រប់គ្រង ចំណុចទាំងអស់នេះត្រូវលម្អិតក្នុងផែនការមេអភិវឌ្ឍន៍តំបន់ទេសចរណ៍សៀមរាបថ្មី ដែលត្រូវពិនិត្យ និងសម្រេចដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា។	
ខេត្តសៀមរាប		វិស័យឯកជន (ភាពជាដៃគូ រដ្ឋ-ឯកជន)			
សារវៈ÷ ខេត្តសៀមរាបមានតម្រូវការក្នុងការធ្វើពិពិធកម្មទេសចរណ៍ ប៉ុន្តែការអភិវឌ្ឍទេសចរណ៍ថ្មីៗមិនត្រូវជាក់សម្ពាធខ្លាំងពេកលើក្រុងសៀមរាបតែមួយគ្រប់គ្រាន់ទេ។ ដូច្នេះ ចាំបាច់ត្រូវបង្កើតតំបន់ទេសចរណ៍សៀមរាបថ្មី មួយទៀតក្នុងរយៈពេលមធ្យម និងវែង ដើម្បីធានាឱ្យបានការអភិវឌ្ឍទេសចរណ៍ខេត្តសៀមរាបជាគោលដៅទេសចរណ៍ប្រកបគុណភាព។					
គោលបំណង÷ • បង្កើតជម្រើសទេសចរណ៍ថ្មីប្រកបដោយភាពទាក់ទាញសម្រាប់ភ្ញៀវទេសចរអន្តរជាតិ និងភ្ញៀវទេសចរក្នុងស្រុក • ដើម្បីរក្សាលំនឹងនៃការអភិវឌ្ឍ និងអភិរក្សកើតចេញពីការអភិវឌ្ឍទេសចរណ៍នៅខេត្តសៀមរាប ឆ្ពោះទៅឆ្នាំ ២០៣៥ ។ • ពិសេសរក្សាតុល្យភាពនៃការអភិរក្សទេសចរណ៍ក្នុងក្រុងសៀមរាបក្លាយជាតំបន់ទេសចរណ៍ថ្មីមួយទៀតដែលបំពេញបន្ថែម ជាមួយតំបន់សក្តានុពលទេសចរណ៍បច្ចុប្បន្ន។			**លទ្ធផលនៃគម្រោង÷** ការអភិវឌ្ឍតំបន់ទេសចរណ៍សៀមរាបថ្មី នឹងផ្តល់នូវលទ្ធផល០២ ដូចខាងក្រោម÷ • ប្រែក្លាយតំបន់ទេសចរណ៍សៀមរាបថ្មីជា÷ - ទីក្រុងដែលប្រកបដោយបរិស្ថានស្អាត-បៃតងគួរឱ្យចង់រស់នៅដោយមានការគិតគូរលើទស្សនៈរួមមាន÷ **រស់នៅបៃតង អគារបៃតង និងមធ្យោបាយដឹកជញ្ជូនបៃតង** - គឺជាទីក្រុងទំនើប និងឆ្លាត។	

<table>
<tr><td colspan="2"></td><td>• ក្រុងទេសចរណ៍ថ្មីបម្រើឱ្យភ្ញៀវទេសចរលំដាប់ខ្ពស់ និងប្រភេទទេសចរណ៍ផ្ទុះទីពីរនាពេលអនាគត។ ក្នុងនោះនឹងទាក់ទាញបានការវិនិយោគសណ្ឋាគារល្បីៗលំដាប់ខ្ពស់ មានឧទ្យានកម្សាន្តកម្រិតខ្ពស់ ទីលានវាយកូនហ្គោលកម្រិតអន្តរជាតិ សំដៅទេសចរណ៍បែបច្នៃប្រឌិត។ ល ។
• តំបន់ទេសចរណ៍សៀមរាបថ្មីរំពឹងថានឹងដោះស្រាយចំនួន ០២ នាពេលអនាគត ទី១). កំណើនប្រជាសាស្ត្រនៅខេត្តសៀមរាប និងទី២). កំណើនតម្រូវការនៃការស្នាក់នៅ និងកម្សាន្តទេសចរណ៍ និងកំណើនការវិនិយោគទេសចរណ៍នាពេលអនាគត។</td></tr>
<tr><td rowspan="2">ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះ នឹងជ្រើសរើសទីតាំង ដែលនឹងផ្តល់ផលប៉ះពាល់តិចតួចបំផុតដល់សង្គម និងបរិស្ថាន។</td><td rowspan="2">របៀបវារៈ÷ អនុវត្តរយៈពេលមធ្យម និងវែង ដោយ ២០២២÷ ជ្រើសរើសទីតាំង ២០២៣÷ ត្រៀមរៀបចំប្លង់ទីតាំង និងប្លង់លម្អិត ២០២៤÷ ការរៀបចំ និងអនុវត្តផែនការ
២០២៥÷ ស្វែងរកវិនិយោគិន និងអ្នកអភិវឌ្ឍរៀបចំឡើងដោយគណៈកម្មាធិការជាតិអភិវឌ្ឍទេសចរណ៍ និងអភិវឌ្ឍដោយវិនិយោគិន</td><td rowspan="2">ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ៨០០-១០០០លានដុល្លារអាមេរិក។</td></tr>
<tr><td>គម្រោងដែលពាក់ព័ន្ធ÷
គម្រោងអភិវឌ្ឍព្រលានយន្តហោះថ្មីសៀមរាប-អង្គរស្ថិតនៅជុំវិញទីតាំងតំបន់ទេសចរណ៍សៀមរាបថ្មីនេះ។</td></tr>
</table>

សកម្មភាពអាទិភាពលេខ១២÷ គម្រោងស្តីពី ការបង្កើតព្រលានយន្តហោះថ្មីនៅខេត្តសៀមរាប "ព្រលានយន្តហោះអន្តរជាតិសៀមរាប-អង្គរ"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងការគាំទ្រវិស័យទេសចរណ៍នៅខេត្តសៀមរាប

ល.រ	ចំណងជើងគម្រោង		ក្រុមទទួលបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.១២	គម្រោងព្រលានយន្តហោះអន្តរជាតិសៀមរាប-អង្គរ (Siem Reap Angkor International Airport)		ភ្ញៀវទេសចរ ប្រជាពលរដ្ឋមូលដ្ឋាន វិស័យសាធារណៈ និងអាជីវកម្ម ក្នុងវិស័យទេសចរណ៍ខេត្តសៀមរាប	រដ្ឋ-ឯកជន	អាទិភាព ១ , ២ និង ៣
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**វិធីសាស្ត្រនៃការអនុវត្ត÷**		
ស្រុកស្វាយទ្រនិតម ខេត្តសៀមរាប		• រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល • ក្រុមហ៊ុនអាកាសចរណ៍អង្គរអ៊ិនធឺរណែសសីណលអ៊ែរអេនជីនអ៊ិនវេសមែន (Angkor International Airport Investment (Cambodia) Co., Ltd)	អនុវត្តតាមផែនការមេអភិវឌ្ឍព្រលានយន្តហោះថ្មី (Master Plan for Siem Reap Angkor International Airport)		
សារវន្តរ÷ ដោយសារលទ្ធភាព និងសមត្ថភាពព្រលានយន្តហោះសៀមរាបបច្ចុប្បន្ននៅមានកម្រិត និងម្យ៉ាងស្ថិតនៅមិនឆ្ងាយពីទីតាំងប្រាសាទសំខាន់ៗដែរ មិនអាចត្រៀមទទួលស្វាគមន៍ភ្ញៀវទេសចរដូចបានកំណត់ក្នុងចក្ខុវិស័យឆ្នាំ២០៣៥នោះ តម្រូវឱ្យបង្កើតព្រលានយន្តហោះថ្មីមួយទៀត។			**សមាសភាពអនុវត្តគម្រោង÷** • បង្កើតព្រលានយន្តហោះថ្មីក្នុងខេត្តសៀមរាប ឱ្យស្របតាមតម្រូវការ និងរំហួរភ្ញៀវទេសចរ • កសាងហេដ្ឋារចនាសម្ពន្ធ៍ទេសចរណ៍គាំទ្រដល់ប្រតិបត្តិការព្រលានយន្តហោះថ្មី។		
គោលបំណង÷ • ការបង្កើតព្រលានយន្តហោះថ្មីក្នុងខេត្តសៀមរាបមានគោលបំណងបង្កើនការហោះហើរត្រង់ពីបណ្តាប្រទេសគោលដៅ និងលើកកម្ពស់សមត្ថភាពទទួលភ្ញៀវឱ្យកាន់តែប្រសើរជាងមុន និងទាក់ទាញការហោះហើរត្រង់ពីគោលដៅទេសចរណ៍ផ្សេងទៀត។			**លទ្ធផលនៃគម្រោង÷** មានព្រលានយន្តហោះថ្មីដែលមានលទ្ធភាព និងសមត្ថភាពទទួលអ្នកដំណើរច្រើនជាងមុន និងទទួលបានយន្តហោះខ្នាតធំជាងមុន។ ព្រលានយន្តហោះអន្តរជាតិសៀមរាប-អង្គរបានកំណត់គោលដៅជា០៤ ជំហានដូចខាងក្រោម÷ • ជំហានទី១÷គម្រោងមានសមត្ថភាពបត់បែន និងងាយស្រួលក្នុងការពង្រីក នឹងត្រូវគ្រប់គ្រងដោយចំនួន អ្នកដំណើរប្រចាំឆ្នាំ៥លាននាក់ នៅឆ្នាំ០២០។		

<table>
<tr><td colspan="3"></td><td colspan="2">• ជំហានទី២÷គម្រោងមិនមានសមត្ថភាពបត់បែនបាន និងមិនងាយស្រួលក្នុងការពង្រីក នឹងត្រូវគ្រប់គ្រងដោយចំនួនអ្នកដំណើរប្រចាំឆ្នាំ៧លាននាក់ នៅឆ្នាំ២០២៥។
• ជំហានទី៣÷គម្រោងដែលមានសមត្ថភាពមិនអាចបត់បែនបានថេរពិបាកពង្រីកនិងត្រូវគ្រប់គ្រងដោយចំនួន អ្នកដំណើរប្រចាំឆ្នាំ៧លានទៅ១០លាននាក់ នៅឆ្នាំ២០២០
• ជំហានទី៤÷ក្នុងរយៈពេលវែងអាចនឹងទទួលអ្នកដំណើរប្រចាំឆ្នាំមិនតិចជាង២០លាននាក់ នៅឆ្នាំ២០៣៥។ តាមការគ្រោងទុកក្នុងរយៈពេលខ្លី÷គ្រោងទទួលភ្ញៀវទេសចរ៧លាននាក់ក្នុងមួយឆ្នាំ និងរយៈពេលវែង÷ គ្រោងទទួលភ្ញៀវទេសចរ ២០លាននាក់ក្នុងមួយឆ្នាំ។</td></tr>
<tr><td colspan="3">ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះ មិនមានផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។</td><td rowspan="3">របៀបវារៈ / រយៈពេល÷
អនុវត្តរយៈពេលមធ្យម និងវែង។</td><td rowspan="3">ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ៧០០លាន - ១០០០លានដុល្លារអាមេរិក។</td></tr>
<tr><td colspan="3">ហេតុផល÷
ដើម្បីឆ្លើយតបទៅនឹងកំណើនទេសចរណ៍នៅខេត្តសៀមរាបនាពេលអនាគត (បង្កើនលទ្ធភាព និងសមត្ថភាពទទួលអ្នកដំណើរច្រើន និងយន្តហោះខ្នាតធំជាងមុន)។</td></tr>
<tr><td colspan="3">គម្រោងពាក់ព័ន្ធផ្សេងទៀត÷
បច្ចុប្បន្ន ព្រលានយន្តហោះខេត្តសៀមរាប ស្ថិតក្នុងក្រុងសៀមរាបដែលប្រតិបត្តិការដោយក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SSCA) របស់បារាំងនេះ។</td></tr>
</table>

សកម្មភាពអាទិភាពទី១៣÷ គម្រោងស្តីពី "ការអភិវឌ្ឍទេសចរណ៍ដែលធ្វើដំណើរដោយខ្លួនឯង"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ យុទ្ធសាស្ត្រជំរុញការតភ្ជាប់ផ្ទៃក្នុង និងអន្តរជាតិមកកាន់ខេត្តសៀមរាប

ល.រ	ចំណងជើងគម្រោង	ក្រុមទទួលបានផលពីគម្រោង	ប្រភពថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.១៣	ការអភិវឌ្ឍទេសចរណ៍ដែលធ្វើដំណើរដោយខ្លួនឯង	ភ្ញៀវទេសចរ ប្រជាពលរដ្ឋមូលដ្ឋាន វិស័យសាធារណៈ និង អាជីវកម្មក្នុងវិស័យទេសចរណ៍ខេត្តសៀមរាប	រដ្ឋ-ឯកជន	អាទិភាពទី ១ និង ២

ទីតាំងគម្រោង	ភ្នាក់ងារអនុវត្តគម្រោង	**វិធីសាស្ត្រនៃការអនុវត្ត÷** • បង្កើតមជ្ឈមណ្ឌលជំនួយទេសចរណ៍ • សម្រួលការធ្វើដំណើរថយន្តទេសចរណ៍ឆ្លងព្រំដែននៅច្រកទ្វារអន្តរជាតិមកកាន់ខេត្តសៀមរាប • បង្កើតកម្មវិធីទូរស័ព្ទបង្ហាញព័ត៌មាននៃការធ្វើដំណើរសម្រាប់ភ្ញៀវទេសចរអន្តរជាតិមកកាន់ខេត្តសៀមរាបភ្ជាប់ទៅនឹងគោលដៅទេសចរណ៍សំខាន់ៗផ្សេងទៀតក្នុងប្រទេសកម្ពុជាផ្សារភ្ជាប់នឹងប្រព័ន្ធ (GPS) ឬ(Google Map) • បំពាក់ស្លាកសញ្ញាបង្ហាញផ្លូវសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ • កែលម្អផ្លូវទៅតភ្ជាប់ទៅកាន់គោលដៅទេសចរណ៍សំខាន់ៗសម្រាប់ដំណើរទស្សនាកម្សាន្តនេះ • ផ្សព្វផ្សាយ និងធ្វើទីផ្សារទេសចរណ៍ធ្វើដំណើរដោយខ្លួនឯងសម្រាប់ទាំងភ្ញៀវទេសចរក្នុងស្រុក និងភ្ញៀវទេសចរអន្តរជាតិមកពីបណ្តាប្រទេសអាស៊ាន។
ខេត្តសៀមរាប	• ក្រសួងទេសចរណ៍ • ក្រសួងសាធារណការ និង ដឹកជញ្ជូន • រដ្ឋបាលខេត្តសៀមរាប • អគ្គនាយកដ្ឋានអន្តោប្រវេសន៍	

សារវតារ÷

បច្ចុប្បន្ន ភ្ញៀវទេសចរនិយមការធ្វើដំណើរតាមដងផ្លូវផ្សារភ្ជាប់ជាមួយនឹងការកម្សាន្តទេសចរណ៍នៅតាមដងផ្លូវ ដោយភ្ញៀវទេសចរអាចថតរូបលេងកម្សាន្ត និងអាចឈានចូលលេងតំបន់រមណីយដ្ឋាននៅតាមតំបន់គោលដៅបានយ៉ាងសប្បាយរីករាយ។ ម្យ៉ាងទៀតក្នុងនិងក្រោយដំណាក់កាលនៃវិបត្តិជំងឺឆ្លងកូវីដ-១៩និន្នាការនៃការធ្វើដំណើរទេសចរណ៍ដោយខ្លួនឯងរវាងកម្ពុជាជាមួយប្រទេសជិតខាង (ថៃ, វៀតណាម, និងឡាវ) គឺជាយុទ្ធសាស្ត្រទាក់ទាញថ្មីៗ។ ដូច្នេះផែនការមេស្នើឱ្យជំរុញការសម្រួលឱ្យមានការធ្វើដំណើរសម្រាប់ភ្ញៀវទេសចរមកពីប្រទេសជិតខាងពិសេសតាមផ្លូវគោក (ដោយសម្រួលឱ្យប្រើប្រាស់រថយន្តចេញ-ចូល ខេត្តសៀមរាប) អមជាមួយការសម្រួលដល់ទិដ្ឋាការនៃការធ្វើដំណើរដោយអាច

សមាសភាពអនុវត្តគម្រោង÷

- បញ្ចូលការផ្សព្វផ្សាយពីផលិតផលទេសចរណ៍ និងគោលដៅទេសចរណ៍នៅតាមបណ្តោយផ្លូវទេសចរណ៍
- ត្រូវរៀចំឱ្យមានស្ថានីយចំណត តាមបណ្តោយផ្លូវទេសចរ និងផ្លូវជាច្រើនទៀត ពិសេសការភ្ជាប់ពី (ភ្នំពេញ-សៀមរាប) ឬ(សៀមរាប-ប៉ោយប៉ែត) និង/ឬ(សៀមរាប-ព្រះវិហារ-ស្ទឹងត្រែង)។ល។
- បន្តពង្រឹងសុវត្ថិភាពចរាចរណ៍តាមរយៈការត្រួតពិនិត្យបច្ចេកទេស, គោរពតាមស្តង់ដាដឹកជញ្ជូន និងផ្លូវថ្នល់មានស្តង់ដាសុវត្ថិភាព
- ផ្តល់ការសម្រួលដល់ការធ្វើដំណើរទេសចរណ៍÷ ផ្លូវតភ្ជាប់គោលដៅទេសចរណ៍ទាំងអស់ត្រូវមានផ្ការសញ្ញា និងសញ្ញាប្រាប់ទិស
- ពង្រឹងផែនការគ្រប់គ្រងចរាចរណ៍នៅតាមគោលដៅទេសចរណ៍សំខាន់ៗក្នុងខេត្តសៀមរាប ក្នុងនោះត្រូវ÷

<table>
<tr><td>ប្រើប្រាស់ប័ណ្ណឆ្លងកាត់ព្រំដែន និងអាចបើកបររថយន្តដោយខ្លួនឯងស្របតាមបទដ្ឋានគតិយុត្តិជាធរមាន។</td><td colspan="2">• ពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ឱ្យបានត្រឹមត្រូវ និងត្រូវមានការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងខ្លឹមសារនៃការអនុវត្តច្បាប់ចរាចរណ៍ដល់ភ្ញៀវទេសចរ។
• ពង្រឹងកែលម្អចំណតរថយន្តក្នុងក្រុងសៀមរាប។
• សម្រួលនីតិវិធីក្នុងការចេញ-ចូលរថយន្តទេសចរណ៍មកកាន់ខេត្តសៀមរាបឱ្យកាន់តែងាយស្រួល
• គួរសម្រួលឱ្យមាន (បណ្តាចេញ - ចូល) ដើម្បីសម្រួលការធ្វើដំណើរដល់ភ្ញៀវទេសចរជនជាតិ។</td></tr>
<tr><td>គោលបំណង÷
• ដើម្បីបង្កើនភាពទាក់ទាញនៃផ្លូវទេសចរខាងលើនេះ និងក៍ដូចជាដើម្បីទាក់ទាញប្រភេទភ្ញៀវទេសចរដែលបើកបររថយន្តដោយខ្លួនឯងដែលជាផ្នែកមួយនៃយុទ្ធនាការជំរុញចលនាទេសចរណ៍ក្នុងស្រុកអាស៊ាន “Asian for Asian”។
• ជំរុញចលនាទេសចរណ៍ក្នុងស្រុក។</td><td colspan="2">លទ្ធផលនៃគម្រោង÷
• ការតភ្ជាប់បណ្តាញផ្លូវថ្នល់នេះនឹងបម្រើឱ្យយុទ្ធសាស្ត្រគាំទ្រភ្ញៀវទេសចរ ដែលបើកបររថយន្តដោយខ្លួនឯងពីបណ្តាប្រទេសក្នុងតំបន់អាស៊ាន ដែលមានបំណងធ្វើដើរកម្សាន្តតាមផ្លូវដែលមានទេសភាពល្អៗ ដើម្បីភាពរីករាយ និងទស្សនាតាមដងផ្លូវ។ ចលនានេះនឹងជំរុញដល់ចល័តភាពក្នុងតំបន់អាស៊ានគាំទ្រយុទ្ធនាការ (ASEAN FOR ASEAN)
• ការតភ្ជាប់ផ្ទៃក្នុងបានល្អប្រសើរ និងជំរុញចលនាទេសចរណ៍ក្នុងស្រុកឱ្យកាន់តែខ្លាំង និងក៍ដូចជាជំរុញចលនាទេសចរណ៍ក្នុងស្រុកឱ្យកាន់តែខ្លាំង ដែលជាការគាំទ្រដល់ចលនាសេដ្ឋកិច្ចផ្ទៃក្នុងកាន់តែខ្លាំងថែមទៀត។</td></tr>
<tr><td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះ មិនមានផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។</td><td>របៀបវារៈ / រយៈពេល÷
អនុវត្តរយៈពេលខ្លី និងមធ្យម ដោយគណៈកម្មាធិការជាតិអភិវឌ្ឍទេសចរណ៍ និងក្រសួងទេសចរណ៍។</td><td>ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ ១០ លានដុល្លារអាមេរិក។</td></tr>
<tr><td>ហេតុផល÷
បច្ចុប្បន្នខេត្តសៀមរាបមានការតភ្ជាប់ផ្លូវថ្នល់នានាទៅកាន់គោលដៅទេសចរណ៍បានល្អរួចហើយ ដែលជាសក្តានុពលក្នុងការអភិវឌ្ឍទេសចរណ៍ធ្វើដំណើរដោយខ្លួនឯងបានកាន់តែប្រសើរ និងអាចទាក់ទាញភ្ញៀវទេសចរពីប្រទេសជិតខាងក្នុងបណ្តាប្រទេសដែលជាសមាជិកអាស៊ានមកទស្សនាខេត្តសៀមរាបកាន់តែច្រើនថែមទៀត។ ម្យ៉ាងទៀតគម្រោងកែលម្អផ្លូវ ៣៨ខ្សែដែលនឹងធ្វើឱ្យផ្លូវក្នុងក្រុងសៀមរាបនឹងបញ្ចប់នៅចុងឆ្នាំ២០២១ និងបង្កលក្ខណៈសម្រាប់ប្រភេទទេសចរណ៍ធ្វើដំណើរដោយខ្លួនឯង។</td><td colspan="2"></td></tr>
</table>

សកម្មភាពអាទិភាពទី១៤÷ គម្រោងស្តីពី "ការកែលម្អ និងពង្រឹងការអភិវឌ្ឍផលិតផលទេសចរណ៍នៅតំបន់បឹងទន្លេសាប"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ តំបន់បឹងទន្លេសាប

ល.រ	ចំណងជើងគម្រោង	ក្រុមទទួលបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.១៤	គម្រោងកែលម្អ និងពង្រឹងការអភិវឌ្ឍផលិតផលទេសចរណ៍នៅតំបន់បឹងទន្លេសាប"	ភ្ញៀវទេសចរ ប្រជាពលរដ្ឋមូលដ្ឋាន វិស័យសាធារណៈ និងអាជីវកម្មក្នុងវិស័យទេសចរណ៍ខេត្តសៀមរាប	រដ្ឋ និងដៃគូអភិវឌ្ឍ	អាទិភាព ១ និង ២

ទីតាំងគម្រោង	ភ្នាក់ងារអនុវត្តគម្រោង
តំបន់ទន្លេសាប	• ក្រសួងទេសចរណ៍ • ក្រសួងបរិស្ថាន • DMOs

សារវាន្ត÷

ក្នុងខេត្តសៀមរាប បឹងទន្លេសាប និងតំបន់ច្រាំងទន្លេសាប និងតំបន់ជនបទ គឺជាតំបន់សក្តានុពលសម្រាប់ការអភិវឌ្ឍអេកូទេសចរណ៍ និងទេសចរណ៍តាមភូមិ។ ក្រៅពីដំណើរកម្សាន្តលើបឹងទន្លេសាប ទស្សនាភូមិអណ្តែតទឹក និងកសិដ្ឋានចិញ្ចឹមត្រីតំបន់ការពារជម្រកសត្វស្លាបព្រៃកទាល់ត្រូវបានផ្សព្វផ្សាយជាតំបន់អេកូទេសចរណ៍បឹងទន្លេសាបអាចបង្កើតជាសៀគ្វីទេសចរណ៍សហគមន៍ និងទន្លេសាប។

វិធីសាស្ត្រនៃការអនុវត្ត÷

- ការសិក្សាពីលទ្ធភាពនៃការជ្រើសរើសទីតាំងសម្រាប់គម្រោងកែលម្អ (សហគមន៍ទេសចរណ៍ កំពង់ផែចុងឃ្នាស កំពង់ភ្នក កំពង់ឃ្លាំង មេជ្រៃ បឹងពាភាំង (ជ្រាវ) បច្ចុប្បន្ននេះសហគមន៍ទេសចរណ៍វប្បធម៌ និងធម្មជាតិផ្សេងទៀត (ឧ.នៅក្នុងតំបន់ទេសចរណ៍ទី១; តំបន់ទេសចរណ៍ទី២ ; តំបន់ទេសចរណ៍ទី៣; តំបន់ទេសចរណ៍ទី៤ និងតំបន់ទេសចរណ៍ទី៦)
- ការជ្រើសរើស និងពង្រឹងគុណភាពផលិតផលទេសចរណ៍សម្រាប់សហគមន៍ (ឧ.ផ្ទះស្នាក់, សកម្មភាពទេសចរណ៍) នានា។ល។ ពិសេសគម្រោងពង្រឹងគុណភាពបរិស្ថាន ការគ្រប់គ្រងសំណល់រឹង-រាវ ក្នុងសហគមន៍ទេសចរណ៍នៅក្នុងតំបន់ទន្លេសាប
- អភិវឌ្ឍផលិតផល ទេសចរណ៍គាំទ្រដល់សកម្មភាពទេសចរណ៍ក្នុងតំបន់ទន្លេសាប
- ការរចនា និងការស្ថាបនាសម្បទាទេសចរណ៍ចាំបាច់ និងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់
- បណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍សហគមន៍ និងអ្នកគ្រប់គ្រងសហគមន៍ត្រូវបង្កើតឱ្យមាន Site Manager សម្រាប់សហគមន៍ទេសចរណ៍អេកូទេសចរណ៍នីមួយៗ។

គោលបំណងនៃគម្រោង÷

គម្រោងនេះ មានគោលបំណងបង្កើត និងផ្សព្វផ្សាយ សហគមន៍ អេកូទេសចរណ៍ និងទេសចរណ៍វប្បធម៌ ជាផលិតផលទេសចរណ៍បន្ថែមសម្រាប់ទីផ្សារទេសចរណ៍ចម្រុះដែលអាចជួយផ្តល់នូវផលប្រយោជន៍ដល់សេដ្ឋកិច្ច។

- **គម្រោងកែលម្អសហគមន៍ និងអេកូទេសចរណ៍ នៅទន្លេសាប និងតំបន់អាទិភាពផ្សេងទៀត÷**
  - បង្កើតឱ្យមានផែនការមេអភិវឌ្ឍន៍ទេសចរណ៍សម្រាប់សហគមន៍នីមួយៗ
  - រៀបចំផែនការប្រតិបត្តិ និងគ្រប់គ្រងសហគមន៍ទេសចរណ៍
  - ផែនការផ្សព្វផ្សាយ និងរៀបចំទីផ្សារទាក់ទាញភ្ញៀវទេសចរទៅកាន់សហគមន៍ទាំងនោះ។
- **ពង្រឹងការអភិវឌ្ឍផលិតផលទេសចរណ៍តាមទន្លេ (River-Cruise)÷**
  - គាំទ្រឱ្យមានកាណូតទេសចរណ៍ធុនធំបែបប្រណីត (River Cruise) បង្កើតជាកម្មវិធីទស្សនាចរលើបឹងទន្លេសាប (ភ្ជាប់បញ្ចូលគោលដៅទេសចរណ៍សហគមន៍នីមួយៗក្នុងតំបន់បឹងទន្លេសាប)
  - សកម្មភាពកីឡាទេសចរណ៍ ឬព្រឹត្តិការណ៍កីឡាលើទឹក (ស្ថិតនៅផ្នែកណាមួយក្នុងសហគមន៍ក្នុងតំបន់ទន្លេសាប)។

ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷

លទ្ធផលនៃគម្រោង÷

<table>
<tr><td>គម្រោងនេះ នឹងជ្រើសរើសទីតាំង ដែលផ្តល់នូវផលប៉ះពាល់តិចតួចដល់សង្គម និងបរិស្ថាន។</td><td colspan="2">• បង្កើនចំណូលរបស់ប្រជាពលរដ្ឋមូលដ្ឋានសហគមន៍ និងបង្កើតឱកាសការងារកាត់បន្ថយភាពក្រីក្រ
• ពង្រីកតម្លៃរបស់ប្រពៃណី និងវប្បធម៌ក្នុងស្រុក និងរៀបចំហេដ្ឋារចនាសម្ព័ន្ធសម្រាប់សហគមន៍
• ពង្រីកការយល់ដឹងលើការអភិរក្ស ការគ្រប់គ្រង និងការពារបរិស្ថានក្នុងបឹងទន្លេសាបប្រកបដោយចីរភាព។</td></tr>
<tr><td>ហេតុផល÷
រៀបចំការប្តូរមុខរបររបស់ប្រជាពលរដ្ឋមូលដ្ឋានពីការកាប់ព្រៃឈើ សម្លាប់សត្វជាលក្ខណៈតូចៗ ដើម្បីចិញ្ចឹមជីវភាពប្រចាំថ្ងៃ មកប្រកបមុខរបរថ្មីជំនួសវិញ ដែលជាយុទ្ធសាស្ត្រវែងឆ្ងាយសម្រាប់ធានាកិច្ចការពារបរិស្ថាន ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ ការបង្កើតសកម្មភាពទេសចរណ៍ ឬសេវាទេសចរណ៍ ដោយប្រជាពលរដ្ឋសហគមន៍មូលដ្ឋានអាចជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការផ្តល់ និងបង្កើតមុខរបរថ្មីជូនប្រជាពលរដ្ឋមូលដ្ឋាន កាត់បន្ថយចំណាកស្រុក ដែលជាការចូលរួមដល់កិច្ចអភិវឌ្ឍ និងថែរក្សាបរិស្ថាន និងធនធានធម្មជាតិ ពិសេសក្នុងតំបន់ការពារធនធានធម្មជាតិ ដែលនិយាយថា “ទេសចរណ៍ត្រូវការតំបន់ការពារធម្មជាតិ តំបន់ការពារធម្មជាតិត្រូវការទេសចរណ៍” ហើយការផ្សារភ្ជាប់ “ទេសចរណ៍ និងបរិស្ថាន” អាចចូលរួមដោះស្រាយនូវបញ្ហាប្រឈមនានាក្នុងសហគមន៍មូលដ្ឋាន។</td><td>របៀបវារៈ/ រយៈពេល÷
អនុវត្តរយៈពេល ខ្លី និងមធ្យម ដោយគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន និងរដ្ឋបាលខេត្ត។</td><td>ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាជា២គ្រោងរួមមាន÷
• គម្រោងទី១. ប្រើប្រាស់ថវិកាប្រមាណពី ៨លាន-១០លានដុល្លារអាមេរិក។
• គម្រោងទី២. ប្រើប្រាស់ថវិកាប្រមាណពី ៤លាន-៥លានដុល្លារអាមេរិក។</td></tr>
<tr><td>គម្រោងពាក់ព័ន្ធផ្សេងទៀត÷
បច្ចុប្បន្ន÷ មានសហគមន៍ទេសចរណ៍ចំនួន០៥ នៅតំបន់ទន្លេសាប (ខេត្តសៀមរាប) រួមមាន÷
១. ភូមិភ្នំក្រោម - កំពង់ផែទេសចរណ៍- ភូមិចុងឃ្នាស, ២. សហគមន៍ទេសចរណ៍បឹងពារាំង (ជ្រោរ), ៣. ភូមិកំពង់ភ្នក, ៤. ភូមិកំពង់ឃ្លាំង, ៥. សហគមន៍មេជ្រៃ។</td><td colspan="2"></td></tr>
</table>

សកម្មភាពអាទិភាពទី១៥÷ គម្រោងស្តីពី "ការបង្កើតបណ្ណាទេសចរណ៍សៀមរាប"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ យុទ្ធសាស្ត្រសិក្សាទីផ្សារ និងការផ្សព្វផ្សាយទេសចរណ៍ខេត្តសៀមរាប

ល.រ	ចំណងជើងគម្រោង		ក្រុមទទួលបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.១៥	ការបង្កើតបណ្ណាទេសចរណ៍សៀមរាប		ភ្ញៀវទេសចរ វិស័យឯកជន	រដ្ឋ-ឯកជន	អាទិភាព ១
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**វិធីសាស្ត្រនៃការអនុវត្ត÷** • បង្កើតរចនាសម្ព័ន្ធ ដើម្បីធានាការអនុវត្ត និងគ្រប់គ្រងបណ្ណាទេសចរណ៍ • ជ្រើសរើសគោលដៅទេសចរណ៍/រមណីយដ្ឋានដៃគូ និងកំណត់តារាងតម្លៃនៃបណ្ណាទេសចរណ៍ ការលក់សំបុត្រចូលទស្សនាអង្គរ និងតាមរមណីយដ្ឋានទេសចរណ៍ធំៗក៏នឹងអាចដាក់បញ្ចូលទៅក្នុងបណ្ណាទេសចរណ៍សៀមរាប ដើម្បីឱ្យដើរតួជា "កម្លាំងចលករ" • ប្រើប្រាស់បណ្ណាទេសចរណ៍ដែលមានភ្ជាប់ជាមួយបច្ចេកវិទ្យាឌីជីថល • បង្កើតកិច្ចព្រមព្រៀងសហការស្របច្បាប់រវាងស្ថាប័នគ្រប់គ្រង និងក្រុមហ៊ុនដៃគូ • ធ្វើការផ្សព្វផ្សាយបណ្ណាទេសចរណ៍សៀមរាប។ល។
ខេត្តសៀមរាប		• ក្រសួងទេសចរណ៍ • ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ • គ្រឹះស្ថានអង្គរ • អាជ្ញាធរជាតិអប្សរា • វិស័យឯកជន		
សារវាៈ÷ ការប្រើប្រាស់បណ្ណាទេសចរណ៍ នឹងធ្វើឱ្យការផ្សព្វផ្សាយ និងការលក់សំបុត្រចូលទស្សនាប្រាសាទអង្គរកាន់មានភាពងាយស្រួល។ តាមបទពិសោធន៍ប្រទេសជំទៃ ភ្ញៀវទេសចរអន្តរជាតិជាច្រើន ប្រើប្រាស់សេវាកម្មប្រភេទនេះ ក្នុងអំឡុងពេលស្នាក់នៅរបស់ខ្លួន ដោយវាជួយកាត់បន្ថយតម្លៃចំណាយបន្ថែម(យ៉ាងតិច ២០%) លើចំណាយសេវាកម្មទេសចរណ៍លក្ខណៈជាកញ្ចប់ (ដោយប្រៀបធៀបជាមួយសេវាកម្មប្រសិនបើភ្ញៀវទេសចរជ្រើសរើសយកដាច់ដោយឡែកពីគ្នា)។ ភ្ញៀវទេសចរអាចទទួលបានបណ្ណាទេសចរណ៍មួយ ដែលរួមបញ្ចូលការទស្សនាវប្បធម៌ និងធម្មជាតិ ឬសកម្មភាពក្នុងតំបន់ និងការដឹកជញ្ជូន នៅតាមរមណីយដ្ឋាន ដែលបានកំណត់ទុកជាមុន។			**សមាសភាពអនុវត្តគម្រោង÷** • រចនាសម្ព័ន្ធបណ្ណាទេសចរណ៍សៀមរាប - ភ្ជាប់តំបន់ទេសចរណ៍សំខាន់ៗនៅខេត្តសៀមរាប - ភ្ជាប់ការចូលទស្សនាអង្គរ និងគោលដៅទេសចរណ៍នានា - ភ្ជាប់តំបន់បេតិកភណ្ឌពិភពលោកផ្សេងទៀត (ប្រាសាទព្រះវិហារ និងប្រាសាទសម្បូរព្រៃគុហ៍) • ដំណើរការ និងបង្កើតប្រព័ន្ធបច្ចេកវិទ្យាសម្រាប់គ្រប់គ្រង និងផ្គត់ផ្គង់បណ្ណាទេសចរណ៍សៀមរាប • បង្កើតភាពជាដៃគូសម្រាប់តួអង្គសំខាន់ៗក្នុងការដាក់ឱ្យដំណើរការគម្រោងបណ្ណាទេសចរណ៍សៀមរាបនេះ។ល។

<table>
<tr><td colspan="2">គោលបំណង÷
• ពន្យារយៈពេលស្នាក់នៅរបស់ភ្ញៀវទេសចរអន្តរជាតិដោយសម្រួលដល់សកម្មភាព និងសេវាកម្មមួយចំនួននៅក្នុងខេត្តសៀមរាប
• បង្កើនប្រាក់ចំណូលទេសចរណ៍នៅតាមរមណីយដ្ឋានផ្សេងៗទៀត និងសម្រាប់អ្នកផ្តល់សេវាកម្មដែលជាដៃគូប្រើប្រាស់បណ្ណនេះ
• ទប់ទល់នឹងការមកដល់ច្រើនកកកុញពេក នៅតាមរមណីយដ្ឋានសំខាន់ៗ តាមរយៈការបង្កើនប្រសិទ្ធភាពនៃការផ្សព្វផ្សាយវិហ្សារភ្ញៀវទេសចរ ទៅកាន់រមណីយដ្ឋានទាក់ទាញទេសចរណ៍ដទៃទៀតនៃខេត្តសៀមរាប
• ចូលរួមគាំទ្រការធ្វើពិពិធកម្មទេសចរណ៍នៅខេត្តសៀមរាប។</td><td colspan="2">លទ្ធផលនៃគម្រោង÷
បណ្ណទេសចរណ៍សៀមរាបនេះនឹងផ្តល់ផលវិជ្ជមាននាពេលអនាគត រួមមាន÷
• ពិពិធកម្មវិហ្សារភ្ញៀវទេសចរ និងការពន្យារការស្នាក់នៅទេសចរណ៍ (ដោយជំរុញចលនាទេសចរណ៍ក្នុងស្រុក)
• ជួយរមណីយដ្ឋានផ្សេងទៀត ឬអ្នកផ្តល់សេវាកម្មដទៃទៀតដែលនៅក្នុងខេត្តឱ្យទទួលបានអត្ថប្រយោជន៍
• បង្កើនចំណូលទេសចរណ៍ខេត្តសៀមរាប ជាពិសេសសម្រាប់ប្រតិបត្តិករក្នុងស្រុក
• ធ្វើឱ្យភ្ញៀវទេសចរអន្តរជាតិនៅខេត្តសៀមរាបមានលក្ខណៈចម្រុះ÷ ជាទូទៅ បណ្ណទេសចរណ៍ ទទួលបានជោគជ័យគួរឱ្យកត់សម្គាល់ ដោយសារភ្ញៀវលក្ខណៈគ្រួសារ មនុស្សវ័យចំណាស់ និងយុវជនសកម្មនៅតាមទីក្រុង (ដែលមានទម្លាប់ប្រើប្រាស់ឧបករណ៍ប្រភេទនេះ)
• គ្រប់គ្រងឱ្យកាន់តែប្រសើរឡើងនូវវិហ្សារភ្ញៀវទេសចរដោយការចែករំលែកភ្ញៀវទេសចរអន្តរជាតិ ទៅកាន់ទីតាំងទេសចរណ៍ផ្សេងៗទៀតនៃខេត្តទាំងមូល ហើយធ្វើយ៉ាងនោះនឹងអាចទប់ស្កាត់បានមួយផ្នែកនូវបាតុភូតវិហ្សារទេសចរណ៍ច្រើនហួសកម្រិត
• គ្រប់គ្រង និងរៀបចំជាដំណើរកម្សាន្តថ្មីៗមួយចំនួន តាមរយៈដៃគូសហការជាមួយវិស័យឯកជន ដូចជា ដំណើរកម្សាន្តនៅលើបឹងទន្លេសាប។ល។</td></tr>
<tr><td colspan="2">ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះ មិនមានផ្តល់នូវផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។</td><td rowspan="2">របៀបវារៈ / រយៈពេល÷
បណ្ណទេសចរណ៍នេះនឹងត្រូវបង្កើតក្នុងរយៈពេលខ្លី ដោយក្រសួងទេសចរណ៍ គ្រឹះស្ថានអង្គរ និងក្រុមហ៊ុនឯកជន។</td><td>ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ ០,៩៥ - ១ លានដុល្លារអាមេរិក។</td></tr>
<tr><td>ហេតុផល÷
ការប្រើប្រាស់បណ្ណទេសចរណ៍នេះ នឹងដើរតួយ៉ាងសំខាន់ ជាពិសេសដល់ការទាក់ទាញភ្ញៀវទេសចរមកលក្ខណៈជាបុគ្គល។ ភ្ញៀវទេសចរទទួលបានសេវាកម្មទៅតាមការចំណាយលើប័ណ្ណរបស់ខ្លួន ដែលមានដាក់បង្ហាញជាតារាងតម្លៃ ឬប្រភេទប័ណ្ណនីមួយៗ។</td><td colspan="2"></td></tr>
</table>

សកម្មភាពអាទិភាពទី១៦÷ គម្រោងស្តីពី "ការពង្រឹងសមត្ថភាពផ្សព្វផ្សាយទេសចរណ៍នៅខេត្តសៀមរាប"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ យុទ្ធសាស្ត្រផ្សព្វផ្សាយ និងទាក់ទាញទេសចរណ៍មកខេត្តសៀមរាប

ល.រ	ចំណងជើងគម្រោង		ក្រុមទទួលបានផលពីគម្រោង ឬ/និងក្រុមគោលដៅ	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.១៦	ការពង្រឹងសមត្ថភាពផ្សព្វផ្សាយទេសចរណ៍នៅខេត្តសៀមរាប		ឧស្សាហកម្មទេសចរណ៍	រដ្ឋ-ឯកជន	អាទិភាព ១
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**សមាសធាតុនៃគម្រោង÷** • បង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (សាខាខេត្តសៀមរាប) • ការរៀបចំផែនការយុទ្ធសាស្ត្រទីផ្សារ និងផែនការផ្សព្វផ្សាយសម្រាប់ខេត្តសៀមរាប (២០២១-២០៣៥) • ការពង្រឹងសមត្ថភាពវិស័យទេសចរណ៍នៅខេត្តសៀមរាបតាមរយៈការបញ្ជូនអ្នកជំនាញការទេសចរណ៍បរទេស (ការធ្វើទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ ការអភិវឌ្ឍធនធានមនុស្ស/ការគ្រប់គ្រង អ្នកជំនាញទិន្នន័យ /អ្នកជំនាញព័ត៌មានវិទ្យា ការអភិវឌ្ឍផលិតផលទេសចរណ៍) • បង្កើតមូលនិធិគាំទ្រសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ខេត្តសៀមរាបទ្រទ្រង់ដំណើរការក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជាសាខាខេត្តសៀមរាប (ក្រោមទម្រង់ភាពជាដៃគូរដ្ឋ-ឯកជន- PPP)÷ - ឆ្នាំដំបូង÷ គួរចាប់ផ្តើមពីការរួមគ្នាថវិកាយ៉ាងហោច ២លានដុល្លារអាមេរិកដោយរដ្ឋ និង ២លានដុល្លារអាមេរិកទៀតដោយផ្នែកឯកជន (បដិភាគ ៥០%-៥០%)។ - ឆ្នាំបន្តបន្ទាប់÷មានការបង្កើនទុនរួមជាបន្តបន្ទាប់ស្របតាមតម្រូវការនៃការអភិវឌ្ឍទេសចរណ៍ខេត្តសៀមរាប។		
ខេត្តសៀមរាប		• ក្រសួងទេសចរណ៍ • ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា			
សារវន្តរ÷ ខេត្តសៀមរាបបានក្លាយជាគោលដៅទេសចរណ៍ដ៏ធំយ៉ាងឆាប់រហ័ស ទោះជាយ៉ាងណា នាពេលបច្ចុប្បន្នការសិក្សាទីផ្សារទេសចរណ៍ និងផ្សព្វផ្សាយទេសចរណ៍ មានកម្រិតនៅឡើយពោលគឺជាឧបសគ្គចំពោះខេត្តសៀមរាបដើម្បីក្លាយជា "ទិសដៅទេសចរណ៍ដែលមានគុណភាព"។ ភាពមានកម្រិតនេះគឺ ដោយសារការចូលរួមរបស់វិស័យឯកជននៅមានកម្រិតក្នុងការទ្រទ្រង់ហិរញ្ញប្បទានសម្រាប់ការផ្សព្វផ្សាយទេសចរណ៍។			**លទ្ធផលនៃគម្រោង÷** លទ្ធផល នៃគម្រោង នឹងជួយពង្រឹងសមត្ថភាពលើការផ្សព្វផ្សាយ និងរៀបចំទីផ្សារ តាមរយៈភាពជាដៃគូសហការរវាងសហការរដ្ឋ និងផ្នែកឯកជន និងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពនៃការផ្សព្វផ្សាយទេសចរណ៍ក្នុងខេត្តសៀមរាប។		
គោលបំណងនៃគម្រោង÷ គម្រោងនេះ មានគោលបំណងលើកស្ទួយតម្លៃនៃវិស័យទេសចរណ៍ខេត្តសៀមរាប តាមរយៈការបង្កើនសមត្ថភាពសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ដោយពង្រឹងភាពជាដៃគូកិច្ចសហការរវាងវិស័យសាធារណៈ និងឯកជនតាមរយៈការបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ខេត្តសៀមរាប និងបង្កើតអង្គភាពអង្កេតព័ត៌មានទេសចរណ៍។					
ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷		**របៀបវារៈ / រយៈពេល÷**	**ថ្លៃដើមនៃគម្រោង÷**		

គម្រោងនេះ មិនមានផលប៉ះពាល់ទៅដល់សង្គម និងបរិស្ថាន។	អនុវត្តរយៈពេលខ្លី ដោយក្រសួងទេសចរណ៍ និងក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា។	គម្រោងនៃការអភិវឌ្ឍនេះ ពិបាកប៉ាន់ប្រមាណថ្លៃដើមនៃគម្រោង ព្រោះផ្អែកលើបច្ចេកវិទ្យាជាក់ស្តែង និងការផ្គត់ផ្គង់សេវាកម្មរបស់ក្រុមហ៊ុនអន្តរជាតិ ឬក្នុងស្រុក។
គម្រោងដែលពាក់ព័ន្ធ÷ រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (ថ្នាក់ជាតិ) ដែលមាន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ជាប្រធាន ក្រោមអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា។		

សកម្មភាពអាទិភាពទី១៧÷ គម្រោងស្តីពី "ការបង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍សាខាខេត្តសៀមរាប"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍

ល.រ	ចំណងជើងគម្រោង		ក្រុមទទួលបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.១៧	បង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍សាខានៅខេត្តសៀមរាប		ប្រជាពលរដ្ឋ ភ្ញៀវទេសចរនិង ប្រតិបត្តិករទេសចរណ៍	រដ្ឋ	អាទិភាព ១
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**វិធីសាស្ត្រនៃការអនុវត្ត÷** • បង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍នៅខេត្តសៀមរាប • កំណត់អត្តសញ្ញាណតួអង្គដៃគូសក្តានុពលសម្រាប់ដំណើរការសាលាជាតិវិជ្ជាជីវៈទេសចរណ៍ • ប៉ាន់ប្រមាណតម្លៃ លទ្ធភាពប្រតិបត្តិការរបស់សាលាជាតិវិជ្ជាជីវៈទេសចរណ៍នៅខេត្តសៀមរាប • ស្វែងរកដៃគូសហការលើដំណើរការសាលាជាតិ (ទាំងបច្ចេកទេស និងហិរញ្ញវត្ថុ)		
តំបន់ប៉ុរីទេសចរណ៍វប្បធម៌ (ក្រុងសៀមរាប)		• ក្រសួងទេសចរណ៍ • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ • សាលាវិជ្ជាជីវៈទេសចរណ៍			
សារវៈ÷ បច្ចុប្បន្នមានសាលាវិជ្ជាជីវៈទេសចរណ៍នៅខេត្តសៀមរាបមានចំនួន ០៦សាលា • អង្គការបណ្តុះបណ្តាលបដិសណ្ឋារកិច្ច និងទេសចរណ៍ អេកបក់ • វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប • សកលវិទ្យាល័យ Southeast Asia ខេត្តសៀមរាប • សាលាសណ្ឋាគារ សាលាបាយ • សាលាសណ្ឋាគារ និងទេសចរណ៍ ប៉ូល ឌុយ ប្រ៊ូល • មជ្ឈមណ្ឌលបណ្តុះបណ្តាល ឌ្រីម ប៉ុន្តែការផ្តល់ការបណ្តុះបណ្តាលដោយមជ្ឈមណ្ឌល/ សាលាបណ្តុះបណ្តាលខាងលើមិនទាន់ឆ្លើយតបនឹងតម្រូវការទីផ្សារការងារក្នុងវិស័យទេសចរណ៍នៅខេត្តសៀមរាបនៅឡើយ។			**សមាសធាតុនៃគម្រោង÷** • រៀបចំហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់លើការរៀបចំសាលាជាតិវិជ្ជាជីវៈទេសចរណ៍ - រៀបចំកម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិ និងអាស៊ានដែលឆ្លើយតបទៅនឹងតម្រូវការ - កំណត់គំរូសេដ្ឋកិច្ចរបស់សាលា (ថ្លៃសាលាតាមកម្រិត ថវិកាសាធារណៈសកម្មភាពបង្កើតចំណូល រំហួរប្រចាំឆ្នាំនៃនិស្សិត ចំនួនគ្រូបណ្តុះបណ្តាលដែលត្រូវជ្រើសរើស។ល។) និងកំណត់តម្រូវការថវិកាបន្តបន្ទាប់។ - រៀបចំអភិបាលកិច្ចរបស់សាលា - ការរៀបចំរចនាអគារ និងបញ្ជីឧបករណ៍ដើម្បីឆ្លើយតបនឹងតម្រូវការបណ្តុះបណ្តាល • រៀបចំហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង (សាងសង់សាលា) ដោយត្រូវការអនុលោមតាមប្លង់ស្ថាបត្យកម្ម។	
គោលបំណង÷ ការបង្កើតសាលាបណ្តុះបណ្តាលជាតិជំនាញវិជ្ជាជីវៈទេសចរណ៍មានគោលបំណង÷ • សាលាជាតិវិជ្ជាជីវៈទេសចរណ៍ ដើរតួនាទីសំខាន់សម្រាប់ឆ្លើយតបទៅនឹងកំណើនតម្រូវការធនធានមនុស្សនៅក្នុងវិស័យទេសចរណ៍ ជាពិសេសបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពយុវជនកម្ពុជា និងផ្តល់ឱកាសដល់យុវជនកម្ពុជា (ពិសេសយុវជនក្រីក្រ) សម្រាប់កសាងអនាគតរបស់ខ្លួន តាមរយៈការចាប់យកអាជីពជាអ្នកជំនាញវិជ្ជាជីវៈទេសចរណ៍ទាំងក្នុង			**លទ្ធផលនៃគម្រោង÷** • ផ្តល់ការបណ្តុះបណ្តាលប្រកបដោយគុណភាពស្របតាមស្តង់ដាកម្មវិធីសិក្សា និងក្របខណ្ឌគុណវឌ្ឍិថ្នាក់ជាតិ និងអាស៊ាន និងបង្កើតឱ្យបានធនធានប្រកបដោយសមត្ថភាពជំនាញវិជ្ជាជីវៈទេសចរណ៍ឆ្លើយតបនឹងតម្រូវការទេសចរណ៍នៅឆ្នាំ ២០៣៥ (ជាទេសចរណ៍គុណភាព) ។ • អាចផ្តល់ឱកាសឱ្យយុវជន សិស្ស និស្សិត (រួមទាំងយុវជនក្រីក្រអាចទទួលបានការបណ្តុះបណ្តាលក្នុងតម្លៃសមរម្យ)។	

<table>
<tr><td colspan="3">ប្រទេស និងការបម្ភាស់ទីនៅក្នុងតំបន់អាស៊ាន ដែលជាកត្តាមួយចូលរួមដល់ការកាត់បន្ថយភាពក្រីក្រ។
• សាលាជាតិវិជ្ជាជីវៈទេសចរណ៍ត្រូវផ្តល់ការបណ្តុះបណ្តាលប្រកបដោយគុណភាព ស្របតាមស្តង់ដាកម្មវិធីសិក្សា និងក្របខ័ណ្ឌគុណវឌ្ឍិថ្នាក់ជាតិ និងអាស៊ាន។
• ផ្តល់ឱកាសឱ្យមានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលមានតម្លៃសមរម្យដល់យុវជន សិស្ស និស្សិត ក្រីក្រទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈស្របតាមទស្សនៈ (ការអប់រំសម្រាប់ទាំងអស់គ្នា)
• ពង្រឹងការផ្គត់ផ្គង់ជូននូវការបណ្តុះបណ្តាលបច្ចុប្បន្នទាក់ទងនឹងសមត្ថភាព
• បង្កើតវគ្គបណ្តុះបណ្តាលថ្មីៗស្របតាមវិជ្ជាជីវៈទេសចរណ៍ថ្មី
• អភិវឌ្ឍជំនាញក្នុងវិស័យទេសចរណ៍
• ពង្រឹងគុណភាពសេវាកម្មទេសចរណ៍ក្នុងគោលបំណងកែលម្អការពេញចិត្តរបស់ភ្ញៀវទេសចរ
• អភិវឌ្ឍអគ្រាត្រឡប់មកវិញនិងកែលម្អរូបភាពខេត្តសៀមរាបជាទិសដៅដែលមានគុណភាពខ្ពស់សម្រាប់សេវាកម្ម</td><td></td></tr>
<tr><td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះ មិនមានផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។</td><td rowspan="2">របៀបវារៈ / រយៈពេល÷
អនុវត្តរយៈពេលខ្លី ដោយក្រសួងទេសចរណ៍។</td><td rowspan="2">ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ ៨-១០លានដុល្លារអាមេរិក។</td></tr>
<tr><td>ហេតុផល÷
យុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ខេត្តសៀមរាបឆ្ពោះទៅឆ្នាំ២០៣៥ ជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព ដែលទាមទារបុគ្គលិកបម្រើការក្នុងឧស្សាហកម្មទេសចរណ៍មានជំនាញវិជ្ជាជីវៈច្បាស់លាស់។ ប៉ុន្តែ ក្នុងដំណាក់កាលបច្ចុប្បន្ននេះ បុគ្គលិកបម្រើការងារក្នុងឧស្សាហកម្មទេសចរណ៍នៅខេត្តសៀមរាបមានប្រមាណតែ៣០% ប៉ុណ្ណោះដែលឆ្លងកាត់ការបណ្តុះបណ្តាលមានវិញ្ញាបនបត្រទទួលស្គាល់។</td></tr>
</table>

សកម្មភាពអាទិភាពទី១៨÷ គម្រោងស្តីពី "ការកែលម្អបរិស្ថានស្អាត និងទីក្រុងស្អាតខេត្តសៀមរាប"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ បង្កើននិរន្តរភាពទេសចរណ៍

ល.រ	ចំណងជើងគម្រោង	ក្រុមឧទ្ទិសបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.១៨	សិក្សាគម្រោងកែលម្អបរិស្ថានស្អាត និងទីក្រុងស្អាតខេត្តសៀមរាប	ភ្ញៀវទេសចរ ប្រតិបត្តិករទេសចរណ៍ ប្រជាពលរដ្ឋមូលដ្ឋាន ក្រុមហ៊ុនប្រមូលសំរាម	រដ្ឋ និងដៃគូអភិវឌ្ឍ	អាទិភាព ១ និង ២

ទីតាំងគម្រោង	ភ្នាក់ងារអនុវត្តគម្រោង	**វិធីសាស្ត្រនៃការអនុវត្ត÷** • កំណត់ និងវិភាគស្ថានភាពលទ្ធភាពរបស់ក្រុមហ៊ុនប្រមូលសំរាម និងបង្កើនសមត្ថភាពក្រុមហ៊ុនប្រមូលសំរាម • កំណត់ និងរៀបចំទីលានចាក់សំរាម (ទីលានចាក់សំរាមមានលក្ខណៈស្តង់ដា) • កំណត់ និងសិក្សាលើលទ្ធភាពរៀបចំ និងអនុវត្តយន្តការថ្មីលើការគ្រប់គ្រងសំរាម សំណល់រឹង ដោយផ្អែកលើ បទពិសោធន៍អនុវត្ត របស់រដ្ឋាករស្ងយ័តគ្រប់គ្រងសំរាមសំណល់រឹងនៅរាជធានីភ្នំពេញ • សិក្សាប្រើប្រាស់ និងបន្សុីបច្ចេកវិទ្យាឌីជីថល។ល។
ខេត្តសៀមរាប	• រដ្ឋបាលខេត្តសៀមរាប • ក្រសួងបរិស្ថាន • គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត • ក្រុមហ៊ុនប្រមូលសំរាម • DMO's	

សាវតារ÷ ខេត្តសៀមរាបមានក្រុមហ៊ុនប្រមូលសំរាមចំនួន (០៤)÷ • ក្រុមហ៊ុន V-Green • ក្រុមហ៊ុន ហ្គា.អ៊ី.យ៉ា ភីអិលស៊ុី (GA.E.A Plc) • ក្រុមហ៊ុន Active Green Co., Ltd • ក្រុមហ៊ុន Cintri Co., Ltd នៅឆ្នាំ២០១៩ បរិមាណសំរាម សំណល់រឹង ដែលបញ្ចេញចោល ក្នុងក្រុង ឬខេត្ត មានចំនួន ៣៨០ តោន/ថ្ងៃ ។	**សមាសភាពអនុវត្តគម្រោង÷** • បង្កើនសមត្ថភាពក្រុមហ៊ុនប្រមូលសំរាមឱ្យមាននៅតាមតំបន់ទេសចរណ៍អាទិភាពនីមួយៗអមជាមួយការពង្រឹងមធ្យោបាយប្រមូលហិរញ្ញប្បទានទ្រទ្រង់ការគ្រប់គ្រងសំរាម សំណល់រឹង ឱ្យកាន់តែមានប្រសិទ្ធភាព • រៀបចំទីលានចាក់សំរាម (ទីលានចាក់បណ្តោះអាសន្ន និងទីលានចាក់សំរាមមានលក្ខណៈស្តង់ដា) • បង្កើតរដ្ឋាករស្ងយ័តគ្រប់គ្រងសំរាម សំណល់រឹង ខេត្តសៀមរាប • ប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការគ្រប់គ្រងសំរាម សំណល់រឹង • បង្កើតយុទ្ធនាការផ្សព្វផ្សាយ ដូចជា យុទ្ធនាការ "សៀមរាបស្អាត" "ទីក្រុងស្អាត" "កម្ពុជាស្អាត" (ក្នុងនោះរួមមានទន្លេសាបស្អាត គូលែនស្អាត បន្ទាយស្រីស្អាត...) ស្របតាមចលនាប្រជុំជុំប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"
គោលបំណង÷	**លទ្ធផលនៃគម្រោង÷**

<table>
<tr><td colspan="3">គម្រោងការកែលម្អបរិស្ថានស្អាត ទីក្រុងស្អាតខេត្តសៀមរាបនេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងសោភណភាពបរិស្ថានស្អាត និងទីក្រុងស្អាត នៅសៀមរាបឱ្យស័ក្តិសមជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព។</td><td colspan="2">លទ្ធផលនៃគម្រោងគឺធ្វើឱ្យ÷
• ក្រុមហ៊ុនប្រមូលសំរាមមានសមត្ថភាពប្រសើរជាងមុន
• ការគ្រប់គ្រងទីលានប្រសើរជាងមុន
• បរិស្ថាន (ខ្យល់អាកាសបរិសុទ្ធ) ជាទីក្រុងនិរន្តរភាពបរិស្ថាន និងជាទីក្រុងស្អាត
• ជាគោលដៅទេសចរណ៍ដែលមិនមានការបំពុលដោយខ្យល់ សំឡេង និងផ្សែងពុល។ល។
• មានយន្តការស្ថាប័ន ក្រុមហ៊ុនកែច្នៃដែលមានប្រសិទ្ធភាពជាងមុន
• ខេត្តសៀមរាប÷ ស្រស់ស្អាតជាខេត្តស្អាត-ទីក្រុងស្អាតស្របតាមពាក្យស្លោក “សៀមរាបផ្ទះខ្ញុំ”។</td></tr>
<tr><td colspan="3">ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះ មិនមានផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងបរិស្ថាន។</td><td rowspan="2">របៀបវារៈ / រយៈពេល÷
អនុវត្តរយៈពេលខ្លី និងមធ្យម ដោយក្រសួងបរិស្ថាន និងរដ្ឋបាលខេត្តសៀមរាប និង DMOs។</td><td rowspan="2">ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ ២០-៣០លាន ដុល្លារ អាមេរិក។</td></tr>
<tr><td colspan="3">ហេតុផល÷
ការកែលម្អបរិស្ថានស្អាត និងទីក្រុងស្អាតខេត្តសៀមរាប គឺជាកត្តាសំខាន់មួយសម្រាប់ខេត្តទេសចរណ៍បេតិកភណ្ឌប្រវត្តិសាស្ត្រមួយនេះ ស័ក្តិសមជាទីកន្លែងនៃសម្បត្តិបេតិកភណ្ឌពិភពលោក និងជាគោលដៅទេសចរណ៍លំដាប់ពិភពលោកដែលបានទទួលស្គាល់ជាបន្តបន្ទាប់ដោយទីភ្នាក់ងារ និងអ្នកជំនាញអន្តរជាតិ។</td></tr>
</table>

សកម្មភាពអាទិភាពទី១៩÷ គម្រោងស្តីពី "ការបង្កើតសារមន្ទីរអរិយធម៌ខ្មែរ"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ ការអភិវឌ្ឍតំបន់ទេសចរណ៍សៀមរាបថ្មី

ល.រ	ចំណងជើងគម្រោង		ក្រុមទទួលបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.១៩	សិក្សាគម្រោងបង្កើតសារមន្ទីរអរិយធម៌ខ្មែរ		ភ្ញៀវទេសចរ ប្រតិបត្តិករទេសចរណ៍ ប្រជាពលរដ្ឋមូលដ្ឋាន	រដ្ឋ-ឯកជន	អាទិភាព ២
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**វិធីសាស្ត្រនៃការអនុវត្ត÷** • ការសិក្សាពីលទ្ធភាពនៃការបង្កើតសារមន្ទីរអរិយធម៌ខ្មែរ • ការជ្រើសរើសទីតាំង និងប្តង់ស្ថាបនាលម្អិត (ការរចនា និងការស្ថាបនាអគារ) • ការរៀបចំប្តង់ទិដ្ឋភាពទូទៅនៃគម្រោងសាងសង់ • ផែនការអនុវត្ត និងគ្រប់គ្រង • ជ្រើសរើសបុគ្គលិកជំនាញ និងបុគ្គលិកគ្រប់គ្រង • រៀបចំផែនការផ្សព្វផ្សាយ និងធ្វើទីផ្សារ។ល។		
តំបន់ទេសចរណ៍សៀមរាបថ្មី		• ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ • ក្រសួងទេសចរណ៍ • អាជ្ញាធរជាតិអប្សរា និងវិស័យឯកជន			
សាវតារ÷ បច្ចុប្បន្ន នៅប្រទេសកម្ពុជាមានសារមន្ទីរជាច្រើនរួចហើយ ប៉ុន្តែការតាំងពិព័រណ៍មានភាគច្រើនផ្តោតតែនៅលើជាវត្ថុបុរាណធ្វើឡើងអំពីឈើ សំរឹទ្ធ និងថ្ម ដែលមានប្រភពពីតំបន់បុរាណវិទ្យា និងបុរាណដ្ឋានតែប៉ុណ្ណោះ។ ប៉ុន្តែតម្រូវការរបស់ភ្ញៀវទេសចរក្រៅពីការស្វែងយល់អំពីវត្ថុបុរាណ ពួកគាត់ត្រូវការស្វែងយល់ពីប្រពៃណីវប្បធម៌ និងរបៀបរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ។			**សមាសភាពអនុវត្តគម្រោង÷** • **សារមន្ទីរអរិយធម៌ខ្មែរ**នឹងប្រើបច្ចេកវិទ្យាឌីជីថល ដូចជា Virtual Reality (VR)/Augmented Reality (AR)..... ដើម្បីបកស្រាយ និងពន្យល់អំពីប្រពៃណី របៀបរស់នៅ ទំនៀមទម្លាប់របស់ប្រជាពលរដ្ឋខ្មែរជាអាទិ៍÷ ផ្តោតទៅលើអរិយធម៌ និងប្រពៃណីខ្មែរ រួមមាន÷ - កំណើត, ភាពពេញវ័យ, អាពាហ៍ពិពាហ៍, មរណភាព ពិធីប្រពៃណីផ្សេងៗ (បច្ចុប្បន្នតាមរយៈការនិយាយគ្នាៗគ្នា ឬជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ ដែលពិបាកក្នុងការផ្សព្វផ្សាយទៅដល់ភ្ញៀវទេសចរបាន)។ - កសិកម្ម÷ ផលិតផលកសិកម្ម ពិធីបុណ្យផ្សេងៗដែលបង្ហាញអំពីជីវភាពរបស់កសិករ - សម្លៀកបំពាក់។ ល។ • **សារមន្ទីរស្រូវ÷** សារមន្ទីរស្រូវនឹងមានការរៀបចំតាំងពិព័រណ៍ អំពីរបៀបដាំដុះស្រូវ មានដូចជា ការរៀបចំដីភ្ជួរស្រែ ដំណើរការសាប/ព្រោះស្រូវ ការដកសំណាប ដំណើរការស្វូង ច្រូតកាត់ បោកស្រូវ និងកិនយកជាអង្ករ។ ដំណើរការនៃផលិតស្រូវរហូតដល់បានជាបាយអាចហូបបាននេះ ជាប្រពៃណីរបស់ប្រជាពលរដ្ឋខ្មែរ		

<table>
<tr><td colspan="2"></td><td>តាំងពីដើមមកដែលគួរមានការដាក់បង្ហាញដល់ភ្ញៀវទេសចរអន្តរជាតិយល់ដឹងបន្ថែម។ ម៉្យាងទៀត សារមន្ទីរនេះក៏នឹងរក្សាទុកដាក់ដើម្បីការការពារ និងតាំងបង្ហាញនូវវត្ថុដ៏មានតម្លៃផ្សេងៗ ផ្នែកសិល្បៈ ប្រវត្តិសាស្ត្រ និងផ្នែកបុរាណវិទ្យារបស់ខ្មែរផងដែរ។</td></tr>
<tr><td colspan="2">គោលបំណង÷
សារមន្ទីរអរិយធម៌ខ្មែរ គឺដើម្បីបង្ហាញការទាក់ទាញចំណាប់អារម្មណ៍របស់ភ្ញៀវទេសចរអន្តរជាតិឱ្យយល់ដឹងអំពីអរិយធម៌ខ្មែរដ៏ល្អប្រពៃ ដែលនឹងក្លាយជាផលិតផលទេសចរណ៍ដ៏ទាក់ទាញថ្មីមួយទៀតនៅខេត្តសៀមរាប។</td><td colspan="2">លទ្ធផលនៃគម្រោង÷
លទ្ធផលនៃគម្រោង គឺនឹងជួយលើកកម្ពស់តម្លៃរបស់ប្រាសាទនីមួយៗ និងផ្តល់បទពិសោធន៍ទេសចរណ៍ថ្មីៗដល់ភ្ញៀវទេសចរឱ្យកាន់តែខ្លាំងថែមមួយកម្រិតទៀត។</td></tr>
<tr><td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះមិនមានផលប៉ះពាល់ដល់ផ្នែកបរិស្ថាន និងសង្គម។

.</td><td>របៀបវារៈ / រយៈពេល÷
អនុវត្តរយៈពេលមធ្យម និងវែង ដោយក្រសួងទេសចរណ៍ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងផ្នែកឯកជន។</td><td>ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ ១៥-២០ លានដុល្លារអាមេរិក។</td></tr>
</table>

សកម្មភាពអាទិភាពទី២០÷ គម្រោងស្តីពី "ការពង្រឹងគុណភាពសេវាកម្មទេសចរណ៍នៅខេត្តសៀមរាប"

តារាងសង្ខេបនៃគម្រោង

ផ្នែក÷ យុទ្ធសាស្ត្រពង្រឹងគុណភាពទេសចរណ៍នៅខេត្តសៀមរាប

ល.រ	ចំណងជើងគម្រោង		ក្រុមទទួលបានផលពីគម្រោង	ថវិការំពឹងទុក	អាទិភាពនៃគម្រោង
ស.អ.២០	បង្កើនការពង្រឹងគុណភាពសេវាកម្មទេសចរណ៍នៅខេត្តសៀមរាប		ភ្ញៀវទេសចរ ប្រតិបត្តិករទេសចរណ៍ ប្រជាពលរដ្ឋមូលដ្ឋាន	រដ្ឋ-ឯកជន	អាទិភាព ១ និង២
ទីតាំងគម្រោង		**ភ្នាក់ងារអនុវត្តគម្រោង**	**វិធីសាស្ត្រនៃការអនុវត្ត÷**		
ខេត្តសៀមរាប		• ក្រសួងទេសចរណ៍ • រដ្ឋបាលខេត្តសៀមរាប • គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍	• ជំរុញឱ្យប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាបចូលរួមក្នុងប្រព័ន្ធផ្តល់ចំណាត់ថ្នាក់ និងការអនុវត្តស្តង់ដាបៃតង "**សេវាកម្មមួយ ស្តង់ដាមួយ**"។ • ពង្រឹងមគ្គុទ្ទេសក៍ទេសចរណ៍ឱ្យមានគុណភាពខ្ពស់÷ - យន្តការត្រួតពិនិត្យ និងតាមដានការអនុវត្តរបស់មគ្គុទ្ទេសក៍ទេសចរណ៍ដោយប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យ និងគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍។ - ពិនិត្យឡើងវិញនូវប្រព័ន្ធបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍។ • បង្កើតយន្តការក្នុងការផ្តល់ប្រឹក្សាយោបល់ ផ្ទេរបច្ចេកវិទ្យា និងតម្រង់ទិសដល់វិស័យឯកជនក្នុងការអនុវត្តតាមស្តង់ដាបៃតងក្នុងសេវាកម្មនីមួយៗ។		
សារវន្ត÷ បច្ចុប្បន្ន ការពង្រឹងគុណភាពសេវាកម្មទេសចរណ៍នៅខេត្តសៀមរាប គឺឈរលើស្តង់ដាបៃតងក្នុងឧស្សាហកម្មទេសចរណ៍ឱ្យស្របតាមស្តង់ដាកម្ពុជា និងស្តង់ដាអាស៊ាន, ស្តង់ដាចំណាត់ថ្នាក់ (សេវាកម្មមួយចំនួន) និងការពង្រឹងគុណភាព តាមរយៈការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តនានា។ ការពង្រឹងគុណភាពសេវាកម្មទេសចរណ៍ គឺយកចិត្តទុកដាក់ខ្ពស់សម្រាប់ខេត្តសៀមរាបឱ្យក្លាយជាគោលដៅទេសចរណ៍លំដាប់ខ្ពស់ និងប្រកបដោយគុណភាព ដើម្បីរួមចំណែកកែលម្អបទពិសោធន៍, បង្កើនការចំណាយ និងរយៈពេលស្នាក់នៅរបស់ភ្ញៀវទេសចរឱ្យកាន់តែប្រសើរ។ ប៉ុន្តែ ផលិតផល និង		**សមាសភាពអនុវត្តគម្រោង÷** • ជំរុញចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ**" ពិសេសផ្តោតលើការពង្រឹងគុណភាពសេវាកម្មទេសចរណ៍នៅខេត្តសៀមរាប ដូចជាសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍, ភោជនីយដ្ឋាន, មណ្ឌលកម្សាន្តមនុស្សពេញវ័យ, ទីភ្នាក់ងារទេសចរណ៍, ហាងលក់វត្ថុអនុស្សាវរីយ៍, សេវាដឹកជញ្ជូនទេសចរណ៍ និងការពង្រឹងមគ្គុទ្ទេសក៍ទេសចរណ៍ឱ្យមានគុណភាពខ្ពស់។ • ជំរុញការពង្រឹងគុណភាពសេវាកម្ម ឈរលើទស្សនាទានបៃតង ដោយអនុវត្តស្តង់ដាបៃតងកម្ពុជា **និងអាស៊ាន** ដូចជា ស្តង់ដាសណ្ឋាគារបៃតងអាស៊ាន, ស្តង់ដាបន្ទប់ប្រជុំអាស៊ាន, ស្តង់ដាផ្ទះស្នាក់អាស៊ាន, រង្វាន់ទេសចរណ៍ប្រកបដោយនិរន្តរភាពអាស៊ាន, ស្តង់ដាបង្គន់សាធារណៈអាស៊ាន, ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន, ស្តង់ដាម៉ាស្សា និងស្ប៉ាអាស៊ាន, ស្តង់ដាសហគមន៍ទេសចរណ៍អាស៊ាន និងស្តង់ដាថ្នាក់ជាតិនានាទៀត។		

<table>
<tr><td>សេវាកម្មទេសចរណ៍មួយចំនួននៅមានការខ្វះខាត និងមិនទាន់អាចឆ្លើយតបនឹងសេចក្តីត្រូវការទាំងស្រុងរបស់ភ្ញៀវទេសចរនៅឡើយ ដូចជា សណ្ឋាគារ ផ្ទះសំណាក់ ហាងលក់វត្ថុអនុស្សាវរីយ៍។ល។</td><td colspan="2">• ជំរុញអនុវត្តស្តង់ដាចំណាត់ថ្នាក់ក្នុងឧស្សាហកម្មទេសចរណ៍ រួមមាន ស្តង់ដាចំណាត់ថ្នាក់សណ្ឋាគារ, ស្តង់ដាចំណាត់ថ្នាក់ភោជនីយដ្ឋាន, ស្តង់ដាចំណាត់ថ្នាក់មណ្ឌលកម្សាន្តមនុស្សពេញវ័យ។ល។
• ជំរុញការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពបុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍
• អនុវត្តការផ្ទេរបច្ចេកវិទ្យា ក្នុងការគាំទ្រការអនុវត្តស្តង់ដាគុណភាព និងស្តង់ដាបៃតង។</td></tr>
<tr><td>គោលបំណង÷
គម្រោងនេះ មានគោលបំណងដើម្បីលើកកម្ពស់គោលដៅទេសចរណ៍ខេត្តសៀមរាបជាគោលដៅទេសចរណ៍គុណភាពកម្រិតតំបន់ និងពិភពលោក។</td><td colspan="2">លទ្ធផលនៃគម្រោង÷ លទ្ធផលនៃគម្រោង គឺធ្វើយ៉ាងណាឱ្យខេត្តសៀមរាបក្លាយជាគោលដៅទេសចរណ៍លំដាប់ខ្ពស់ និងប្រកបដោយគុណភាពតាមរយៈការជំរុញសេវាកម្មទេសចរណ៍ទាំងអស់អនុលោមតាមស្តង់ដាបៃតង
• ការសម្រេចបានទស្សនៈ “សេវាកម្មមួយ ស្តង់ដាមួយ”
• ការបង្កើតមជ្ឈមណ្ឌលទ្រទ្រង់សេវាកម្មទេសចរណ៍បៃតង
• ចំណាត់ថ្នាក់សម្រាប់មូលដ្ឋានអាជីវកម្មទេសចរណ៍សំខាន់ៗ។</td></tr>
<tr><td>ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម÷
គម្រោងនេះមិនមានផលប៉ះពាល់ដល់ផ្នែកបរិស្ថាន និងសង្គម។</td><td>របៀបវារៈ/ រយៈពេល÷
អនុវត្តរយៈពេលខ្លី និងមធ្យម ដោយក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍ខេត្តសៀមរាប។</td><td>ថ្លៃដើមនៃគម្រោង÷
គម្រោងនេះ គ្រោងប្រើប្រាស់ថវិកាប្រមាណ ២លានដុល្លារអាមេរិក។</td></tr>
</table>

សម្គាល់÷ អក្សរកាត់ឈ្មោះស្ថាប័ន

ក.ទ.ច = ក្រសួងទេសចរណ៍

រ.ប.ស = រដ្ឋបាលខេត្តសៀមរាប

គ.ជ.អ.ទ = គណៈកម្មាធិការជាតិអភិវឌ្ឍទេសចរណ៍

ក.អ.ជ = ក្រសួងអភិវឌ្ឍន៍ជនបទ

ក.ស.ហ.វ = ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គ.ជ.អ.ក = គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា

រ.ស.ស = រដ្ឋាករទឹកស្វយ័តខេត្តសៀមរាប

ក.វ.វ.ស = ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប.ស្ថ = ក្រសួងបរិស្ថាន

ក.ស.ក = ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អ.យ.ក = ក្រសួងអប់រំ យុវជន និងកីឡា

ស.ម.ទ = សមាគមមគ្គុទ្ទេសក៍ទេសចរណ៍

ឧ.ជ.ភ.ត = ឧទ្យានជាតិភ្នំតូលែន

ស.វ.ទ = សាលាវិជ្ជាជីវៈទេសចរណ៍

អ.ក = អគ្គិសនីកម្ពុជា

ក.ធ.ស = ក្រសួងធម្មការ និងសាសនា

ស.ខ.ល = ក្រសួងសុខាភិបាល

គ្រ.អ = គ្រឹះស្ថានអង្គរ

ក.ប= ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ប.ស.ស= បេឡាជាតិសន្តិសុខសង្គម

ស.ម = សហគមន៍មូលដ្ឋាន

ក្រ.កបទ.សអ = ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ក.ប.ទ = ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

គ.ជ.គ.ម = គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

អ.ធ.អ = អាជ្ញាធរជាតិអប្សរា

ម.ផ = ក្រសួងមហាផ្ទៃ

អ.ធ.ទ = អាជ្ញាធរទន្លេសាប

ម.ទ.ស = មន្ទីរទេសចរណ៍ខេត្តសៀមរាប

ស.ក = ក្រសួងសាធារណការ និងដឹកជញ្ជូន

ក.អ.ក = ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក.ផ.ផ = ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា

ក្រ.ធ.ទ.ឧ = ក្រសួងធនធានទឹក និងឧតុនិយម

ឧ.វ.ប.ន = ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍

ក្រ.ដ.ន.ស = ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

រ.ល.អ.ស = រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

គ.ជ.វ.ទ = គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

ក្រ.ព.ណ = ក្រសួងពាណិជ្ជកម្ម

វ.ឯ = វិស័យឯកជន

ប.ទ = ប្រតិបត្តិករទេសចរណ៍

គ.អ.ទ.ស= គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

ក.ត.អ = ក្រុមការងារអន្តរក្រសួងគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេក្វូទេសចរណ៍

គ.ស.ផ.ស = គណៈកម្មការអន្តរក្រសួងដើម្បីសិក្សា និងអនុវត្តគម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន ៣៨ខ្សែ នៅក្រុងសៀមរាប ខេត្តសៀមរាប

គ.អ.ច.ទ = គណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស